វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា
The NGO Forum on Cambodia

# របាយការណ៍វាយតម្លៃ ស្ថានភាពនិរាករណ៍សម្បទានដីសេដ្ឋកិច្ច

## ករណីសិក្សាពីខេត្តភាគឧត្តរនៃប្រទេសកម្ពុជា

ភ្នំពេញ កម្ពុជា

## មាតិកា


ពាក្យបំព្រួញ និងអក្សរកាត់ ..... v

សេចក្តីថ្លែងអំណរគុណ ..... vii

សេចក្តីសង្ខេប ..... viii

១. សេចក្តីផ្តើម ..... 1

២. គោលបំណង ..... 2

៣. សំណួរគន្លឹះ ..... 2

៤. វិធីសាស្ត្រសិក្សាស្រាវជ្រាវ ..... 3

៤.១ ការពិនិត្យលើឯកសារដែលមានស្រាប់ ..... 3

៤.២ ការប្រមូលទិន្នន័យ និងការងារទីវាល ..... 3

៥. វិសាលភាព និងដែនកំណត់ ..... 4

៦.ទិដ្ឋភាពទូទៅនៃសម្បទានដីសេដ្ឋកិច្ចក្នុងប្រទេសកម្ពុជា ..... 4

៦.១ ក្របខណ្ឌគតិយុត្តស្តីពីសម្បទានដីសេដ្ឋកិច្ច ..... 4

៦.២ ស្ថានភាពសម្បទានដីសេដ្ឋកិច្ចក្នុងប្រទេសកម្ពុជា ..... 7

**៦.២.១ សម្បទានដីសេដ្ឋកិច្ចនៅក្រោមដែនសមត្ថកិច្ចក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ** ..... 7

**៦.២.២ ស្ថានភាពសម្បទានដីសេដ្ឋកិច្ចស្ថិតនៅក្រោមសមត្ថកិច្ចក្រសួងបរិស្ថាន** ..... 11

៦.៣ និរាសករណ៍សម្បទានដីសេដ្ឋកិច្ច និងកាត់បន្ថយទំហំផ្ទៃដីស្ថិតនៅក្រោមក្រសួងបរិស្ថាន ..... 11

៦.៤ បច្ចុប្បន្នភាពតំបន់ការពារប្រទេសកម្ពុជាក្រោមដែនសមត្ថកិច្ចក្រសួងបរិស្ថាន ..... 15

**៦.៤.១ សម្បទានដីសេដ្ឋកិច្ចស្ថិតនៅក្នុងតំបន់ការពារធម្មជាតិក្រោមសមត្ថកិច្ចក្រសួងបរិស្ថាន** ..... 15

៦.៥ និរាសករណ៍សម្បទានដីសេដ្ឋកិច្ចក្រោមដែនសមត្ថកិច្ចក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ..... 17

៦.៦ បច្ចុប្បន្នភាពនៃការចុះពិនិត្យឆ្នាំ២០១៦ ..... 20

៧.លទ្ធផលសំខាន់ៗ ..... 22

៧.១ ស្ថានភាពនៃការប្រើប្រាស់ដី និងទីតាំងដីដែលបានកាត់បន្ថយទំហំផ្ទៃដីនិងរាសករណ៍ពីសម្បទានដីសេដ្ឋកិច្ច ..... 22

**៧.១.១ ស្ថានភាពនៃសម្បទានដីសេដ្ឋកិច្ចនៅក្នុងខេត្តរតនៈគីរី** ..... 22

**៧.១.២ ស្ថានភាពសម្បទានដីសេដ្ឋកិច្ចនៅក្នុងខេត្តស្ទឹងត្រែង** ........ 30

**៧.១.៣ ស្ថានភាពនៃសម្បទានដីសេដ្ឋកិច្ចនៅខេត្តឧត្តរមានជ័យ** ........ 35

**៧.១.៤ ស្ថានភាពសម្បទានដីសេដ្ឋកិច្ចនៅក្នុងខេត្តក្រចេះ** ........ 40

៧.២ ចំនួនសម្បទានដីសេដ្ឋកិច្ចដែលកំពុងប្រតិបត្តិការនៅក្នុងប្រទេសកម្ពុជា និងករណីទំនាស់ដីធ្លីដែលបានកើតឡើង ........ 45

**៧.២.១ ទស្សនៈរបស់សហគមន៍មូលដ្ឋានលើការនិរាសករណ៍សម្បទានដីសេដ្ឋកិច្ច** ........ 46

**៧.២.២ ទំនាស់ដីធ្លី និងជីវភាពរបស់សហគមន៍** ........ 47

៧.៤ សំណូមពររបស់សហគមន៍ចំពោះរាជរដ្ឋាភិបាលសម្រាប់សម្បទានដីសេដ្ឋកិច្ចដែលបាននិរាសករណ៍បច្ចុប្បន្ន51

៨. សេចក្ដីសន្និដ្ឋាន និងអនុសាសន៍ ........ 53

៨.១ សន្និដ្ឋាន ........ 53

៨.២ អនុសាសន៍ ........ 53

ឯកសារយោង ........ 56

ឧបសម្ព័ន្ធ១៖ បច្ចុប្បន្នភាពបញ្ជីក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចក្នុងខេត្តចំនួន០៤(រតនៈគីរី ស្ទឹងត្រែង ក្រចេះ និងឧត្តរមានជ័យ) ........ 1

## បញ្ជីតារាង

**លរ** **ឈ្មោះតារាង** **ទំព័រ**

តារាង ៦.១: សម្បទានដីសេដ្ឋកិច្ចចេញដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ១៩៩៦-២០១២ .. ៩

តារាង ៦.២: សម្បទានដីសេដ្ឋកិច្ចដែលបាននិរាករណ៍និងប្រគល់ដីមករដ្ឋាភិបាលវិញដោយស្ម័គ្រចិត្តក្រោមដែនសមត្ថកិច្ចក្រសួងបរិស្ថាន ........ ១១

តារាង ៦.៣: សម្បទានដីសេដ្ឋកិច្ចចំនួនពីរបានកាត់បន្ថយទំហំ និង០៤ទៀតដាក់កាលបរិច្ឆេទឱ្យកែលម្អ ក្រោមក្រសួងបរិស្ថាន ........ ១៤

តារាង ៦.៤: បច្ចុប្បន្នភាពក្រុមហ៊ុនចំនួន១៥ ស្ថិតនៅក្រោមដែនសមត្ថកិច្ចក្រសួងបរិស្ថាន២០១៦........... ១៥

តារាង ៦.៥: បញ្ជីបច្ចុប្បន្នភាពសម្បទានដីសេដ្ឋកិច្ចដែលបាននិរាសករណ៍ក្រោមដែនសមត្ថកិច្ចក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ........ ១៧

## បញ្ជីក្រាហ្វិច

**លរ** **ចំណងជើងក្រាហ្វិច** **ទំព័រ**

ក្រាហ្វិច៦.១: ផែនទីសម្បទានដីសេដ្ឋកិច្ចក្នុងប្រទេសកម្ពុជាយោងតាម*ODC* ........ ១០

ក្រាហ្វិច៧.១.១: ទស្សនៈរបស់សហគមន៍រងផលប៉ះពាល់លើអត្ថប្រយោជន៍ពីនិរាសករណ៍សម្បទានដីសេដ្ឋកិច្ច នៅខេត្តរតនៈគិរី........ ២៤

ក្រាហ្វិច ៧.១.២.ទស្សនៈរបស់សហគមន៍រងផលប៉ះពាល់លើអត្ថប្រយោជន៍ពីនិរាសករណ៍សម្បទានដីសេដ្ឋកិច្ច នៅខេត្តស្ទឹងត្រែង........ ៣១

ក្រាហ្វិច ៧.១.៣.ទស្សនៈរបស់សហគមន៍រងផលប៉ះពាល់លើអត្ថប្រយោជន៍ពីនិរាសករណ៍សម្បទានដីសេដ្ឋកិច្ច នៅខេត្តឧត្តរមានជ័យ........ ៣៦

ក្រាហ្វិច ៧.១.៤.ទស្សនៈរបស់សហគមន៍រងផលប៉ះពាល់លើអត្ថប្រយោជន៍ពីនិរាសករណ៍សម្បទានដីសេដ្ឋកិច្ច នៅខេត្តក្រចេះ........ ៤១

ក្រាហ្វិច ៧.២.១: ទស្សនៈរបស់សហគមន៍មូលដ្ឋានលើមូលហេតុដែលនាំឱ្យនិរាសករណ៍សម្បទានដីសេដ្ឋកិច្ច

នៅក្នុងប្រទេសកម្ពុជា ........................................................................................................ ៤៧
ក្រាហ្វិច ៧.២.២: ចំនួនទំនាស់ដីធ្លីរវាងក្រុមហ៊ុនសម្បទាន និងសហគមន៍ ............................................... ៤៨
ក្រាហ្វិច៧.៤.១: សំណូមពររបស់សហគមន៍រងផលប៉ះពាល់លើការកែប្រែសម្បទានដីសេដ្ឋកិច្ចដែលបាននិរាសករណ៍ .. ៥២

# ពាក្យបំព្រួញ និងអក្សរកាត់

| | |
|---|---|
| ADHOC | សមាគមអភិវឌ្ឍន៍ និងសិទ្ធិមនុស្សកម្ពុជា |
| CBO | អង្គការសហគមន៍មូលដ្ឋាន |
| CC | ក្រុមប្រឹក្សាឃុំ |
| CDC | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា |
| DPs | ដៃគូអភិវឌ្ឍន៍ |
| ELC | សម្បទានដីសេដ្ឋកិច្ច |
| EIA | វាយតម្លៃហេតុប៉ះពាល់បរិស្ថាន |
| FA | រដ្ឋបាលព្រៃឈើ |
| FiA | រដ្ឋបាលជលផល |
| GPS | ប្រព័ន្ធទីតាំងសាកល |
| GIS | ប្រព័ន្ធព័ត៌មានភូមិសាស្ត្រ |
| MAFF | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| MEF | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| MLMUPC | ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ |
| MoE | ក្រសួងបរិស្ថាន |
| MoI | ក្រសួងមហាផ្ទៃ |
| NGO | អង្គការមិនមែនរដ្ឋាភិបាល |
| NSDP | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ |
| NTFP | អនុផលព្រៃឈើ |
| PES | បង់ថ្លៃសេវាប្រព័ន្ធអេកូឡូស៊ី |
| REDD | កាត់បន្ថយការបញ្ចេញឧស្ម័នពីការបាត់បង់ និងរិចរឹលនៃព្រៃឈើ |
| RGC | រាជរដ្ឋាភិបាលកម្ពុជា |
| RS | ផែនការយុទ្ធសាស្ត្រចតុកោណ |
| SLC | សម្បទានដីសង្គមកិច្ច |

| | |
|---|---|
| SEIA | វាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គម |
| UN | សហប្រជាជាតិ |
| UNDP | កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ |
| UNFCCC | អនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ |
| WCS | អង្គការអភិរក្សសត្វព្រៃ និងសង្គម |
| WWF | មូលនិធិពិភពលោកដើម្បីធម្មជាតិ |

# សេចក្តីថ្លែងអំណរគុណ

ក្រុមសិក្សាស្រាវជ្រាវសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះអ្នកសំខាន់ៗ មួយចំនួនដែលបានចូលរួមចំណែកដ៏ធំក្នុងការសិក្សាស្រាវជ្រាវដែលរួមមានអ្នកផ្តល់ព័ត៌មានសំខាន់ៗពីស្ថាប័នរដ្ឋាភិបាល ទីភ្នាក់ងារម្ចាស់ជំនួយ សហគមន៍មូលដ្ឋាន មន្ទីរជំនាញតាមខេត្តនានា អង្គការជាតិនិងអន្តរជាតិ និងជំនាញការនានាដែលបានចំណាយពេលវេលាដ៏មានតម្លៃ និងបានផ្តល់ព័ត៌មានដ៏មានសារៈសំខាន់កំឡុងពេលសម្ភាស និងដំណើរការពិគ្រោះយោបល់។

អ្នកនិពន្ធសូមសំដែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅ និងកោតសរសើរចំពោះការគាំទ្រនិងកិច្ចសហប្រតិបត្តការល្អប្រសើររបស់គណៈកម្មាធិការគ្រប់គ្រងនៃវេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា គណៈកម្មាការត្រួតពិនិត្យរបាយការណ៍វាយតម្លៃសម្បទានដីសេដ្ឋកិច្ច ជាពិសេស លោកបណ្ឌិត តឹក វណ្ណារ៉ា លោក អ៊ុក វណ្ណារ៉ា លោក អៀ ចុង លោក ស៊ុន យូរ៉ា និងសហការីរបស់កម្មវិធីដីនិងជីវភាព ព្រមទាំងសមាជិកបណ្តាញអង្គការទាំងអស់ដែលបានផ្តល់នូវដំបូន្មានដ៏មានសារៈសំខាន់ សម្របសម្រួល និងផ្តល់ធាតុចូលសំខាន់ៗកំឡុងពេលសិក្សាស្រាវជ្រាវ និងពិគ្រោះយោបល់។ យើងខ្ញុំសូមសំដែងនូវការកោតសរសើរចំពោះអ្នកចូលរួមទាំងអស់នៅក្នុងកិច្ចប្រជុំពិគ្រោះយោបល់លើលទ្ធផលបឋមសម្រាប់សេចក្តីព្រាងរបាយការណ៍លើកទី១និងលើកទី២ ព្រមទាំងសិក្ខាសាលាពិគ្រោះយោបល់និងកិច្ចប្រជុំនានាដោយបានផ្តល់នូវមតិកែលម្អក្នុងន័យស្ថាបនា និងមតិយោបល់សម្រាប់ការអនុវត្តកន្លងមក។

**សិទ្ធិថតចម្លងឆ្នាំ២០១៧ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា**

សូមរក្សាសិទ្ធិគ្រប់យ៉ាង គ្មានផ្នែកណាមួយនៃឯកសារនេះអាចត្រូវបានផលិតឡើងវិញ រក្សាទុកក្នុងប្រព័ន្ធដែលអាចទាញយកបាន ឬបំលែងក្នុងទម្រង់ណាមួយ ឬមធ្យោបាយអេឡិចត្រូនិច យន្តកម្ម ថតចម្លង កត់ត្រា ឬមធ្យោបាយផ្សេងៗទៀតដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីវេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជាឡើយ។

**ការដកស្រង់**

វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា២០១៧. *របាយការណ៍វាយតម្លៃស្ថានភាពនិរាសករណ៍សម្បទានដីសេដ្ឋកិច្ចៈករណីសិក្សាពីខេត្តភាគឧត្តរនៃប្រទេសកម្ពុជា*, រាជធានីភ្នំពេញ, ប្រទេសកម្ពុជា

## សេចក្តីសង្ខេប

ក្រសួងបរិស្ថាននិងក្រសួងកសិកម្ម រុក្ខប្រមាញ់ និងនេសាទគឺស្ថាប័នសេនាធិការរបស់រាជរដ្ឋាភិបាលកម្ពុជាដែលមានសិទ្ធិផ្តល់សម្បទានដីសេដ្ឋកិច្ច និងសម្បទានព្រៃសេដ្ឋកិច្ចទៅក្រុមហ៊ុនឯកជនតាំងពីឆ្នាំ១៩៩៥។ ការវិនិយោគខ្នាតធំលើដំណាំកសិកម្មនិងកសិ-ឧស្សាហកម្មគឺជាផ្នែកមួយនៃយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលកម្ពុជាដោយផ្តោតលើកំណើនសេដ្ឋកិច្ច។ អនុលោមតាមច្បាប់ភូមិបាលឆ្នាំ២០០១ សម្បទានដីសេដ្ឋកិច្ចផ្តល់ក្នុងគោលបំណងសេដ្ឋកិច្ចនិងសង្គម។ មានតែដីឯកជនរបស់រដ្ឋប៉ុណ្ណោះដែលអាចផ្តល់ជាសម្បទានដីសេដ្ឋកិច្ច និងទំហំផ្ទៃដីសម្បទានមួយមិនឱ្យលើសពី១០.០០០ហិកតា។ បុគ្គលម្នាក់ ឬស្ថាប័នស្របច្បាប់មួយអនុញ្ញាត្តកាន់កាប់ដីសម្បទានច្រើន ប៉ុន្តែទំហំផ្ទៃដីសរុបមិនឱ្យលើសពី១០.០០០ហិកតា។ សម្បទានដីសេដ្ឋកិច្ចគឺជាការជួលរយៈពេលវែងដែលអាចផ្តល់រហូតដល់រយៈពេល៩៩ឆ្នាំ ហើយគោលបំណងសម្បទានដីសេដ្ឋកិច្ចមិនអាចក្លាយជាម្ចាស់កម្មសិទ្ធិលើដីនេះទេ។ អ្នកដែលទទួលបានដីសម្បទានដីសេដ្ឋកិច្ចអនុញ្ញាតឱ្យឈូសឆាយដីដើម្បីដាំដុះដំណាំកសិ-ឧស្សាហកម្ម។

ដោយផ្អែកលើការវិភាគនិងករណីសិក្សាទាំងបួន ចំនួនក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចដែលកំពុងបន្តដំណើរការនៅក្រោមសមត្ថកិច្ចក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងបរិស្ថានមានចំនួន២២៨ក្រុមហ៊ុន ដែលមានផ្ទៃដីសម្បទានសរុប១,៥៣លានហិកតា ទូទាំងប្រទេសកម្ពុជា។ ចំនួនក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចដែលបាននិរាករណ៍មានចំនួន៣៤ក្រុមហ៊ុន (១១ក្រុមហ៊ុនស្ថិតនៅក្រោមសមត្ថកិច្ចក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង២៣ ក្រុមហ៊ុនស្ថិតនៅក្រោមក្រសួងបរិស្ថាន)។ ការទទួលបានព័ត៌មានរបស់សាធារណៈជនអំពីសម្បទានដីសេដ្ឋកិច្ច និងឯកសារគតិយត្តពុំសូវមានតម្លាភាព។ ចំពោះបញ្ហាសិទ្ធិមនុស្ស សហគមន៍ដែលរងផលប៉ះពាល់ពីសម្បទានដីសេដ្ឋកិច្ចមិនអាចទទួលបានព័ត៌មាន ហើយមិនបានចូលរួមពេញលេញក្នុងដំណើរការនៃការធ្វើសេចក្តីសម្រេចចិត្ត។ ក្រុមហ៊ុនដែលទទួលបានសម្បទានដីសេដ្ឋកិច្ចមួយចំនួនមិនបានបំពេញតាមកាតព្វកិច្ចផ្លូវច្បាប់របស់ប្រទេសកម្ពុជាតម្រូវនោះទេ ដូចជារបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន(EIA) ការធ្វើអនុបយោគដីសាធារណៈរបស់រដ្ឋ ការចុះបញ្ជីដីរដ្ឋ ការកាប់ឈើខុសច្បាប់ និងព្រំប្រទល់ដីសម្បទានត្រួតស៊ីគ្នាជាមួយដីសហគមន៍ ជាដើម។ ភាគច្រើននៃសម្បទានដីសេដ្ឋកិច្ចត្រូវបានផ្តល់នៅក្នុងតំបន់ការពារធម្មជាតិ។ ការផ្តល់សំណងរបស់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចដល់សហគមន៍មិនអាចទទួលយកបាន ដោយសារតែតម្លៃទាបជាងទីផ្សារ ទំហំដីតូចជាងមុន ដីគ្មានជីជាតិ និងបាត់បង់ព្រៃឈើធម្មជាតិ។ ភាគច្រើននៃក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចដែលបាននិរាសករណ៍មិនគោរពតាមច្បាប់ជាធរមានរបស់ប្រទេសកម្ពុជា និងបានចូលរួមដល់ការកាប់ឈើខុសច្បាប់ ព្រមទាំងរំលោភសិទ្ធិមនុស្សផងដែរ។

### អនុសាសន៍

*សម្រាប់ក្រសួងពាក់ព័ន្ធរបស់រាជរដ្ឋាភិបាលកម្ពុជា*

1) ពង្រឹង និងជំរុញការអនុវត្តច្បាប់របស់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចនីមួយៗពាក់ព័ន្ធនឹងការធ្វើអនុបយោគដីសាធារណៈរបស់រដ្ឋ វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ការចុះបញ្ជីដីឯកជនរបស់រដ្ឋជាមួយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បទល្មើសឈើខុសច្បាប់ក្នុងតំបន់ជុំវិញគម្រោងសម្បទានដីសេដ្ឋកិច្ច។ល។
2) ក្រុមហ៊ុនទីប្រឹក្សាឯករាជ្យទាំងអស់ដែលនឹងធ្វើការសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម(SEIA) គួរ

តែពិនិត្យមើលឡើងវិញ និងជានាគុណភាពដោយក្រសួងបរិស្ថាន។ សហគមន៍រងផលប៉ះពាល់ អង្គការមិនមែនរដ្ឋាភិបាល អង្គការមូលដ្ឋាន និងអ្នកពាក់ព័ន្ធផ្សេងៗទៀតគួរតែចូលរួមពិគ្រោះយោបល់ ចរចារ និងដាក់បញ្ចូលនូវមតិយោបល់របស់ពួកគេឱ្យបានពេញលេញនៅគ្រប់ដំណាក់កាលទាំងអស់នៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម។ ជានាថាលទ្ធផលនៃរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមគួរតែអាចរកបានជាសាធារណៈ ការផ្សព្វផ្សាយឱ្យបានទូលំទូលាយ ប្រជាជនមូលដ្ឋានអាចយល់ខ្លឹមសារបានអាចរកបាននៅលើក្តាព័ត៌មានមូលដ្ឋានដែលស្ថិតនៅជិតទីតាំងគម្រោងសម្បទានដីសេដ្ឋកិច្ច ព្រមទាំងដាក់លើគេហទំព័រ។

3) អនុលោមតាមកិច្ចសន្យា និងផែនការមេថ្មីរបស់ក្រុមហ៊ុននីមួយៗ ក្រសួងពាក់ព័ន្ធរបស់រាជរដ្ឋាភិបាលគួរតែបន្តតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តប្រចាំឆ្នាំឱ្យបានម៉ត់ចត់។ ផ្តល់ឱកាសដល់សហគមន៍ដែលរងផលប៉ះពាល់ដើម្បីចូលរួមក្នុងដំណើរការវាយតម្លៃការអនុវត្តប្រចាំឆ្នាំ និងផ្តល់ភស្តុតាង/ធាតុចូលដើម្បីគាំទ្រដំណើរការធ្វើសេចក្តីសម្រេចចិត្ត។
4) ទំនាស់ដីធ្លីរវាងសហគមន៍ និងក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចគួរតែដោះស្រាយឱ្យបានរួចរាល់មុនពេលឈូសឆាយព្រៃឈើ។ ការឈូសឆាយដីនិងព្រៃគួរតែទទួលបានការអនុម័តដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទជាមុនសិន។
5) មុខរបរចិញ្ចឹមជីវិតតាមបែបប្រពៃណី ទំនៀមទំលាប់សហគមន៍ជនជាតិដើមភាគតិច និងតំបន់បេតិកភណ្ឌគួរតែរៀបចំផែនទី និងបោះបង្គោលព្រំសម្រាប់គោលបំណងអភិរក្ស និងផែនការ។ ការផ្តល់សម្បទានដីសេដ្ឋកិច្ចគួរតែជៀសវាងនៅទីកន្លែងនោះ ឬជិតទីតាំងនោះ។
6) ដើម្បីជៀសវាងការបកស្រាយខុសគ្នារបស់អ្នកពាក់ព័ន្ធ ជាពិសេស អង្គការសង្គមស៊ីវិល និងរដ្ឋាភិបាលលើស្ថិតិសម្បទានដីសេដ្ឋកិច្ច ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គួរតែធ្វើបច្ចុប្បន្នភាព និងបំពេញព័ត៌មានក្នុងបញ្ជីក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច និងព្រៃសម្បទានដែលនៅមានសកម្មភាពឱ្យបានពេញលេញដោយរួមបញ្ចូលនូវវឌ្ឍនភាពនៃប្រតិបត្តិការគម្រោង និងដាក់ជូនឱ្យសាធារណៈជនអាចរកបាននៅពេលណាមួយសមស្រប។ បញ្ជីឈ្មោះក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចគួរតែមានព័ត៌មានពេញលេញរួមមានព័ត៌មានលម្អិតរបស់ម្ចាស់ក្រុមហ៊ុន ភាគហ៊ុន ម្ចាស់ដើមរបស់ក្រុមហ៊ុន និងអាសយដ្ឋានទំនាក់ទំនងលម្អិតរបស់ក្រុមហ៊ុននៅក្នុងស្រុក (ការិយាល័យក្នុងប្រទេស និងទីតាំងដែលអាចរកឃើញ) ការបង់ថ្លៃឈ្នួលសម្បទាន និងចំណូលបានពី សម្បទានដីសេដ្ឋកិច្ច។ ព័ត៌មានទាំងនេះគួរតែមានទាំងភាសាខ្មែរ និងអង់គ្លេស។
7) យោងតាមសំណូមពររបស់សហគមន៍ដែលរងផលប៉ះពាល់ពីគម្រោង សម្បទានដីសេដ្ឋកិច្ចដែលបាននិរាសករណ៍គួរតែសម្បទានទៅគ្រួសារក្រីក្រដែលពុំមានដី និងគ្រួសារទីទាល់ក្រដើម្បីដាំដុះដំណាំកសិកម្ម និងបង្កើនប្រាក់ចំណូល ដោយអនុលោមតាមយន្តការរបស់រាជរដ្ឋាភិបាលដែលមានស្រាប់។ ផ្ទៃដីព្រៃដែលនៅសល់ពីការនិរាសករណ៍សម្បទានដីសេដ្ឋកិច្ចគួរតែរក្សាទុកជាតំបន់អភិរក្សព្រៃឈើ ឬតំបន់ស្តារព្រៃឈើឡើងវិញ។ ក្រសួងពាក់ព័ន្ធគួរតែផ្តល់នូវការគាំទ្របច្ចេកទេសដល់ការងារទាំងនេះ។
8) ការបាត់បង់ ឬវិចរឹលបរិស្ថាន ការហូរច្រោះដី ផលប៉ះពាល់សេដ្ឋកិច្ច និងសង្គម ការបាត់បង់ជីវៈចម្រុះនិងប្រព័ន្ធអេកូឡូស៊ីដោយសារតែការអនុវត្តមិនស្របតាមច្បាប់ និងសម្មភាពរបស់ក្រុមហ៊ុនសម្បទានគួរតែផ្តល់សំណងសមរម្យ និងមានវិធានការតាមផ្លូវច្បាប់។

## សម្រាប់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច

1) ស្តង់ដានៃការទទួលខុសត្រូវសង្គម(CSR)គួរតែអនុវត្តដោយក្រុមហ៊ុនទាំងអស់។ ការតាំងទីលំនៅថ្មីគួរតែពិគ្រោះយោបល់ជាមួយប្រជាជនរងផលប៉ះពាល់ឱ្យបានពេញលេញ និងគោលរពតាមស្តង់ដាសិទ្ធិមនុស្ស និងតម្រូវការជាមូលដ្ឋានរបស់មនុស្ស។ ស្តង់ដាដោយសេរី ជាមុនដោយមានព័ត៌មានគ្រប់គ្រាន់(FPIC) គួរតែអនុវត្តឱ្យបានម៉ឺងម៉ាត់នៅពេលពិគ្រោះយោបល់ជាមួយជនជាតិដើមភាគតិច។
2) ដើម្បីចូលរួមចំណែកក្នុងគោលនយោបាយកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាល ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចគួរតែផ្តល់ការងារដល់ប្រជាជនមូលដ្ឋានឱ្យបានច្រើនដើម្បីធ្វើការជាមួយក្រុមហ៊ុនដោយទទួលបានប្រាក់ឈ្នួល/ប្រាក់បៀវត្សសមរម្យ។ លក្ខណ្ឌការងារគួរតែអនុលោមតាមច្បាប់ស្តីពីការងារនៃប្រទេសកម្ពុជា។
3) សហគមន៍ដែលរស់នៅជុំវិញសម្បទានដីសេដ្ឋកិច្ចគួរតែអាចប្រើប្រាស់ផ្លូវថ្មី និងមិនហាមឃាត់ការធ្វើដំណើរនៅក្នុងទីតាំងដីសម្បទានសេដ្ឋកិច្ច។
4) ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចគួរតែផ្តល់ការគាំទ្រដើម្បីជាប្រយោជន៍សង្គម ដូចជា សេវាសុខភាព ឱកាសអប់រំ និងវិធានការការពារបរិស្ថាន ព្រមទាំងចូលរួមចំណែកដល់សកម្មភាពអភិវឌ្ឍន៍សហគមន៍។

## សម្រាប់អង្គការមិនមែនរដ្ឋាភិបាល/អង្គការសង្គមស៊ីវិល

1) ជូនដំណឹង និងចែករំលែកព័ត៌មានស្តីពីផលប៉ះពាល់ជាសក្តានុពលលើជីវភាពរស់នៅរបស់សហគមន៍ដែលរងផលប៉ះពាល់តាមរយៈការគាំទ្រផ្នែកបច្ចេកទេស និងផ្នែកច្បាប់ទៅតាមការចាំបាច់។
2) អនុលោមតាមច្បាប់នៃក្រមបរិស្ថាន និងធនធានធម្មជាតិ(ថ្មី) លើកកម្ពស់ និងពង្រឹងការពិគ្រោះយោបល់ជាសាធារណៈលើការអភិវឌ្ឍសម្បទានដីសេដ្ឋកិច្ច ការរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ការអនុវត្តនលិខិតបទដ្ឋានគតិយុត្ត និងលក្ខណ្ឌតម្រូវផ្សេងៗនៃច្បាប់ផ្សេងៗ ចំពោះក្រុមហ៊ុនដែលកំពុងដំណើរការដើម្បីកែលម្អការអភិវឌ្ឍកសិ-ឧស្សាហកម្មកាន់តែប្រសើរចំពោះជីវភាពរស់នៅមូលដ្ឋានដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្រនៅក្នុងប្រទេសកម្ពុជា។
3) លើកកម្ពស់ការយល់ដឹងជាសាធារណៈ និងអភិវឌ្ឍន៍សមត្ថភាពសហគមន៍មូលដ្ឋានលើសិទ្ធិមនុស្ស ក្របខណ្ឌច្បាប់ សិទ្ធិដីធ្លី ដំណើការចុះបញ្ជីដីធ្លី យុទ្ធសាស្រ្តតស៊ូមតិ និងជំនាញចាំបាច់នានាទៀត។
4) អនុវត្តតាមរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងប្រភពព័ត៌មានផ្សេងៗទៀតអំពីក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច គួររៀបចំជាឯកសារការពិត ឬសម្ភារៈផ្សព្វផ្សាយសម្រាប់សហគមន៍ដែលរងផលប៉ះពាល់ពីគម្រោងដើម្បីជាព័ត៌មានសម្រាប់ពួកគាត់។

## ១. សេចក្ដីផ្ដើម

ក្រសួងបរិស្ថាននិងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ(កសក)គឺស្ថាប័នសេនាធិការរបស់រាជរដ្ឋាភិបាលកម្ពុជាដែលមានសិទ្ធិផ្ដល់សម្បទានដីសេដ្ឋកិច្ច និងសម្បទានព្រៃសេដ្ឋកិច្ចទៅក្រុមហ៊ុនឯកជនតាំងពីឆ្នាំ១៩៩៥។ យោងលើប្រព័ន្ធទិន្នន័យសម្បទានដីសេដ្ឋកិច្ចបង្ហាញថា ចំនួនក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចបានកើនឡើងយ៉ាងឆាប់រហ័សចន្លោះឆ្នាំ២០០៣ និង២០១២[1]។ ទោះជាយ៉ាងនេះក្ដី ចំនួននេះបានថយចុះមកវិញនៅចន្លោះឆ្នាំ២០១៣ និង២០១៥ បន្ទាប់ពីរាជរដ្ឋាភិបាលចេញនូវបទបញ្ជាលេខ០០១បប ក្រោមរូបភាពកំណែទម្រង់ដីធ្លីស៊ីជម្រៅដែលអនុវត្តដោយក្រសួងបរិស្ថាន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងដែនដី នគរូបនីយកម្ម និងសំណង់។ល។ កំណែទម្រង់ដីធ្លីស៊ីជម្រៅរបស់រាជរដ្ឋាភិបាលផ្ដោតសំខាន់ទៅលើការវាស់វែង និងវាយតម្លៃក្នុងគោលបំណងដើម្បីពង្រឹងការគ្រប់គ្រងដីធ្លី ការបែងចែកដីធ្លី និងការប្រើប្រាស់ដី ដើម្បីធានាសន្តិសុខម្ចាស់កម្មសិទ្ធដីធ្លី លុបបំបាត់ការកាន់កាប់ដីខុស ច្បាប់ និងទប់ស្កាត់ការប្រមូលផ្ដុំដីហើយមិនបានប្រើប្រាស់មួយចំនួននៅក្នុងដៃមនុស្សមួយក្ដាប់តូច។ កម្មវិធីនេះគឺជាកត្តាចាំបាច់មួយដើម្បីបង្កើនការបែងចែកដីកសិកម្មនៅក្នុងក្របខណ្ឌការផ្ដល់សម្បទានដីសង្គមកិច្ចដល់កសិកម្មដើម្បីលើកកម្ពស់ផលិតកម្មកសិកម្ម និងពិពិធភាវូនីយកម្មនិងកាត់បន្ថយភាពក្រីក្រនៅជនបទ[2]។ សម្បទានដីសេដ្ឋកិច្ចផ្ដល់ឥទ្ធិពលវិជ្ជមាន និងអវិជ្ជមានចំពោះសេដ្ឋកិច្ច ជីវភាពសហគមន៍ ពិសេសជនជាតិដើមភាគតិចដែលកំពុងរស់នៅក្នុង និងជុំវិញដីសម្បទានសេដ្ឋកិច្ច។

កាលពីឆ្នាំ២០១៤ គណៈកម្មាធិការជាតិសម្រាប់ដោះស្រាយទំនាស់ដីធ្លីដឹកនាំដោយ ឯកឧត្តម ប៊ិន ឈិន ឧបនាយករដ្ឋមន្ត្រីត្រូវបានបង្កើតឡើង។ គោលបំណងនៃការបង្កើតគណៈកម្មាធិការនេះដើម្បីពិនិត្យ និងសិក្សាវាយតម្លៃស៊ីជម្រៅចំពោះការអនុវត្តរបស់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចទាំងអស់ទូទាំងប្រទេស។ អនុក្រុមការងារនិងលេខាធិការដ្ឋានដែលមានសមាសភាពមកពីក្រសួងពីរ(ក្រសួងបរិស្ថាន និង ក.ស.ក) ត្រូវបានបង្កើតឡើងដើម្បីគាំទ្រដំណើរការវាយតម្លៃ និងរាយការណ៍ជូនប្រធានគណៈកម្មាធិការខាងលើដើម្បីធ្វើសេចក្ដីសម្រេចចិត្ត។ ក្រុមលេខាធិការដ្ឋានបច្ចេកទេសសម្បទានដីសេដ្ឋកិច្ចមានសមាសភាពមកពីក្រសួងពាក់ព័ន្ធរបស់រដ្ឋាភិបាលរួមមាន ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងបរិស្ថាន ដែលបានដើរតួនាទីសំខាន់ក្នុងការត្រួតពិនិត្យការអនុវត្តនៅទីវាលរបស់ក្រុមហ៊ុននីមួយៗក្នុងខេត្តចំនួន១៩។ យោងលើសេចក្ដីជូនដំណឹងរបស់ទីស្ដីការគណៈរដ្ឋមន្ត្រីឆ្នាំ២០១៥ ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចប្រមាណជា១៦២ ក្រុមហ៊ុនបានកំណត់ និងវាយតម្លៃស៊ីជម្រៅ។ ជាលទ្ធផលនៃការវាយតម្លៃ ទីស្ដីការគណៈរដ្ឋមន្ត្រីសម្រេចនិរាសករណ៍៣២ក្រុមហ៊ុន ដែលមិនបានបំពេញកាតព្វកិច្ចផ្លូវច្បាប់ មិនអនុវត្តតាមកិច្ចព្រមព្រៀង និងផែនការមេរបស់ក្រុមហ៊ុន។ ស្របពេលនោះដែរ ក្រុមហ៊ុនភាគច្រើនតម្រូវឱ្យកែសម្រួលកិច្ចព្រមព្រៀងជាថ្មីរួមបញ្ចូលទាំងផែនការមេ ទំហំផ្ទៃដីសម្បទាន ការបោះបង្គោលព្រំ ដោះស្រាយដីដែលមានជម្លោះ រយៈពេលនៃកិច្ចព្រមព្រៀង ជាដើម ។ល។ បន្ទាប់ពីនិរាសករណ៍សម្បទានដីសេដ្ឋកិច្ចឆ្នាំ២០១៥ រាជរដ្ឋាភិបាលមិនបានបញ្ចេញព័ត៌មានណាមួយ ឬទិន្នន័យអំពីស្ថានភាពនៃក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចដែលបាននិរាសករណ៍នោះទេ ថាតើដីដែលបាននិរាសករណ៍នោះធ្វើប្រទានកម្មជាដីសម្បទានសង្គមកិច្ចសម្រាប់ជីវភាពសហគមន៍ ជាដីទុកស្ដារព្រៃ និងដាំឈើឡើងវិញ ឬរក្សាទុកសម្រាប់បង្កើនគម្របព្រៃឈើ។ល។

---

[1] *វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្ដីពីកម្ពុជា ២០១៥*

[2] *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ២០១៤-២០១៨*

ទោះបីជាយ៉ាងណា រដ្ឋាភិបាលនៅបន្តការត្រួតពិនិត្យ និងអាចឈានដល់ការនិរាសករណ៍សម្បទានដីសេដ្ឋកិច្ចមួយចំនួនទៀត តែបញ្ហាសិទ្ធិដីធ្លីនៅតែប្រឈមធ្ងន់ធ្ងរដដែលនៅក្នុងប្រទេសកម្ពុជា ពីព្រោះអតីតអ្នកកាន់កាប់ដីមិនទទួលបានការបង្វិលត្រឡប់ដីមកឱ្យពួកគាត់នោះទេ។ ហើយករណីទំនាស់ដីធ្លីរវាងសហគមន៍ និងម្ចាស់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចនៅតែមិនទាន់ដោះស្រាយបាននោះឡើយ សហគមន៍មួយចំនួនត្រូវបានចាប់ខ្លួនដោយសារតែចូលរួមបាតុកម្ម ហើយមួយចំនួនទៀតត្រូវបានបញ្ជូនទៅតុលាការ។ លើសពីនេះទៅទៀត សហគមន៍ជនជាតិដើមភាគតិចគួយនៅខេត្តព្រះវិហារបានអះអាងថាដីប្រពៃណីរបស់ពួកគេត្រូវបានក្រុមហ៊ុនទន្ទ្រានយក បើទោះបីជាគាត់បានបញ្ចប់នូវជំហានទី២នៃការចុះបញ្ជីដីធ្លី ហើយបានទទួលស្គាល់ដោយក្រសួងមហាផ្ទៃក៏ដោយ[3]។

## ២. គោលបំណង

វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា តាមរយៈកម្មវិធីដីនិងជីវភាព និងបណ្តាញអង្គការសមាជិករបស់ខ្លួនបានស្នើឡើងនូវការវាយតម្លៃស្តីពីស្ថានភាពសម្បទានដីសេដ្ឋកិច្ចដែលបាននិរាករណ៍ដែលមានទីតាំងស្ថិតនៅក្នុងខេត្តគោលដៅចំនួនបួន (ក្រចេះ ស្ទឹងត្រែង រតនៈគិរី និងឧត្តរមានជ័យ)។ ការសិក្សានេះមានគោលបំណងជាក់លាក់ចំនួនបួនគឺ

1. ស្វែងយល់អំពីប្រភេទនៃដីប្រើប្រាស់និងទីតាំងដីសម្បទានដែលបានកាត់បន្ថយទំហំ និងនិរាសករណ៍ពីទំហំផ្ទៃសម្បទានដីសេដ្ឋកិច្ច
2. បង្ហាញអំពីចំនួនក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច និងករណីទំនាស់ដីធ្លីដែលបានកើតឡើងនិងកត្តាជំរុញរបស់វាដើម្បីកែលម្អការអនុវត្តក្របខណ្ឌគតិយុត្តពាក់ព័ន្ធនឹងសម្បទានដីសេដ្ឋកិច្ច
3. កំណត់ថាតើការនិរាសករណ៍សម្បទានដីសេដ្ឋកិច្ចបានចូលរួមចំណែកកែលម្អជីវភាពរស់នៅរបស់សហគមន៍មូលដ្ឋានបានដោយរបៀបណា និងគាំទ្រយន្តការកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាលបានយ៉ាងដូចម្តេច?
4. ផ្តល់ជាអនុសាសន៍ដល់អ្នកពាក់ព័ន្ធ រដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ វិស័យឯកជន និងស្ថាប័នសិក្សាស្រាវជ្រាវលើយន្តការនិរាសករណ៍សម្បទានដីសេដ្ឋកិច្ច

## ៣. សំណួរគន្លឹះ

ដើម្បីសម្រេចបាននូវគោលបំណងខាងលើ ក្រុមសិក្សាស្រាវជ្រាវត្រូវឆ្លើយនឹងសំណួរតម្រង់ទិសដូចខាងក្រោម

- តើអ្វីជាគោលបំណងនៃការប្រើប្រាស់ដីបន្ទាប់ពីនិរាករណ៍និងកាត់បន្ថយទំហំផ្ទៃដី?
- តើមានសម្បទានដីសេដ្ឋកិច្ចបានផ្តល់ថ្មីៗដែរ ឬទេ?
- តើដីនេះនឹងរក្សាទុកសម្រាប់ស្តារគម្របព្រៃឈើឡើងវិញ ឬសម្រាប់ប្រជាជនមូលដ្ឋានដើម្បីគាំទ្រជីវភាពរស់នៅប្រចាំថ្ងៃរបស់ពួកគាត់?
- តើដីសម្បទានដែលបាននិរាសករណ៍និងកាត់បន្ថយទំហំពីសម្បទានដីសេដ្ឋកិច្ចទាំងមូលជាប្រភេទដីដូចម្តេច?
- តើស្ថានភាពនៃទំនាស់ដីធ្លីលើសម្បទានដីសេដ្ឋកិច្ចនាពេលបច្ចុប្បន្នដូចម្តេចដែរ?
- តើសម្បទានដីសេដ្ឋកិច្ចប៉ុន្មានក្រុមហ៊ុនត្រូវបានកាត់បន្ថយទំហំ និងប៉ុន្មានត្រូវបាននិរាសករណ៍?

[3] *អ្នករាយការសិទ្ធិមនុស្សពិសេសរបស់អង្គការសហប្រជាជាតិ ចេញផ្សាយខែកញ្ញា ឆ្នាំ២០១៦*

- តើមានយន្តការអ្វីដើម្បីកែលម្អការអនុវត្តក្របខណ្ឌច្បាប់ពាក់ព័ន្ធសម្បទានដីសេដ្ឋកិច្ច?
- តើនិវាសករណ៍សម្បទានដីសេដ្ឋកិច្ចបានចូលរួមចំណែកកែលម្អជីវភាពសហគមន៍មូលដ្ឋានអ្វីខ្លះ និងគាំទ្រដល់យន្តការកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាលអ្វីខ្លះ?
- តើអ្វីជាមធ្យោបាយល្អបំផុតដើម្បីគាំទ្រអ្នកពាក់ព័ន្ធដើម្បីចូលរួមឱ្យកាន់តែមានប្រសិទ្ធភាពជាមួយការនិវាសករណ៍សម្បទានដីសេដ្ឋកិច្ចនាពេលបច្ចុប្បន្ននេះ?
- តើអ្វីជាតម្រូវការរបស់សហគមន៍ពីរដ្ឋាភិបាលដើម្បីប្រើប្រាស់សម្បទានដីសេដ្ឋកិច្ចដែលបាននិវាសករណ៍?
- តើសហគមន៍បានទទួលព័ត៌មានអំពីនិវាសករណ៍សម្បទានដីសេដ្ឋកិច្ចដែរ ឬទេ
- តើរដ្ឋាភិបាលមានយន្តការអ្វីដើម្បីរៀបចំនិវាសករណ៍សម្បទានដីសេដ្ឋកិច្ចទៅមុខទៀត ព្រោះព្រៃឈើលើដីសម្បទានសេដ្ឋកិច្ចនេះត្រូវបានឈូសឆាយអស់?
- តើដីសម្បទានសេដ្ឋកិច្ចដែលបាននិវាសករណ៍មានស្ថានភាពដូចម្តេច?
- តើអ្វីជាភាពខុសគ្នារវាងការផ្តល់សំណងពីក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចនៅក្នុងក្រុមជនជាតិដើមភាគតិច និងប្រជាជនដែលមិនមែនជនជាតិដើមភាគតិច?

## ៤. វិធីសាស្ត្រសិក្សាស្រាវជ្រាវ

### ៤.១ ការពិនិត្យលើឯកសារដែលមានស្រាប់

ការសិក្សាស្រាវជ្រាវលើឯកសារដែលមានស្រាប់គឺជំហានដំបូងនៃវិធីសាស្ត្រសិក្សាស្រាវជ្រាវដើម្បីពិនិត្យមើលឯកសារដែលមានស្រាប់ពាក់ព័ន្ធនឹងអភិបាលកិច្ចដីធ្លី ការចុះបញ្ជីដីធ្លី ក្របខណ្ឌគតិយុត្តនិងសិទ្ធិជនជាតិដើមភាគតិចក្នុងប្រទេសកម្ពុជា។ ការពិនិត្យមើលឯកសាររួមមានច្បាប់ភូមិបាល និងគោលនយោបាយ ផែនការយុទ្ធសាស្ត្ររបស់រដ្ឋាភិបាល ច្បាប់ស្តីពីការគ្រប់គ្រងធនធានធម្មជាតិ ច្បាប់ព្រៃឈើ ច្បាប់ស្តីពីតំបន់ការពារធម្មជាតិ អនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ច អនុក្រឹត្យស្តីពីនីតិវិធីចុះបញ្ជីដីជនជាតិដើមភាគតិច គោលនយោបាយស្តីពីការចុះបញ្ជី និងសិទ្ធដើម្បីប្រើប្រាស់ដីសហគមន៍ជនជាតិដើមភាគតិចនៅក្នុងប្រទេសកម្ពុជា ជាដើម។

### ៤.២ ការប្រមូលទិន្នន័យ និងការងារទីវាល

អនុលោមតាមលក្ខណ្ឌការងារ(ToR) និងផែនការការងារដែលបានឯកភាពគ្នាជាមួយវេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា ដំណាក់កាលទី២នៃការវាយតម្លៃនេះគឺជាការងារនៅទីវាលក្នុងខេត្តគោលដៅចំនួនបួន(ក្រចេះ ស្ទឹងត្រែង រតនៈគីរី និងឧត្តរមានជ័យ)។ ការសិក្សានេះបានប្រើប្រាស់ឧបករណ៍ស្រាវជ្រាវជាច្រើនដើម្បីប្រមូលព័ត៌មានដូចជា ការអង្កេតតាមគ្រួសារ ការសម្ភាសន៍ជាមួយអ្នកផ្តល់ព័ត៌មានសំខាន់ៗ ការសង្កេតនិងការសម្ភាសន៍ជាក្រុមដើម្បីប្រមូលទាំង**ទិន្នន័យគុណភាព និងបរិមាណ**។ ការសិក្សានេះនឹងផលិតជាករណីសិក្សាចំនួនបួនរបស់សហគមន៍ដែលរងផលប៉ះពាល់ជីវភាពរស់នៅរបស់គេដោយសារក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច។ សហគមន៍ដែលរងផលប៉ះពាល់ដែលកំពុងរស់នៅក្នុងខេត្តគោលដៅនឹងត្រូវបានសម្ភាសន៍ផងដែរដោយប្រើប្រាស់បញ្ជីសំណួរ។

ការសិក្សាស្រាវជ្រាវនេះបាន ធ្វើឡើងដោយមានការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធសំខាន់ៗ ដែលរួមមានមន្ត្រីក្រសួង ស្ថាប័នរដ្ឋាភិបាល (MoE, MAFF, MLUPC) សហគមន៍មូលដ្ឋាន អង្គការសង្គមស៊ីវិល ស្ថាប័នសិក្សាធិការ បណ្តាញអង្គការរបស់វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា អង្គការសិទ្ធិមនុស្ស, ភ្នាក់ងារអង្គការ UN ។ល។

ការសិក្សាលើឯកសារដែលមានស្រាប់ និងការពិគ្រោះយោបល់ជាមួយស្ថាប័នពាក់ព័ន្ធផ្តល់នូវគោលគំនិតសម្រាប់ក្រុមសិក្សាស្រាវជ្រាវដើម្បីបង្កើតជាអតិក្រមវាយតម្លៃដើម្បីសម្រេចគោលបំណងស្រាវជ្រាវ។

## ៥. វិសាលភាព និងដែនកំណត់

ផ្អែកលើលក្ខណ្ឌការងារនៃការសិក្សាស្រាវជ្រាវ ក្រុមសិក្សាគួរកំណត់អំពីវិសាលភាពនៃការងារនិងប្រភពព័ត៌មានដូចបានរៀបរាប់ខាងក្រោមនេះ៖

- ក្រុមស្រាវជ្រាវនឹងទទួលបានទិន្នន័យស្តីពីចំនួនសម្បទានដីសេដ្ឋកិច្ចក្នុងខេត្តចំនួនបួន តាមរយៈការសម្ភាសជាមួយមន្ត្រីរាជរដ្ឋាភិបាល (MAFF, MoE) និង NGOs ប៉ុន្តែរាល់ទិន្នន័យសម្បទានដីសេដ្ឋកិច្ចទាំងអស់ (ទិន្នន័យទាំងមូល) មិនអាច ស្វែងរកបានដោយសារតែរដ្ឋាភិបាលរក្សាទុកព័ត៌មានជាការសម្ងាត់។ ទោះបីយ៉ាងនេះក៏ដោយ ក្រុមសិក្សាស្រាវ ជ្រាវបានស្វែងរកមធ្យោបាយផ្សេងៗទៀតដើម្បីជួបជាមួយមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មន្ទីរបរិស្ថាន មន្ត្រីសាលាខេត្ត មន្ត្រីរដ្ឋាភិបាលថ្នាក់ជាតិដើម្បីទទួលបានព័ត៌មានទាំងនេះ ព្រមទាំងរកបានតាមរយៈគេហទំព័រនានា។
- ករណីសិក្សាចំនួន០៤ត្រូវបានជ្រើសរើសចេញពីខេត្តចំនួនបួន(មួយក្នុងមួយខេត្ត) ផ្អែកលើការសិក្សាឯកសារដែលមានស្រាប់ និងការសម្ភាសស៊ីជម្រៅ។ ការជ្រើសរើសករណីសិក្សានឹងផ្តោតសំខាន់លើសម្បទានដីសេដ្ឋកិច្ចដែលបាននិរាសករណ៍ក្នុងខេត្តចំនួន៤ប៉ុណ្ណោះ។
- យ៉ាងហោចណាស់អ្នកផ្តល់ព័ត៌មានសំខាន់ៗចំនួន ២០-២៥ នាក់នឹងសម្ភាសដោយរួមបញ្ចូលនូវ ក.ស.ក ក្រសួងបរិស្ថាន មន្ទីរតាមខេត្ត អាជ្ញាធរមូលដ្ឋាន ស្ថាប័នសិក្សាស្រាវជ្រាវ មេដឹកនាំសហគមន៍ ។ល។
- យ៉ាងហោចណាស់សហគមន៍គោលដៅចំនួន ១០០នាក់ក្នុងខេត្តចំនួន៤ (តំណាងសហគមន៍រងផលប៉ះពាល់ ២៥នាក់ក្នុងមួយខេត្ត) បានត្រូវសម្ភាសសម្រាប់ករណីសិក្សានីមួយៗ ការវិភាគទិន្នន័យ និងអនុសាសន៍។

## ៦.ទិដ្ឋភាពទូទៅនៃសម្បទានដីសេដ្ឋកិច្ចក្នុងប្រទេសកម្ពុជា

### ៦.១ ក្របខណ្ឌគតិយុត្តស្តីពីសម្បទានដីសេដ្ឋកិច្ច

រាជរដ្ឋាភិបាលកម្ពុជាបានលើកកម្ពស់ការវិនិយោគកសិកម្ម និងកសិ ឧស្សាហកម្មខ្នាតធំក្នុងប្រទេសកម្ពុជាតាមរយៈការផ្តល់សម្បទានដីសេដ្ឋកិច្ច(ELCs)ជាផ្នែកមួយនៃយុទ្ធសាស្ត្ររបស់ខ្លួនដោយផ្តោតសំខាន់លើកំណើនសេដ្ឋកិច្ចក្នុងវិស័យកសិកម្ម។ យោងទៅលើច្បាប់ភូមិបាលឆ្នាំ២០០១ សម្បទានដីសេដ្ឋកិច្ចគឺជា "សិទ្ធិស្របច្បាប់ដែលត្រូវបានបង្កើតឡើងដោយឯកសារគតិយុត្តមួយ" ដែលអាចប្រទានសម្រាប់គោលបំណងសង្គមនិងសេដ្ឋកិច្ច។ មានតែដីឯកជនរបស់រដ្ឋប៉ុណ្ណោះដែលផ្តល់ជាសម្បទានរយៈពេលវែងហើយទំហំសម្បទានដីមួយមិនឱ្យលើសពី១០០០០ហិកតា។ បុគ្គលម្នាក់ឬស្ថាប័នស្របច្បាប់មួយអនុញ្ញាតកាន់កាប់ដីសម្បទានច្រើនប៉ុន្តែទំហំផ្ទៃដីសរុបមិនឱ្យលើសពី១០០០០ហិកតា។ សម្បទានដីសេដ្ឋកិច្ចគឺជាការជួលរយៈពេលវែងដែលអាចផ្តល់រហូតដល់រយៈពេលអតិបរិមា៩៩ឆ្នាំ ហើយគោលបំណងសម្បទានដីសេដ្ឋកិច្ចមិនអាចក្លាយជាម្ចាស់លើដីនេះទេ។ អ្នកដែលទទួលបានដីសម្បទានដីសេដ្ឋកិច្ចអនុញ្ញាតឱ្យឈូសឆាយដីដើម្បីដាំដុះដំណាំកសិ-ឧស្សាហកម្ម។ ក្នុងរយៈពេល១២ខែបន្ទាប់ពីទទួលបានសម្បទានដីសេដ្ឋកិច្ចសម្បទានិកត្រូវប្រតិបត្តិការងារទៅតាមកិច្ចព្រមព្រៀង។

ក្នុងឆ្នាំ២០០៥ អនុក្រឹត្យលេខ១៤៦ ស្តីពីសម្បទានដីសេដ្ឋកិច្ចត្រូវបានបង្កើតឡើងដើម្បីផ្តល់ដីឯកជនរបស់រដ្ឋតាមរយៈកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ចជាមួយសម្បទានិកដើម្បីប្រើប្រាស់ជាអាជីវកម្មលើដំណាំកសិកម្មនិងកសិ ឧស្សាហកម្ម[4]។ អនុក្រឹត្យនេះបានបញ្ជាក់ថាសម្បទានដីសេដ្ឋកិច្ចអាចផ្តល់លើដីដែលបំពេញគ្រប់លក្ខណ្ឌចំនួនប្រាំគឺ ១)ដីដែលបានចុះបញ្ជី និងធ្វើចំណាត់ថ្នាក់ថាជាដីឯកជនរបស់រដ្ឋស្របតាមអនុក្រឹត្យស្តីពីការគ្រប់គ្រងដីរដ្ឋ និងអនុក្រឹត្យស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី ឬអនុក្រឹត្យស្តីពីការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ ២)ដីដែលមានផែនការប្រើប្រាស់ដី និងអនុម័តដោយគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត/ក្រុង ហើយការប្រើប្រាស់ស្របទៅតាមផែនការនោះ ៣) ដីដែលបានធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមចំពោះការប្រើប្រាស់ និងអភិវឌ្ឍន៍ដីចំពោះគម្រោងសម្បទានដីសេដ្ឋកិច្ច ៤)ដីដែលមានដំណោះស្រាយចំពោះបញ្ហាតាំងទីលំនៅថ្មីស្របតាមក្របខណ្ឌគតិយុត្ត និងនីតិវិធីជាធរមាន។ អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យាត្រូវធានា មិនមានការបង្ខិតបង្ខំឱ្យធ្វើការតាំងទីលំនៅថ្មីដោយគ្មានការស្ម័គ្រចិត្តពីអ្នកកាន់កាប់ដីស្របច្បាប់ និងត្រូវធានាការគោរពសិទ្ធមានច្រកចេញចូលទៅកាន់ដីឯកជន ៥) ដីដែលមានការពិគ្រោះយោបល់ជាសាធារណៈអំពីគម្រោង ឬ សំណើសម្បទានដីសេដ្ឋកិច្ចជាមួយអាជ្ញាធរដែនដី និងប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់[5]។

អនុក្រឹត្យលេខ១១៨ស្តីពីការគ្រប់គ្រងដីរដ្ឋត្រូវបានបង្កើតឡើងដោយបន្ទុបន្ថយលើសម្បទានដីសេដ្ឋកិច្ច ចំពោះដីឯកជនរបស់រដ្ឋ។ ប្រសិនបើដីនោះចាត់ថ្នាក់ជាដីសាធារណៈរបស់រដ្ឋ រដ្ឋត្រូវចាត់ថ្នាក់ឡើងវិញជាដីឯកជនរបស់រដ្ឋមុនពេលផ្តល់សម្បទាន។ អនុក្រឹត្យលេខ១១៨ បានបង្កើតៈ អាជ្ញារ និងស្ថាប័នជាក់លាក់មួយដែលទទួលខុសត្រូវលើការកំណត់ ការធ្វើចំណាត់ថ្នាក់ដី ការធ្វើអនុបយោគ និងការចុះបញ្ជីដីរដ្ឋ បានផ្តល់ជាមូលដ្ឋានសម្រាប់កិច្ចសហប្រតិបត្តិការក្នុងចំណោមអន្តរក្រសួងលើការពិនិត្យការប្រើប្រាស់ និងការគ្រប់គ្រងដីរដ្ឋ ដោយរួមបញ្ចូលនូវនីតិវិធីសម្រាប់ការផ្តល់មតិយោបល់ពីសាធារណៈជនផងដែរ។

នៅខែឧសភា ឆ្នាំ២០១២ នាយករដ្ឋមន្ត្រីបានចេញបទបញ្ជាលេខ០១បប ដើម្បីផ្អាកការផ្តល់ដីសម្បទានដីសេដ្ឋកិច្ចថ្មី និងអំពាវឱ្យមានការពិនិត្យឡើងវិញនូវសម្បទានដីសេដ្ឋកិច្ចទាំងអស់ដែលមានស្រាប់ដើម្បីផ្ទៀងផ្ទាត់មើលអំពីការអនុវត្តក្របខណ្ឌច្បាប់របស់ពួកគេ។ ដោយផ្អែកលើបទបញ្ជា០១បប បណ្ណកម្មសិទ្ធដីធ្លីបានផ្តល់ដល់អ្នកដែលបានកាន់កាប់ដីជាក់ស្តែងតាមរយៈ "យុទ្ធសាស្ត្រស្បែកខ្លា" ដោយមានគោលបំណងដើម្បីអនុញ្ញាតឱ្យសហគមន៍រស់នៅតាមផ្នែកៗនៃសម្បទានដីសេដ្ឋកិច្ច និងតំបន់ការពារ។ អនុលោមតាមបទបញ្ជាលេខ០១បប ចំនួននៃការផ្តល់សម្បទានដីសេដ្ឋកិច្ចថ្មីបានថយចុះយ៉ាងគំហុកចន្លោះឆ្នាំ២០១២ ទៅ២០១៥[6]។

នៅខែឧសភា ឆ្នាំ២០១៤ មានប្រកាសរួមរវាងក្រសួងបរិស្ថាន និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទស្តីពីការពង្រឹង និងការគ្រប់គ្រងសម្បទានដីសេដ្ឋកិច្ច។ គោលបំណងនៃប្រកាសរួមនេះគឺដើម្បីកែលម្អការអនុវត្ត និងបច្ចេកទេសពាក់ព័ន្ធនឹងការគ្រប់គ្រងសម្បទានដីសេដ្ឋកិច្ចក្នុងប្រទេសកម្ពុជា ក្នុងទិសដៅដើម្បីធានាថារាល់សម្បទានដីសេដ្ឋកិច្ចទាំងអស់នឹងប្រើប្រាស់ក្នុងបរិបទការអភិវឌ្ឍន៍ដោយនិរន្តរភាព តម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាព។

នៅខែសីហា ឆ្នាំ២០១៤ រាជរដ្ឋាភិបាលកម្ពុជាបានចេញសេចក្តីសម្រេចលេខ១២៥ សសរ ដើម្បីបង្កើតក្រុម

---

[4] *មាត្រា២ អនុក្រឹត្យលេខ១៤៦ ស្តីពីសម្បទានដីសេដ្ឋកិច្ច ២០០៥*

[5] *មាត្រា៤ អនុក្រឹត្យលេខ១៤៦ ស្តីពីសម្បទានដីសេដ្ឋកិច្ច ២០០៥*

[6] *វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា(២០១៦)វិភាគស្ថិតិសម្បទានដីសេដ្ឋកិច្ចក្នុងប្រទេសកម្ពុជា*

ការងារអន្តរក្រសួងដើម្បីត្រួតពិនិត្យ អង្កេតនិងវាយតម្លៃសម្បទានដីសេដ្ឋកិច្ចដែលមានសមាសភាពមកពីក្រសួង ស្ថាប័នពាក់ព័ន្ធ និងក្រុមប្រឹក្សាខេត្ត។

នៅខែវិច្ឆិកា ឆ្នាំ២០១៤ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរដ្ឋមន្ត្រីក្រសួងបរិស្ថានបានចាត់តាំងក្រុមការងារដើម្បីវាស់វែង ត្រួតពិនិត្យ និងវាយតម្លៃស៊ីជម្រៅប្រចាំឆ្នាំចំពោះការអនុវត្តរបស់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចទាំងអស់ដែលស្ថិតនៅក្រោមដែនសមត្ថកិច្ចរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងបរិស្ថាន និងអាជ្ញាធរខេត្ត។ ការងារទទួលខុសត្រូវសំខាន់ៗរបស់ក្រុមការងារគឺធ្វើការសិក្សានៅទីវាលដែលស្ថិតនៅក្នុងទីតាំងក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចនីមួយៗ ដើម្បផ្ទះបញ្ជាំងជាមួយផែនការមេ និងកិច្ចព្រមព្រៀងជាមួយក្រសួង និងខេត្ត។ ក្រុមការងារនេះក៏បានត្រួតពិនិត្យលើការអនុវត្តច្បាប់របស់ក្រុមហ៊ុនសម្បទាន ទំនាស់ដីធ្លីជាមួយសហគមន៍ បញ្ហាបច្ចេកទេសការចុះបញ្ជីដី ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងការអនុវត្តក្របខណ្ឌច្បាប់ផ្សេងៗទៀត។ លទ្ធផលនៃការវាយតម្លៃរបស់ក្រុមការងារបានដាក់ជូនទៅរដ្ឋមន្ត្រីដើម្បីត្រួតពិនិត្យមុនពេលដាក់ជូនទីស្តីការគណៈរដ្ឋមន្ត្រីចាត់វិធានការបន្ត និងធ្វើសេចក្តីសម្រេចចិត្ត។

នៅដើមឆ្នាំ២០១៥ ទីស្តីការគណៈរដ្ឋមន្ត្រីដឹកនាំដោយឧបនាយករដ្ឋមន្ត្រី(ឯកឧត្តម ប៊ិន ឈិន)បានអញ្ជើញ ក្រុមការងារអន្តក្រសួងប្រជុំ។ លទ្ធផលនៃកិច្ចប្រជុំបានចេញនូវសេចក្តីជូនដំណឹង (ស.ជ.ណ) ដោយបង្ហាញថា ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចចំនួន២៣ស្ថិតនៅក្រោមដែនសមត្ថកិច្ចក្រសួងបរិស្ថាន និងក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចចំនួន១២ ស្ថិតនៅក្រោមដែនសមត្ថកិច្ចរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទត្រូវបាននិរាសករណ៍ដែលមានទំហំផ្ទៃដីសរុប៩០.៦៨២ហិកតា ក្រុមហ៊ុនសម្បទានចំនួន៣ ក្រោមសមត្ថកិច្ចក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានប្រគល់ដីសម្បទានមករដ្ឋាភិបាលវិញដែលមានផ្ទៃដីសរុប ២៥.៨៥៥ហិកតា ក្រុមហ៊ុនសម្បទានចំនួន០២បានកាត់បន្ថយទំហំផ្ទៃដី ហើយក្រុមហ៊ុនសម្បទានចំនួន១៣៨បានអនុញ្ញាឱ្យបន្តសកម្មភាពរបស់ខ្លួន និងបានកំណត់ពេលវេលាជាក់លាក់ដើម្បីអនុវត្តនីតិវិធីដោយកែសម្រួលផែនការមេ និងធ្វើកិច្ចសន្យាថ្មីជាមួយរដ្ឋាភិបាល។



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

សេចក្តីសម្រេច
ស្តីពី
និរាករណ៍សេចក្តីសម្រេចលេខ ១២៥.សសរ
ចុះថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០១៤ ស្តីពីការបង្កើតគណៈកម្មការ
អន្តរក្រសួងដើម្បីត្រួតពិនិត្យ វាស់វែង និងវាយតម្លៃសម្បទានដីសេដ្ឋកិច្ច

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
-យោងសេចក្តីជូនដំណឹងលេខ ២២៥ សជណ ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០១៦ របស់ទីស្តីការគណៈរដ្ឋមន្ត្រី

ក្នុងឱកាសសម្ពោធដាក់ឱ្យប្រើប្រាស់អាគារទីស្តីការក្រសួងបរិស្ថានថ្មី កាលពីថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៦ សម្តេចតេជោ នាយករដ្ឋមន្ត្រី ហ៊ុន សែន បានកោតសរសើរការប្តេជ្ញាខ្ពស់របស់គណៈកម្មាធិការអន្តរក្រសួងដែលបានចំណាយពេលតិចជាងមួយឆ្នាំដើម្បីបញ្ចប់ការវាយតម្លៃសម្បទានដីសេដ្ឋកិច្ចទូទាំងប្រទេសកម្ពុជា។ នាយករដ្ឋមន្ត្រីទទួលស្គាល់ថាទំហំផ្ទៃដីសរុបនៃសម្បទានដីសេដ្ឋកិច្ចទាំងអស់ទូទាំងប្រទេសមានចំនួនជាង២លានហិកតា។ ចំនួននេះមានភាពប្រហាក់ប្រហែលគ្នាទៅនឹងប្រព័ន្ធទិន្នន័យសម្បទានដីសេដ្ឋកិច្ចរបស់អង្គការទិន្នន័យអំពីការអភិវឌ្ឍ(ODC) និងរបាយការណ៍វិភាគស្ថិតិសម្បទានដីសេដ្ឋកិច្ចឆ្នាំ២០១៥ របស់វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា។ បន្ទាប់ពីការត្រួតពិនិត្យ និងនិរាករណ៍ចំនួនសម្បទានដីសេដ្ឋកិច្ចបានថយចុះរហូតដល់១,៩លានហិកតា ដែលបានអនុញ្ញាត ឱ្យបន្តកិច្ចសន្យាដោយមានការត្រួតពិនិត្យយ៉ាងតឹងរ៉ឹងពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងបរិស្ថាន។ នាយករដ្ឋមន្ត្រីក៏បានផ្តល់អនុសាសន៍ថា រាល់សម្បទានដីសេដ្ឋកិច្ចដែលបាននិរាសករណ៍ទាំងអស់អាចនឹងបង្វិលទៅជា

ដីសង្គមកិច្ចដើម្បីចែកជូនពលរដ្ឋដែលក្រីក្រនៅពេលអនាគត[7]។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានចេញសេចក្តីសម្រេចលេខ១១៥ ចុះថ្ងៃតី០៦ ខែកុម្ភៈ ឆ្នាំ២០១៧ ដោយបង្កើតក្រុមការងារមួយដើម្បីធ្វើការសិក្សាស្រាវជ្រាវ និងវាយតម្លៃទីតាំងដីដែលត្រូវបានរាជរដ្ឋាភិបាលដកហូតនិងនិរាសករណ៍ពីក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ដីព្រៃរិចរិល និងដីទំនេររបស់រដ្ឋដើម្បីធ្វើសារពើភណ្ឌឡើងវិញសម្រាប់ប្រើប្រាស់លើការអភិវឌ្ឍវិស័យព្រៃឈើនៅពេលអនាគត។ ក្រុមការងារត្រូវអនុវត្តតួនាទី និងការទទួលខុសត្រូវរួមមាន ១)សហការជាមួយអាជ្ញាធរខេត្តនិងស្ថាប័នពាក់ព័ន្ធដើម្បីធ្វើការសិក្សាស្រាវជ្រាវនិងវាយតម្លៃទីតាំងដីដែលត្រូវបានរាជរដ្ឋាភិបាលដកហូត និងនិរាសករណ៍ពីក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ដីព្រៃរិចរិល និងដីទំនេររបស់រដ្ឋដើម្បីធ្វើសារពើភណ្ឌឡើងវិញសម្រាប់ប្រើប្រាស់លើការអភិវឌ្ឍវិស័យព្រៃឈើ ២)សម្របសម្រួលជាមួយអ្នកពាក់ព័ន្ធដើម្បីដោះស្រាយទំនាស់ដីធ្លី ៣)ផលិតផែនទីព្រំដី បោះបង្គោលព្រំ ស្នើសុំធ្វើអនុបយោគចុះបញ្ជី ដោយមានការទទួលស្គាល់ពីអាជ្ញាធរមូលដ្ឋាន និងអ្នកពាក់ព័ន្ធ ៤)លើកសំណើដើម្បីដាក់ ជូនរដ្ឋមន្ត្រីធ្វើសេចក្តីសម្រេចចិត្ត។


ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ ១១៥

សេចក្តីសម្រេច
ស្តីពីការបង្កើតក្រុមការងារចុះសិក្សាស្រាវជ្រាវ និងវាយតម្លៃលើទីតាំងដីដែលត្រូវបានរាជរដ្ឋាភិបាលដកហូត និងនិរាករណ៍ពីក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ដីព្រៃរេចរឹល និងដីទំនេររបស់រដ្ឋ ដើម្បីធ្វើបញ្ជីសារពើភណ្ឌឡើងវិញសម្រាប់ប្រើប្រាស់លើការងារអភិវឌ្ឍវិស័យព្រៃឈើ

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ

## ៦.២ ស្ថានភាពសម្បទានដីសេដ្ឋកិច្ចក្នុងប្រទេសកម្ពុជា

### ៦.២.១ សម្បទានដីសេដ្ឋកិច្ចនៅក្រោមដែនសមត្ថកិច្ចក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

នៅខែមករា ឆ្នាំ២០១៥ ឯកឧត្តម អ៊ាង សុផល្លែត អតីតអនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ទទួលបន្ទុកសម្បទានដីសេដ្ឋកិច្ចបានលើកឡើងថាក្រុមហ៊ុនសម្បទានចំនួន៧១ដែលគ្របដណ្តប់ផ្ទៃដី៦៥៦.៣៨០ហិកតា ត្រូវបាននិរាករណ៍និងកាត់បន្ថយទំហំផ្ទៃដី ពីព្រោះក្រុមហ៊ុនទាំងនោះមិនអនុវត្តតាមកិច្ចសន្យាជាមួយរាជរដ្ឋាភិបាល និងមិនបានគោរពតាមច្បាប់របស់ប្រទេសកម្ពុជា។ នៅឆ្នាំ២០១២ នាយករដ្ឋមន្ត្រីបានអំពាវនាវឱ្យផ្អាកការផ្តល់សម្បទានដីសេដ្ឋកិច្ចថ្មីបន្ថែម និងពិនិត្យឡើងវិញនូវសម្បទានដីសេដ្ឋកិច្ចដែលមានស្រាប់។ ទោះបីយ៉ាងនេះក្តី អង្គការសង្គមស៊ីវិលសង្កេតឃើញថាក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចមួយចំនួនដែលទទួលបានគោលការណ៍ពីរាជរដ្ឋាភិបាលសម្រាប់ការវិនិយោគមិនបាននិរាសករណ៍នោះទេ។ ក្រុមហ៊ុនដែលត្រូវបាននិរាករណ៍ស្ថិតនៅក្នុងខេត្តកំពង់ស្ពឺ ព្រះសីហនុ មណ្ឌលគីរី បន្ទាយមានជ័យ ព្រះវិហារ កំពង់ធំ ឧត្តរមានជ័យ បាត់ដំបង និងខេត្តក្រចេះ[8]។

ផ្អែកលើអនុក្រឹត្យលេខ៦៩ ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៦ ក្រសួងបរិស្ថានបានផ្ទេរក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចចំនួន៧៣ ដែលស្ថិតនៅក្រោមដែនសមត្ថកិច្ចក្រសួងបរិស្ថានទៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ហើយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានផ្ទេរតំបន់ការពារនិងអភិរក្សព្រៃឈើចំនួន១៣កន្លែងនិងតំបន់ការពារព្រៃឈើចំនួន០៥ទៅក្រសួងបរិស្ថាន។ នៅក្នុងមាត្រា២នៃអនុក្រឹត្យលេខ៦៩ បញ្ជាក់ថាតំបន់ព្រៃឈើនឹងប្រែក្លាយទៅជា

[7] សន្ទរកថានាយករដ្ឋមន្ត្រី ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៦(មតិបន្ថែមរបស់នាយករដ្ឋមន្ត្រី)

[8] http://www.phnompenhpost.com/post-weekend/another-11-land-concessions-cancelled

តំបន់ការពារ និងតំបន់អភិរក្សព្រៃឈើ[9]។

ចំពោះទិន្នន័យសម្បទានដីសេដ្ឋកិច្ច និងយោងលើការសិក្សាឯកសារដែលមានស្រាប់ ចំនួនក្រុមហ៊ុន និងទំហំផ្ទៃដីរវាងអង្គការសង្គមស៊ីវិល និងទិន្នន័យរបស់រាជរដ្ឋាភិបាលមិនមានសង្គតភាពដោយសារតែទិន្នន័យដែលអាចរកបាននៅមានកម្រិត។ ដោយផ្អែកលើគេហទំព័ររបស់ក្រសួងកសិកម្ម រុក្ខប្រមាញ់ និងនេសាទ កំឡុងឆ្នាំ១៩៩៦ -២០១២ ក្រសួងកសិកម្មបានចុះកិច្ចសន្យាជាមួយក្រុមហ៊ុនចំនួន១១៨ដែលមានផ្ទៃដីសរុប១.២០៤.៧៥០ហិកតា។ របាយការណ៍វិភាគស្ថិតិសម្បទានដីសេដ្ឋកិច្ចរបស់វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្ដីពីកម្ពុជាឆ្នាំ២០១៥និងប្រព័ន្ធទិន្នន័យអង្គការទិន្នន័យអភិវឌ្ឍន៍ឆ្នាំ២០១៦ បានលើកឡើងថា ទំហំសម្បទានដីសេដ្ឋកិច្ចមានប្រហែលជា២លានហិកតាទូទាំងប្រទេស។ បច្ចុប្បន្ននេះទិន្នន័យសម្បទានដីសេដ្ឋកិច្ចលើគេហទំព័រក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទមិនអាចរកបានទៀត[10]។

នៅកំឡុងពេលកិច្ចប្រជុំជាមួយក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចទាំងអស់ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៦ ឯកឧត្តម វេង សាខុន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានបញ្ជាក់នៅក្នុងសន្ទរកថារបស់គាត់ថា *"នៅក្នុងឆមាសទី១នៃឆ្នាំ២០១៦នេះ រាជរដ្ឋាភិបាលបានអនុម័តការវិនិយោគជាគោលការណ៍ដល់ក្រុមហ៊ុនចំនួន២២៣ ក្រុមហ៊ុន។ ក្រុមហ៊ុនទាំងនេះស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងបរិស្ថាន"*។ ពាក់ព័ន្ធនឹងចំនួននេះ មន្ត្រីរដ្ឋាភិបាលបានពន្យល់ថា *ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចដែលស្ថិតនៅក្រោមខេត្តគ្រប់គ្រង (មានផ្ទៃដីតិចជាង១០០០ហិកតា) បានប្រគល់មកឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទក្នុងឆ្នាំ២០១៦នេះ (ប្រហែលជា៣៤ក្រុមហ៊ុនសម្បទាន) និងបានផ្ទេរពីក្រសួងបរិស្ថានមកតាមរយៈអនុក្រឹត្យលេខ៦៩ មានចំនួន៧៣ក្រុមហ៊ុន។ រហូតមកដល់បច្ចុប្បន្ននេះ ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចដែលស្ថិតនៅក្រោមសមត្ថកិច្ចគ្រប់គ្រងដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានកើនឡើងប្រមាណជា២២៩ ទៅ២៣០ ក្រុមហ៊ុន។* ទោះជាយ៉ាងណា មន្ត្រីរដ្ឋាភិបាលមិនអាចបញ្ជាក់ប្រាប់អំពីទំហំដីសរុបរបស់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចទាំងអស់ ដីដែលបានធ្វើចំណាត់ថ្នាក់ ដីដែលបាននិរាករណ៍ដីដែលបានកាត់បន្ថយទំហំ ជាដើម។ *គាត់បន្ថែមថា អន្តរក្រសួងដែលដឹកនាំដោយឧបនាយករដ្ឋមន្ត្រីបានត្រួតពិនិត្យសម្បទានដីសេដ្ឋកិច្ចប្រមាណជា២២៤ក្រុមហ៊ុនប៉ុណ្ណោះ(មិនបានមើលក្រុមហ៊ុនចំនួន០៥ទៀតនៅក្រចេះ) ប៉ុន្តែគាត់មិនដឹងថា ហេតុអ្វីបានជាមិនបានត្រួតពិនិត្យក្រុមហ៊ុនទាំងប្រាំនេះទេ។* អនុប្រធានមន្ទីរកសិកម្មបានលើកឡើងថាពួកគាត់មិនបានដឹងព័ត៌មានច្បាស់អំពីចំនួនសម្បទានដីសេដ្ឋកិច្ចក្នុងប្រទេសកម្ពុជា បើទោះបីជាការងារនេះស្ថិតនៅក្រោមដែនសមត្ថកិច្ចរបស់ខ្លួនក៏ដោយ។ មន្ត្រីរដ្ឋាភិបាលដែលធ្លាប់តែចូលរួមក្នុងការវាយតម្លៃសម្បទានដីសេដ្ឋ កិច្ចបានពន្យល់ថាថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទមិនអនុញ្ញាឱ្យមន្ត្រីណាមួយបញ្ចេញទិន្នន័យសម្បទានដីសេដ្ឋកិច្ចទៅសាធារណៈឬអង្គការណាមួយនោះទេ បើមិនដូច្នោះទេ តួនាទីនិងភារកិច្ចរបស់គេនឹងប៉ះពាល់[11]។

ឯកឧត្តម វេង សាខុន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានបន្ថែមថា មានក្រុមហ៊ុនចំនួន១១១ បានចុះកិច្ចសន្យាជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង០៧ក្រុមហ៊ុនទៀតទទួលបានការឯកភាពជាគោលការណ៍លើការវិនិយោគពីរាជរដ្ឋាភិបាល តែមិនទាន់បានចុះកិច្ចព្រមព្រៀងនៅឡើយទេ ៣២ក្រុមហ៊ុនបានទទួលដីសម្បទានក្រោម១០០០ហិកតា និង៧៣ ក្រុមហ៊ុនបានចុះកិច្ចព្រមព្រៀងជាមួយក្រសួងបរិស្ថាន។ សម្បទានដីសេដ្ឋកិច្ច

[9] អនុក្រឹត្យលេខ៦៩អនក្រ បក ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៦ មាត្រា១ និង២

[10] គេហទំព័រក្រសួងកសិកម្ម: www.maff.gov.kh/elc,២០១៥

[11] ការសម្ភាសជាមួយមន្ត្រីរដ្ឋាភិបាលសំខាន់ៗ ខែមករា កុម្ភៈ ឆ្នាំ២០១៧

បានផ្តល់ទៅឱ្យ២២៣ក្រុមហ៊ុន[12] ដែលមានទីតាំងស្ថិតនៅក្នុងខេត្តចំនួន១៨ ដែលមានផ្ទៃដីសរុប១,៥៩លានហិកតា"[13]។ យោងតាមរបាយការណ៍ការសែតផ្ទៃដីសម្បទានដីសេដ្ឋកិច្ចទំហំចំនួន១.៩៣៤.៨៩៦ ហិកតាបានផ្តល់ឱ្យក្រុមហ៊ុនចំនួន ២៣០ ដែល ១២២ក្រុមហ៊ុនទទួលបានអាជ្ញាប័ណ្ណពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលមានផ្ទៃដីវិនិយោគ ១.៣១៦.៣៩៦ហិកតា ខណៈដែល១១៣ក្រុមហ៊ុនទទួលអាជ្ញាប័ណ្ណពីក្រសួងបរិស្ថាន ប៉ុន្តែ២៣ក្រុមហ៊ុនបានដកអាជ្ញាប័ណ្ណបន្ទាប់ពីបរាជ័យក្នុងការអនុវត្តកិច្ចព្រមព្រៀងវិនិយោគ[14]។

**តារាង៦.១៖សម្បទានដីសេដ្ឋកិច្ចដែលផ្តល់ដោយក្រសួងកសិកម្ម រុក្ខប្រមាញ់ និងនេសាទ តាំងពីឆ្នាំ១៩៩៦ ដល់២០១២ (ទិន្នន័យផ្សេងៗពីឆ្នាំ២០១៣ដល់២០១៧ មិនអាចរកបាន)**

| ឆ្នាំ | ចំនួនសម្បទានដីសេដ្ឋកិច្ចផ្តល់ដោយក្រសួងកសិកម្ម | ទំហំផ្ទៃដី (ហ.ត) |
|---|---|---|
| 1996-1999 | 7 | 44,124 |
| 2000-2001 | 6 | 408,404 |
| 2004 | 2 | 6,100 |
| 2005 | 8 | 67,580 |
| 2006 | 16 | 136,360 |
| 2007 | 05 | 32,185 |
| 2008 | 15 | 99,968 |
| 2009 | 16 | 117,785 |
| 2010 | 15 | 117,785 |
| 2011 | 24 | 185,576 |
| 2012 | 04 | 16,607 |
| សរុប | **118** | **1,181,523** |

ប្រភព: អង្គការ Forest Trend, ២០១៥

[12] សម្បទានដីសេដ្ឋកិច្ចក្នុងរបាយការណ៍ កសក មាន២២៩ ស្ថិតនៅក្រោមការគ្រប់គ្រង

[13]សន្ទរកថារបស់ ឯកឧត្តម វេង សាខុន កំឡុងពេលជួបជាមួយក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៦

[14] កាសែតAgency Kumpuchea Press ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៥: http://www.akp.gov.kh/?p=69494




រូបភាព៦.១ ផែនទីសម្បទានដីសេដ្ឋកិច្ចក្នុងប្រទេសកម្ពុជា ដោយផ្អែកតាមទិន្នន័យអង្គការទិន្នន័យអភិវឌ្ឍន៍

ប្រភព*: ODC, https://opendevelopmentcambodia.net/profiles/economic-land-concessions/ ) download on 12 Dec 2016.*

បន្ទាប់ពីក្រុមអ្នកស្រាវជ្រាវផ្ទៀងផ្ទាត់ជាមួយប្រភពទិន្នន័យដែលអាចទុកចិត្តបានក្នុងឆ្នាំ២០១៧ រួមមានទិន្នន័យសម្បទានដីសេដ្ឋកិច្ចមកពីអង្គការសង្គមស៊ីវិល និងទិន្នន័យពីស្ថាប័នរដ្ឋាភិបាល ពិសេសស្ថាប័នរដ្ឋាភិបាលថ្នាក់ក្រោមជាតិរបស់ក្រសួងកសិកម្ម និងក្រសួងបរិស្ថាន ចំនួនដីសម្បទានសេដ្ឋកិច្ចដែលស្ថិតនៅក្រោមសមត្ថកិច្ចក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងបរិស្ថានមានចំនួន**រវាង ២២៩-២៣០ក្រុមហ៊ុន**(មានទំហំផ្ទៃដី១,៥៩លានហិកតា)ទូទាំងប្រទេសកម្ពុជា ស្របពេលដែលទិន្នន័យពីអង្គការសង្គមស៊ីវិលអះអាងថាមានចំនួន២៥៧ ក្រុមហ៊ុន ដែលមានទំហំផ្ទៃដី១,៨លានហិកតា)។ ខែមេសា ឆ្នាំ២០១៦ អតីតរដ្ឋមន្ត្រីក្រសួងកសិកម្ម ឯកឧត្តម អ៊ុក រ៉ាប៊ុន បានលើកឡើងថា ទំហំផ្ទៃដីសរុបនៃសម្បទានដីសេដ្ឋកិច្ចសរុប១,៤លានហិកតា ដែលមានទីតាំងស្ថិតនៅក្នុងខេត្តចំនួន១៨ ហើយមានក្រុមហ៊ុនទទួលបានដីសម្បទានសរុប១៧៣ ក្រុមហ៊ុន។ ការសែតក្នុងស្រុកបានរាយការណ៍ថា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទប្រមូលចំណូលរដ្ឋបាន៥លានដុល្លាអាមេរិចក្នុងមួយឆ្នាំពីសម្បទានដីសេដ្ឋកិច្ចនៅក្នុងឆ្នាំ២០១៥[15]

[15] http://www.akp.gov.kh/?p=79287, 14 April 2016

### ៦.២.២ ស្ថានភាពសម្បទានដីសេដ្ឋកិច្ចស្ថិតនៅក្រោមសមត្ថកិច្ចក្រសួងបរិស្ថាន

កំឡុងពេលសម្ពោធអាគារថ្មីក្រសួងបរិស្ថានឈ្មោះ "បរតកតេជោ" កាលពីថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៦ ឯកឧត្តម សាយ សំអាល់ រដ្ឋមន្ត្រីបរិស្ថានបានរាយការណ៍ក្នុងសន្ទរកថាស្វាគមន៍ថា មានក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចសរុប១១៣ក្រុមហ៊ុន (ទំហំផ្ទៃដីសរុប៦៤៦.២៩៦,៧៥ហិកតា) ស្ថិតនៅក្រោមដែនសមត្ថកិច្ចក្រសួងបរិស្ថានកំពុងត្រួតពិនិត្យ វាស់វែង និងវាយតម្លៃ។ យោងលើរបាយការណ៍វឌ្ឍនភាពក្រសួងបរិស្ថាន(កញ្ញា ២០១៣ ដល់ មេសា ២០១៥) បង្ហាញថាក្រុមហ៊ុនដែលទទួលបានសម្បទានដីសេដ្ឋកិច្ចចំនួន៣២ ក្នុងចំណោម១១៣ក្រុមហ៊ុនបានដាក់ជូន ទៅគណៈកម្មាធិការអន្តរក្រសួងដើម្បីត្រួតពិនិត្យ និងដាក់ជូនទៅនាយករដ្ឋមន្ត្រីដើម្បីសម្រេច។

## ៦.៣ និរាសករណ៍សម្បទានដីសេដ្ឋកិច្ច និងកាត់បន្ថយទំហំផ្ទៃដីស្ថិតនៅក្រោមក្រសួងបរិស្ថាន

យោងរបាយការណ៍របស់ក្រសួងបរិស្ថានឆ្នាំ២០១៥ មានក្រុមហ៊ុនសម្បទាន២៣(សរុបទំហំផ្ទៃដី៩០.៦៨២ហិកតា) ស្ថិតនៅក្រោមក្រសួងបរិស្ថានត្រូវបាននិរាសករណ៍ដោយរាជរដ្ឋាភិបាលនិង០៣ក្រុមហ៊ុន( ទំហំផ្ទៃដី២៥.៨៥៥ហិកតា) បានប្រគល់ដីដោយស្ម័គ្រចិត្តទៅរដ្ឋាភិបាលវិញ ហើយក្រុមហ៊ុនសម្បទានចំនួន០២ ( ទំហំផ្ទៃដី ១០.៣៨៩ហិកតា)បានកាត់បន្ថយទំហំផ្ទៃដីដោយរដ្ឋាភិបាល(ទៅ២៣៥ហិកតា) និងក្រុមហ៊ុនសម្បទាន០៤ទៀត បានកំណត់ពេលវេលារយៈពេល ០៦ខែទៅ០១ឆ្នាំដើម្បីបន្តនីតិវិធីក្រោមការតាមដានយ៉ាងតឹងរ៉ឹងពីក្រសួងបរិស្ថាន[16]។

ការនិរាសករណ៍ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចនេះបានស្វាគមន៍ដោយសាធារណៈជន អង្គការសង្គមស៊ីវិល ស្ថាប័នសិក្សាធិការ សហគមន៍ជាតិ និងអន្តរជាតិ ពិសេសសហគមន៍អឺរ៉ុប។ រដ្ឋមន្ត្រីក្រសួងបរិស្ថានបានអះអាងថា "*ការនិរាសករណ៍សម្បទានដីសេដ្ឋកិច្ចទាំងនេះបានគាំទ្រដល់សម្បទានិកដើម្បីបញ្ចៀសនូវទំនាស់ដីធ្លីជាមួយប្រជាពលរដ្ឋកម្ពុជា។ យើងក៏ពិនិត្យមើលផងដែរនូវក្រមខណ្ឌច្បាប់ និងអាណត្តរបស់ក្រសួងបរិស្ថានមុនពេលនិរាសករណ៍*"។ រដ្ឋមន្ត្រីបរិស្ថានបានលើកឡើងថា "*ដីសម្បទានដែលបាននិរាសករណ៍គឺជាដីតំបន់សេដ្ឋកិច្ចពិសេស តំបន់ទេសចរណ៍ និងតំបន់អភិរក្សព្រៃកោងកាង ដែលមានទីតាំងស្ថិតនៅ កំពង់ស្ពឺ ព្រះសីហនុ កោះកុង ព្រះវិហារ កំពង់ធំ មណ្ឌលគីរី រតនៈគីរី ឧត្តរមានជ័យ បាត់ដំបង សៀមរាប ក្រចេះ និងបន្ទាយមានជ័យ។ លើសពីនេះទៅទៀត មូលហេតុដែលឈានដល់ការនិរាសករណ៍ក្រុមហ៊ុនសម្បទានសេដ្ឋកិច្ចទាំងនេះដោយសារតែ ការពន្យាពេលអភិវឌ្ឍន៍ មិនមានភាពសកម្មក្នុងការវិនិយោគ និងហេតុផលផ្សេងៗទៀត ដូចជាការកាន់កាប់ដីត្រួតស៊ីគ្នាលើការកាន់កាប់របស់សហគមន៍ជាដើម*"។

**តារាង៦.២ និរាសករណ៍សម្បទានដីសេដ្ឋកិច្ចនិងការប្រគល់ដីដោយស្ម័គ្រចិត្តទៅរដ្ឋាភិបាលក្រោមក្រសួងបរិស្ថានឆ្នាំ២០១៥**

| លរ | ឈ្មោះក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច | ទំហំផ្ទៃដី (ហ.ត) | ទីតាំងសម្បទានដីសេដ្ឋកិច្ច | | កំណត់សម្គាល់ |
|---|---|---|---|---|---|
| | | | ទីតាំង | ខេត្ត | |
| 1. | ក្រុមហ៊ុន BSC IMPORT EXPORT Co., LTD | 4,557 | ដែនជម្រកសត្វព្រៃនៀនជូនសំ | បាត់ដំបង | អនុក្រឹត្យ ៣០៤, ២៨ វិច្ឆិកា ២០១៤ |

[16] H.E Say Sam Al 'speech during inauguration of new MoE building on 25 Feb 2016. Progress report of general directorate of local community 2016. http://www.phnompenhpost.com/national/minister-says-23-elcs-nixed

| លរ | ឈ្មោះក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច | ទំហំផ្ទៃដី (ហ.ត) | ទីតាំងសម្បទានដីសេដ្ឋកិច្ច | | កំណត់សម្គាល់ |
|---|---|---|---|---|---|
| | | | ទីតាំង | ខេត្ត | |
| 2. | ក្រុមហ៊ុន NEW COSMOS DEVELOPMENT (CAMBODIA), Co., LTD | 900 | ដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់ | កំពង់ស្ពឺ | អនុក្រឹត្យ ៣០៤, ២៨ វិច្ឆិកា ២០១៤ |
| 3. | ក្រុមហ៊ុន JIAN KING (CAMBODIA) INTERNATIONAL INVESTMENT Co., LTD | 8,568 | ឧទ្យានជាតិគីររម្យ | កំពង់ស្ពឺ | អនុក្រឹត្យ ៣០៤, ២៨ វិច្ឆិកា ២០១៤ |
| 4. | ក្រុមហ៊ុន SUON VATANAK Co., LTD | 585 | ឧទ្យានជាតិព្រះមុន្នីវង្ស (បូកគោ) និង ឧទ្យានជាតិគីររម្យ | កំពង់ស្ពឺ និង ព្រះសីហនុ | អនុក្រឹត្យលេខ ២៧០, ០៩ តុលា ២០១៤ |
| 5. | ក្រុមហ៊ុន ចាន់ រ័ត្ន | 63 | ស្រុកដូនពេញ | កោះកុង | អនុក្រឹត្យលេខ ២៧០, ០៩ តុលា ២០១៤ |
| 6. | ក្រុមហ៊ុនកសិកម្មខ្មែរអង្គរ លីមីតធីត | 9,160 | ដែនជម្រកសត្វព្រៃភ្នំព្រិច | មណ្ឌលគីរី | អនុក្រឹត្យលេខ ៣០៤, ២៨ វិច្ឆិកា ២០១៤ |
| 7. | ក្រុមហ៊ុន LKL CONSTRUCITON Co., LTD | 5,559 | ដែនជម្រកសត្វព្រៃភ្នំណាមលៀ | មណ្ឌលគីរី | អនុក្រឹត្យលេខ ៣០៤, ២៨ វិច្ឆិកា ២០១៤ |
| 8. | ក្រុមហ៊ុន RITHY KIRI SEIMA COMPANY | 5,000 | ដែនជម្រកសត្វព្រៃស្នួល | មណ្ឌលគីរី | អនុក្រឹត្យលេខ ៣០៤, ២៨ វិច្ឆិកា ២០១៤ |
| 9. | ក្រុមហ៊ុន VIMEAN SEILA Co., LTD | 987 | ឧទ្យានជាតិរាម | ព្រះសីហនុ | អនុក្រឹត្យលេខ ២៧០, ០៩ តុលា ២០១៤ |
| 10. | ក្រុមហ៊ុន SREY PAGNHA DEVELOPMETN Co., LTD | 588 | ដែនជម្រកសត្វព្រៃបឹងពែ | ព្រះវិហារ និង កំពង់ធំ | អនុក្រឹត្យលេខ ៣០៤, ២៨ វិច្ឆិកា ២០១៤ |
| 11. | ក្រុមហ៊ុន KHUNSHEA | 8,200 | ដែនជម្រកសត្វ | ឧត្តរមានជ័យ | អនុក្រឹត្យលេខ |

| ល.រ | ឈ្មោះក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច | ទំហំផ្ទៃដី (ហ.ត) | ទីតាំងសម្បទានដីសេដ្ឋកិច្ច | | កំណត់សម្គាល់ |
|---|---|---|---|---|---|
| | | | ទីតាំង | ខេត្ត | |
| | IMPORT EXPORT Co., LTD | | ព្រៃគូលែន-ព្រហ្មទេព | | ៧៨ អនក្រ .បក |
| 12. | ក្រុមហ៊ុន Blue Metro Co., LTD | 350 | ទេសចរណ៍ធម្មជាតិរាម | ព្រះសីហនុ | |
| 13. | ក្រុមហ៊ុន ហេង ប៊ុណ្ណាត | 963 | ទេសចរណ៍ធម្មជាតិរាម | ព្រះសីហនុ | |
| 14. | ក្រុមហ៊ុន Sean Heng Investment Company | 988 | អេកូទេសចរណ៍រាម | ព្រះសីហនុ | |
| 15. | ក្រុមហ៊ុន Sean Heng Investment Company | 350 | អេកូទេសចរណ៍រាម | ព្រះសីហនុ | |
| 16. | ក្រុមហ៊ុន Paradise Investment Co., LTD | 9,137 | បូទុំសាគរ | កោះកុង | |
| 17. | ក្រុមហ៊ុន Sam Nang Sambou | 1,783 | បន្ទាយឆ្មារ | បន្ទាយមានជ័យ | |
| 18. | ក្រុមហ៊ុន FU SHENG HAI Co., LTD | 7,079 | វីរៈជ័យ | រតនៈគីរី | |
| 19. | ក្រុមហ៊ុន JING ZHONG TAIN Co., Ltd | 9,936 | វីរៈជ័យ | រតនៈគីរី | |
| 20 | ក្រុមហ៊ុន Investment and Development Dai Nam (Cambodia) JSC Ltd | 8,685 | ដែនជម្រកសត្វព្រៃភ្នំព្រិច | មណ្ឌលគីរី | |
| 21. | ក្រុមហ៊ុន Do Well Plus Co Ltd | 3,110 | ដែនជម្រកសត្វព្រៃភ្នំព្រិច | មណ្ឌលគីរី | |
| 22 | ក្រុមហ៊ុន BVB Cambodia Agriculture Development Co., Ltd | 3,134 | ភ្នំគូលែន | សៀមរាប | |
| 23 | ក្រុមហ៊ុន Yee Jia Tourism Development Cambodia Company | 1000 | ស្រុកឱរ៉ាល់ | កំពង់ស្ពឺ | |

| លរ | ឈ្មោះក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច | ទំហំផ្ទៃដី (ហ.ត) | ទីតាំងសម្បទានដីសេដ្ឋកិច្ច | | កំណត់សម្គាល់ |
|---|---|---|---|---|---|
| | | | ទីតាំង | ខេត្ត | |
| ក្រុមហ៊ុនសម្បទានចំនួន០៣ ដែលប្រគល់ដីមករាជរដ្ឋាភិបាលកម្ពុជា | | | | | |
| 24 | ក្រុមហ៊ុន Try Pheap Import Export | 9,079 | វីរៈជ័យ | រតនៈគីរី | |
| 25 | ក្រុមហ៊ុន MDS THMORDA S.E.Z Co., Ltd | 9,146 | វីរៈជ័យ | រតនៈគីរី | |
| 26 | ក្រុមហ៊ុន Future Environment | 1000 | ស្រុកឱរ៉ាល់ | កំពង់ស្ពឺ | |

ប្រភព: ក្រសួងបរិស្ថាន២០១៥

**តារាង៦.៣៖ សម្បទានដីសេដ្ឋកិច្ចកាត់បន្ថយទំហំផ្ទៃដីចំនួន០២និងក្រុមហ៊ុន០៤ដែលទុកឱសានវាទក្រោមក្រសួងបរិស្ថាន**

| លរ | ឈ្មោះក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច | ទំហំផ្ទៃដី (ហ.ត) | ទីតាំងសម្បទានដីសេដ្ឋកិច្ច | | កំណត់សម្គាល់ |
|---|---|---|---|---|---|
| | | | ទីតាំង | ខេត្ត | |
| ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចចំនួន០២ដែលកាត់បន្ថយទំហំផ្ទៃដី | | | | | |
| 1. | ក្រុមហ៊ុន Kirirom Eco Tourism Investment | 609 | ទេសចរណ៍ធម្មជាតិគីរីរម្យ | កំពង់ស្ពឺ | កាត់បន្ថយមក ២០ ហ.ត |
| 2. | ក្រុមហ៊ុន TTY Agriculture Plant Development and Imex Co., Ltd | 9780 | ដែនជម្រកសត្វព្រៃស្នួល | ក្រចេះ | កាត់បន្ថយទំហំមក ២១៥ហត |
| ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចចំនួន០៤ដែលផ្តល់ឱសានវាទ០៦ខែ ទៅ១ឆ្នាំ ដោយការតាមដានតឹងរ៉ឹងពីក្រសួងបរិស្ថាន | | | | | |
| 1 | ក្រុមហ៊ុន EVERGREEN SUCCESS AND ASIA RESORT DEVELOPMENT CO., Ltd | 1,480 | ឧទ្យានជាតិរាម | ព្រះសីហនុ | ទុកពេល០៦ខែដើម្បីកែសម្រួលផែនការមេ |
| 2 | ក្រុមហ៊ុន Royal Group Co., Ltd | 1,408 | ឧទ្យានជាតិរាម | ព្រះសីហនុ | ទុកពេល០៦ខែដើម្បីកែសម្រួលផែនការមេ |
| 3 | ក្រុមហ៊ុន Jing Zhong Ri Co., Ltd | 9,224 | លំផាត់ | រតនៈគីរី | រយៈពេល១២ខែចុះកិច្ចព្រមព្រៀង |
| 4 | ក្រុមហ៊ុន Cambodia Blue Heven Limited | 9,129 | គូលែន | ព្រះវិហារ | អនុញ្ញាតឱ្យចុះកិច្ចព្រមព្រៀងលើដីដែលនៅសល់ |

ប្រភព: ក្រសួងបរិស្ថាន២០១៥

## ៦.៤ បច្ចុប្បន្នភាពតំបន់ការពារប្រទេសកម្ពុជាក្រោមដែនសមត្ថកិច្ចក្រសួងបរិស្ថាន

ចន្លោះឆ្នាំ១៩៩៣-១៩៩៩ មានតំបន់ការពារធម្មជាតិចំនួន២៣ ដោយបញ្ចូលនូវតំបន់រ៉ាមសា (ផ្ទៃដី៣.១៩៤.៧៩៦ហត) ដែលស្មើនឹង១៧%ទូទាំងប្រទេសកម្ពុជា) បង្កើតដោយព្រះរាជក្រឹត្យ ក្រោមសមត្ថកិច្ចក្រសួងបរិស្ថាន។ បន្ទាប់ពីកំណែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាលក្នុងវិស័យបរិស្ថាននិងធនធានធម្មជាតិ តំបន់ការពារធម្មជាតិចំនួន០៨ត្រូវបានបង្កើតឡើងបន្ថែមតាមសំណើររបស់ក្រសួងបរិស្ថាន។ អនុលោមតាមការផ្ទេរសមត្ថកិច្ច តំបន់ការពារ និងអភិរក្សព្រៃឈើចំនួន ១៣ ក្រោមក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវបានផ្ទេរទៅក្រសួងបរិស្ថានដោយចាប់អនុវត្តពីឆ្នាំ២០១៦ ដែលមានផ្ទៃដីសរុប២.៧១០.០៨៧ហិកតា។ បច្ចុប្បន្ននេះ ប្រទេសកម្ពុជាមានតំបន់ការពារធម្មជាតិចំនួន៤៥កន្លែងដែលមានទំហំ៥៩០៤៨៨៣ហិកតា ស្មើនឹង៣២%នៃផ្ទៃដីប្រទេសកម្ពុជា[17]។

### ៦.៤.១ សម្បទានដីសេដ្ឋកិច្ចស្ថិតនៅក្នុងតំបន់ការពារធម្មជាតិក្រោមសមត្ថកិច្ចក្រសួងបរិស្ថាន

ក្រសួងបរិស្ថានត្រូវបានសាធារណៈជន និងអ្នកសិក្សាស្រាវជ្រាវទទួលស្គាល់ថាបានផ្តល់សម្បទានដីសេដ្ឋកិច្ចនៅក្នុងតំបន់ការពារធម្មជាតិ។ បញ្ជីក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចចំនួន៧៣ ដែលស្ថិតនៅក្រោមក្រសួងបរិស្ថានបានបង្ហាញនៅក្នុងឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ៦៩ ស្តីពីការផ្ទេរដែនសមត្ថកិច្ចគ្រប់គ្រងរវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងបរិស្ថានក្នុងឆ្នាំ២០១៦។ យោងលើរបាយការណ៍វិភាគរបស់អង្គការ Forest Trends អន្តរជាតិ(២០១១) បញ្ជាក់ថា មានក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចចំនួន១០៩ ត្រូវបានផ្តល់ឱ្យនៅក្នុងតំបន់ការពារធម្មជាតិចំនួន១៦ ក្នុងចំណោម ២៣ ដែលបានបង្កើតឡើងនៅឆ្នាំ១៩៩៣ ដោយព្រះរាជក្រឹត្យ។

បើទោះបីជារដ្ឋាភិបាលបានផ្ទេររាល់សម្បទានដីសេដ្ឋកិច្ចទាំងអស់ទៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តែនៅមានក្រុមហ៊ុនវិនិយោគមួយចំនួន(ផ្តោតសំខាន់លើទេសចរណ៍ធម្មជាតិ សណ្ឋាគារ និងរីសត) នៅតែស្ថិតក្រោមដែនសមត្ថកិច្ចក្រសួងបរិស្ថាន។ ផ្អែកលើរបាយការណ៍វឌ្ឍនភាពក្រសួងបរិស្ថានខែធ្នូ ឆ្នាំ២០១៦ បានបញ្ជាក់ឱ្យឃើញថាក្រសួងបរិស្ថាននៅតែបន្តគ្រប់គ្រងក្រុមហ៊ុនចំនួន១៥ (ផ្ទៃដី៨៩.២៥២,៧៨ហិកតា)ក្នុងខេត្តចំនួន០៥(កំពង់ស្ពឺ កោះកុង ព្រះសីហនុ ពោធិ៍សាត់ និងឧត្តរមានជ័យ) ដែលមានទីតាំងស្ថិតនៅក្នុងតំបន់ការពារធម្មជាតិ។ ខាងក្រោមនេះគឺជាបញ្ជីដែលបានធ្វើបច្ចុប្បន្នភាពនៃក្រុមហ៊ុនសម្បទានដែលស្ថិតនៅក្រោមក្រសួងបរិស្ថានបន្ទាប់ពីផ្ទេរទៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**តារាង៦.៤៖ បច្ចុប្បន្នភាពក្រុមហ៊ុនសម្បទានចំនួន១៥ ក្រោមសមត្ថកិច្ចក្រសួងបរិស្ថាន ២០១៦**

| លរ | ក្រុមហ៊ុនវិនិយោគ | ទំហំផ្ទៃដី (ហ.ត) | ទីតាំង | ស្ថានភាពកិច្ចព្រមព្រៀង | ស្ថានភាពផែនការមេ |
|---|---|---|---|---|---|
| 1 | ក្រុមហ៊ុនSok Kong Import-Export Co,.Ltd | 2,200 | គីរីរម្យ កំពង់ស្ពឺ | រួចរាល់ | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាបានអនុម័ត |

[17] http://moe.gov.kh/ download on 26 December 2016 and MoE Mapping on protected area 2016

| លរ | ក្រុមហ៊ុនវិនិយោគ | ទំហំផ្ទៃដី (ហ.ត) | ទីតាំង | ស្ថានភាពកិច្ចព្រមព្រៀង | ស្ថានភាពផែនការមេ |
|---|---|---|---|---|---|
| 2 | ក្រុមហ៊ុន JW Cambodia Eco Holidays | 5,000 | បូទុមសាគរ កោះកុង | កំពុងបន្ត | កំពុងបន្ត |
| 3 | ក្រុមហ៊ុន A2A Town (Cambodia) Co.,Ltd | 2,000 | គីរីរម្យ កំពង់ស្ពឺ | រួចរាល់ | ពិនិត្យ និងអនុម័តដោយក្រសួងបរិស្ថាន |
| 4 | ក្រុមហ៊ុន A2A Town (Cambodia) Co.,Ltd | 7,668 | គីរីរម្យ, កំពង់ស្ពឺ-ព្រះសីហនុ | កំពុងបន្ត | ពិនិត្យ និងអនុម័តដោយក្រសួងបរិស្ថាន |
| 5 | ក្រុមហ៊ុន Kirirom Eco Tourism Investment | 20 | គីរីរម្យ កំពង់ស្ពឺ | មិនទាន់ | មិនទាន់រៀបចំ |
| 6 | ក្រុមហ៊ុន EVERGREEN SUCCESS AND ASIA RESORT DEVELOPMENT Co.,LTD | 1,480 | រាម ព្រះសីហនុ | រួចរាល់ | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាកំពុងពិនិត្យមើលផែនការមេ |
| 7 | ក្រុមហ៊ុន ROYAL GROUP Co., Ltd | 1,408 | រាម ព្រះសីហនុ | រួចរាល់ | ដាក់ជូនក្រសួងបរិស្ថានដើម្បីពិនិត្យ |
| 8 | ក្រុមហ៊ុន SINOMEXIM Investment Co., Ltd | 4,280 | បទុមសាគរ កោះកុង | រួចរាល់ | កំពុងបន្ត |
| 9 | ក្រុមហ៊ុន UNION DEVELOPMENT GROUP CO., LTD | 36,000 | បទុមសាគរ កោះកុង | រួចរាល់ | CDC អនុម័ត |
| 10 | ក្រុមហ៊ុន Yeejia Development Company Ltd | 3,300 | រាម, ព្រះសីហនុ | រួចរាល់ | CDCកំពុងពិនិត្យ |
| 11 | ក្រុមហ៊ុន Sokha Hotel | 18,987 | បូកគោ កំពត-សីហនុ | រួចរាល់ | CDC អនុម័ត |
| 12 | ក្រុមហ៊ុន Yun Khean Mineral (Cambodia) | 290 | បូកគោ (សីហនុ) | រួចរាល់ | មិនទាន់ |

| លរ | ក្រុមហ៊ុនវិនិយោគ | ទំហំផ្ទៃដី (ហ.ត) | ទីតាំង | ស្ថានភាពកិច្ចព្រមព្រៀង | ស្ថានភាពផែនការមេ |
|---|---|---|---|---|---|
| 13 | ក្រុមហ៊ុន MDS Thmor Dar (Special Economic | 2,265 | សំកុស ពោធិសាត់ | មិនទាន់ | មិនទាន់ |
| 14 | ក្រុមហ៊ុន Cam-Ag Import | 4,350 | គូលែនភ្នំទេព ឧត្តរមានជ័យ | មិនទាន់ | កំពុងបន្ត |
| 15 | ក្រុមហ៊ុន Heng Huot Import Export and Transport | 4.78 | គីរីរម្យ កំពង់ស្ពឺ | ចុះកិច្ចព្រមព្រៀងបរិស្ថាន | កំពុងបន្ត |
| សរុបផ្ទៃដីសម្បទានក្រោមក្រសួងបរិស្ថាន | | **89,252.78** | | | |

ប្រភព: របាយការណ៍វឌ្ឍនភាពក្រសួងបរិស្ថាន(២២ ធ្នូ ២០១៦)

### ៦.៥ និរាសករណ៍សម្បទានដីសេដ្ឋកិច្ចក្រោមដែនសមត្ថកិច្ចក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ផ្អែកលើការពិភាក្សាជាមួយមន្ត្រីរាជរដ្ឋាភិបាលនិងសម្ភាសអ្នកផ្តល់ព័ត៌មានសំខាន់របស់រាជរដ្ឋាភិបាលលើហេតុផលដែលនាំឱ្យនិរាសករណ៍សម្បទានដីសេដ្ឋកិច្ច គឺដោយសារតែក្រុមហ៊ុនទាំងនោះមិនគោរពច្បាប់របស់ប្រទេសកម្ពុជាចូលរួមចំណែកកាប់ឈើខុសច្បាប់ មិនអនុវត្តតាមកិច្ចព្រមព្រៀងនិងផែនការមេ ទំនាស់ដីធ្លី មិនមានឆន្ទៈក្នុងការអភិវឌ្ឍដីមិនមានដីជាតិ ប្រគល់ដីជូនរដ្ឋ ជាដើម ។ល។ ខាងក្រោមនេះគឺជាបញ្ជីនៃសម្បទានដីសេដ្ឋកិច្ចដែលបាននិរាសករណ៍ដោយទីស្តីការគណៈរដ្ឋមន្ត្រី។

**តារាង៦.៥ បច្ចុប្បន្នភាពបញ្ជីសម្បទានដីសេដ្ឋកិច្ចនិរាសករណ៍ក្រោមដែនសមត្ថកិច្ចក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

| លរ | ឈ្មោះសម្បទានដីដែលបាននិរាសករណ៍ | ទំហំដី (ហត) | ទីតាំងដីសម្បទាន | | | ឯកសារច្បាប់ |
|---|---|---|---|---|---|---|
| | | | ឃុំ | ស្រុក | ខេត្ត | |
| 1. | ក្រុមហ៊ុន IPD instant protrading Co., Ltd. | 987 | ក្បាលដំរី | សំបូរ | ក្រចេះ | អនុក្រឹត្យ ៦៧៤, ១៨ ឧសភា ២០០៨ |
| 2. | ក្រុមហ៊ុន ស៊ី អាយ វី អភិវឌ្ឍន៍កសិ ឧស្សាហកម្ម | 769 | ២ធ្នូ | ស្នួល | ក្រចេះ | អនុក្រឹត្យ ១៧១០, ៣០ វិច្ឆិកា ២០០៧ |

| លរ | ឈ្មោះសម្បទានដីដែលបាននិរាសករណ៍ | ទំហំដី (ហត) | ទីតាំងដីសម្បទាន | | | ឯកសារច្បាប់ |
|---|---|---|---|---|---|---|
| | | | ឃុំ | ស្រុក | ខេត្ត | |
| 3. | ក្រុមហ៊ុន Harmony Plantation Co.,Ltd | 623 | ចង្រ្កង | ចិត្របូរី | ក្រចេះ | លិខិត កសក, ២៧២១/ ២៧៧ កសក. ៣០ ឧសភា ២០០៨ |
| 4. | ក្រុមហ៊ុន Huot Sambath Co., Ltd | 6432 | ២ ធ្នូ | ស្នួល | ក្រចេះ | អនុក្រឹត្យ# ៤៦១, ១៨ មីនា ២០០៩, អនុក្រឹត្យ# ១២៨, ១៣ សីហា ២០០៩, អនុក្រឹត្យ # ១៨៨ , ៣០ តុលា ២០០៩ |
| 5. | ក្រុមហ៊ុន សុខ ហេង | 7172 | | ស្រុកសេសាន | ស្ទឹងត្រែង | អនុក្រឹត្យ # ៤៣២, ២០ មេសា ២០១០ សជណ ៣៥, ០៩ មករា ២០១៥ |
| 6. | ក្រុមហ៊ុន UN INTER TRADING AND DEVELOPMENT GROUP | 7000 | ក្បាលរមាស | សេសាន | ស្ទឹងត្រែង | អនុក្រឹត្យ # ៩០០, ២២ មិថុនា ២០០៩ |

| លរ | ឈ្មោះសម្បទានដីដែលបាននិរាសករណ៍ | ទំហំដី (ហត) | ទីតាំងដីសម្បទាន | | | ឯកសារច្បាប់ |
|---|---|---|---|---|---|---|
| | | | ឃុំ | ស្រុក | ខេត្ត | |
| | | | | | | សជណ# ៣៥, ០៩ មករា ១៥ |
| 7. | ក្រុមហ៊ុន Can and Sugar Welly Co.,Ltd | 6594 | | សំរោង & ចុងកាល់ | ឧត្តរមានជ័យ | អនុក្រឹត្យ# ១៤៧៥, 0៥ តុលា ២០០៧ , អនុក្រឹត្យ# ៨៤,២១ មករា ២០០៨ |
| 8. | ក្រុមហ៊ុន ទន្លេស៊ូហ្គើរ | 6618 | | សំរោង & ចុងកាល់ | ឧត្តរមានជ័យ | អនុក្រឹត្យ# ១៤៧៥, 0៥ តុលា ២០០៧ , អនុក្រឹត្យ# ៨៤,២១ មករា ២០០៨ |
| 9. | ក្រុមហ៊ុន Angkor Sugar Co.,Ltd | 6523 | | សំរោង & ចុងកាល់ | ឧត្តរមានជ័យ | អនុក្រឹត្យ# ១៤៧៥, 0៥ តុលា ២០០៧ , អនុក្រឹត្យ# ៨៤,២១ មករា ២០០៨ |
| 10. | ក្រុមហ៊ុន ហេងហ៊ាប វិនិយោគ | 7000 | | អូយ៉ាដាវ | រតនៈគីរី | អនុក្រឹត្យ# ១១៤៦, ២៥ កក្កដា ២០០៦; |

| លរ | ឈ្មោះសម្បទានដីដែលបាននិរាសករណ៍ | ទំហំដី (ហត) | ទីតាំងដីសម្បទាន | | | ឯកសារច្បាប់ |
|---|---|---|---|---|---|---|
| | | | ឃុំ | ស្រុក | ខេត្ត | |
| | | | | | | អនុក្រឹត្យ# ១៩៤, ២១ កុម្ភៈ ២០១២ |
| 11. | ក្រុមហ៊ុន RESEARCH MINING DEVELOPMENT | 7,200 | ក្បាលរមាស | សេសាន | ស្ទឹងត្រែង | អនុក្រឹត្យ # ៨៩៩, ២៧ មិថុនា ២០០៨ សជណ ៣៥, ០៩ មករា ២០១៥ |
| សរុបទំហំផ្ទៃដីសម្បទាន | | ៦៤១១៨ | | | | |

ប្រភព:ក្រុមអ្នកសិក្សាស្រាវជ្រាវពិនិត្យដោយផ្អែកលើសេចក្តីជូនដំណឹងរបស់ទីស្តីការគណៈរដ្ឋមន្ត្រី ២០១៥

### ៦.៦ បច្ចុប្បន្នភាពនៃការចុះពិនិត្យឆ្នាំ២០១៦

អនុលោមតាមអនុសាសន៍របស់ឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៦ នៅចុងឆ្នាំ ២០១៦ ក្រុមការងារបច្ចេកទេសវាយតម្លៃសម្បទានដីសេដ្ឋកិច្ចនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទគួរតែចុះត្រួតពិនិត្យប្រចាំឆ្នាំ(២០១៥-២០១៦) ក្នុងខេត្តចំនួន១៨។ មានក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចសរុប២២៩ត្រូវបានត្រួតពិនិត្យវាស់វែង និងវាយតម្លៃឡើងវិញចំពោះការអនុវត្តរបស់ក្រុមហ៊ុនដោយផ្អែកលើកិច្ចព្រមព្រៀងនិងផែនការមេ។ គោលបំណងនៃការត្រួតពិនិត្យគឺដើម្បីឆ្លុះបញ្ចាំងនូវស្ថានភាពនៃការអនុវត្តផែនការមេរបស់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ដំណើរការចុះបញ្ជីដីរដ្ឋ ការអនុវត្តច្បាប់ ជម្លោះដីធ្លី វឌ្ឍនភាពដែលបានអនុវត្តដោយប្រៀបធៀបទិន្នន័យគោលឆ្នាំ២០១៤ បញ្ហាប្រឈម និងសំណូមពរ[18]។

ផ្អែកលើការសម្ភាសន៍ជាមួយមន្ត្រីរដ្ឋាភិបាលដែលបានចូលរួមក្នុងដំណើរការវាយតម្លៃសម្បទានដីសេដ្ឋកិច្ច ពួកគាត់បានលើកឡើងថា ដំណើការអនុវត្តច្បាប់ដោយក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចស្ថិតនៅក្រោមក្រសួងបរិស្ថាន ខុសគ្នាពីការអនុវត្តដោយក្រុមហ៊ុនដែលស្ថិតនៅក្រោមក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ជាឧទាហរណ៍ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទតម្រូវឱ្យក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចទាំងអស់ដាក់លិខិតស្នើសុំការឈូសឆាយដី និងព្រៃជាមុនទៅក្រសួងកសិកម្ម។ បន្ទាប់មក ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទត្រូវពិនិត្យមើលផែនការមេ របាយការណ៍វឌ្ឍនភាព ក្របខណ្ឌច្បាប់ និងកិច្ចព្រមព្រៀងមុនពេលចេញលិខិតអនុញ្ញាតជាផ្លូវការទៅក្រុមហ៊ុនសម្បទាន។

[18] លទ្ធផលនៃការសម្ភាសសមាជិកក្រុមការងារវាយតម្លៃសម្បទានដីសេដ្ឋកិច្ច ២០-៣០ ធ្នូ ២០១៦ ខេត្តព្រះវិហារ

ទោះជាយ៉ាងនេះក្តី ក្រុមហ៊ុនសម្បទានមួយចំនួនដែលស្ថិតនៅក្រោមសមត្ថកិច្ចក្រសួងបរិស្ថាន ពិសេសក្រុមហ៊ុនវិនិយោគដោយជនបរទេសបានលើកឡើងថាពួកគេអនុវត្តតាមផែនការមេ និងកិច្ចព្រមព្រៀង ដូច្នេះពួកគេឈូសឆាយដី និងព្រៃក្នុងព្រំដីរបស់គេ រួចហើយដាក់លិខិតស្នើទៅក្រសួងបរិស្ថានតាមក្រោយដើម្បីសុំការឯកភាព។ ទោះជាយ៉ាងនេះក្តី ក្រុមហ៊ុនក្រោមក្រសួងបរិស្ថានមួយចំនួនក៏អនុវត្តតាមនីតិវិធីដែលក្រសួងកសិកម្មអនុវត្តដែរ។

## ៧.លទ្ធផលសំខាន់ៗ

ការសិក្សានៅទីវាលបានអនុវត្តនៅចន្លោះខែមករា ដល់ខែមេសា ឆ្នាំ២០១៧ ដើម្បីពិនិត្យមើលស្ថានភាពនៃករណីសិក្សាលើសម្បទានដីសេដ្ឋកិច្ចនៅក្នុងខេត្តចំនួនបួន។ សហគមន៍រងផលប៉ះពាល់ពីគម្រោងដីសម្បទានចំនួន១០៣នាក់ត្រូវបានសម្ភាសន៍ និងពិភាក្សាលើការអនុវត្តសម្បទានដីសេដ្ឋកិច្ច ការគ្រប់គ្រងព្រៃឈើ សិទ្ធិដីធ្លី ទំនាស់ដីធ្លី និងទស្សនៈរបស់ពួកគាត់លើការនិរាសករណ៍សម្បទានដីសេដ្ឋកិច្ច។ យ៉ាងហោចណាស់មន្ត្រីរដ្ឋាភិបាលចំនួន៤៥នាក់ ដែលរួមបញ្ចូលទាំងអាជ្ញាធរដែនដី និងមេដឹកនាំសហគមន៍បានពិគ្រោះយោបល់ និងពិភាក្សាលើតួនាទី និងការទទួលខុសត្រូវរបស់ពួកគាត់លើការគ្រប់គ្រងសម្បទានដីសេដ្ឋកិច្ចនៅក្រោមដែនសមត្ថកិច្ចរបស់ពួកគាត់ ជាពិសេសយន្តការដោះស្រាយលើជម្លោះដីធ្លី។ យ៉ាងហោចណាស់ករណីសិក្សាចំនួន០៤លើស្ថានភាពនៃការនិរាសករណ៍សម្បទានដីសេដ្ឋកិច្ចត្រូវបានរៀបចំឡើងដើម្បីគាំទ្រលើលទ្ធផលនៃការសិក្សានេះ។ ការវិភាគស្ថិតិបានផ្តោតសំខាន់លើព័ត៌មានគុណភាព និងទិន្នន័យពីការងារទីវាល។

### ៧.១ ស្ថានភាពនៃការប្រើប្រាស់ដី និងទីតាំងដីដែលបានកាត់បន្ថយទំហំផ្ទៃដីនិងរាសករណ៍ពីសម្បទានដីសេដ្ឋកិច្ច

### ៧.១.១ ស្ថានភាពនៃសម្បទានដីសេដ្ឋកិច្ចនៅក្នុងខេត្តរតនៈគីរី

ដី និងជីវភាពរស់នៅរបស់ជនជាតិដើមភាគតិចនៅក្នុងខេត្តរតនៈគីរីបានទទួលរងនូវសម្ពាធពីការវិនិយោគកសិពាណិជ្ជកម្មរបស់ក្រុមហ៊ុនបរទេស កសិ-ឧស្សាហកម្ម សម្បទានដីសេដ្ឋកិច្ច និងការកាប់ឈើខុសច្បាប់។ ខេត្តរតនៈគីរីគឺជាខេត្តដែលសំបូរដោយដីកំអែភ្នំភ្លើងព័ណ៌ក្រហម ស្ទឹងទន្លេ ព្រៃឈើដ៏សំបូរបែប និងមានប្រជាពលរដ្ឋរស់នៅតិចតួចបានក្លាយទៅជាដែនដីថ្មីសម្រាប់គម្រោងសំណើដាំដុះកសិ-ឧស្សាហកម្ម រ៉ែអគ្គិសនីនិងសម្បទានដីសេដ្ឋកិច្ច។ ខេត្តរតនៈគីរីគ្របដណ្តប់ដោយផ្ទៃដី១,១៦លានហិកតាដែលបានបែងចែកជាតំបន់ក្សេត្របរិស្ថានចំនួនបួនសំខាន់ៗ រួមមានតំបន់ខ្ពង់រាបកណ្តាល តំបន់ខ្ពង់រាប តំបន់ភ្នំ និងតំបន់ទំនាប។ ដោយយោងលើការសម្ភាសជាមួយសហគមន៍ជនជាតិដើមដែលរងផលប៉ះពាល់ពីគម្រោងសម្បទាននៅឃុំ យ៉ាទុង ស្រុកអូយ៉ាដាវ បានអះអាងថា ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចមិនខ្វល់នឹងជីវភាពរស់នៅរបស់ពួកគាត់និងមិនគោរពប្រពៃណីជនជាតិដើមនោះទេ។ សហគមន៍ដែលរងផលប៉ះពាល់បានលើកឡើងថាក្រុមហ៊ុនបានឈូសឆាយគ្មានសល់អ្វី សូម្បីតែអាហាររបស់ពួកគាត់ ហើយពុំបានពិគ្រោះយោបល់ជាមួយពួកគាត់នោះទេ ខណៈដែលស្បៀងអាហារប្រចាំថ្ងៃរបស់គាត់ពឹងផ្អែកទាំងស្រុងលើព្រៃធម្មជាតិ។ សហគមន៍គាត់មានការសោកស្តាយបំផុតដែលព្រៃស្រោងត្រូវបានបាត់បង់ទាំងស្រុងដោយសារក្រុមហ៊ុនវិនិយោគ។ ពួកគាត់ក៏បានលើកឡើងថាក្រុមហ៊ុនមិនចង់វិនិយោគលើដីសម្បទានរបស់គេនោះទេតែពួកគេចង់កាប់ឈើយកទៅវៀតណាមប៉ុណ្ណោះ ។ តំបន់សម្បទានដីសេដ្ឋកិច្ចមានទីតាំងស្ថិតនៅក្នុងតំបន់ព្រៃឈើដែលជាទីកន្លែងសម្រាប់ការរកស្បៀងអាហាររបស់សហគមន៍ជនជាតិដើមភាគតិច។ ជាទម្លាប់និងប្រពៃណី ពួកគាត់តែងតែចូលទៅក្នុងព្រៃដើម្បីប្រមូលផល អនុផលព្រៃឈើ ការធ្វើកសិកម្មពនេចរ ការធ្វើស្រូវចំការ និងការធ្វើពិធីបុណ្យដើម្បីសែនអារក្ស អ្នកតាជាដើម។ ដោយសារតែមានការកើនឡើងនៃការកាប់ឈើខុសច្បាប់ សហគមន៍ចារ៉ាយបានកៀរគរប្រជាពលរដ្ឋដើម្បីបង្កើតសហគមន៍ព្រៃឈើដោយមានការគាំទ្រពីអង្គការសង្គមស៊ីវិលក្នុងស្រុកមួយ។ សហគមន៍នេះបានទទួលស្គាល់ដោយអាជ្ញាធរមូលដ្ឋានឃុំផងដែរ។ ដោយសារតែមានការស្មុគស្មាញលើនីតិវិធីច្បាប់ សហគមន៍មិនបានចុះបញ្ជីសហគមន៍ព្រៃឈើនេះជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនោះទេ។ តែទោះជាយ៉ាងនេះក្តី សហគមន៍នៅតែបន្តសកម្មភាពការពារព្រៃយ៉ាងសកម្មប្រឆាំងនឹងបទល្មើសព្រៃឈើ។


រូបថត៧.១: ការប្រជុំពិគ្រោះយោបល់ជាមួយសហគមន៍ដែលរងផលប៉ះពាល់ និងអាជ្ញាធរមូលដ្ឋាននៅស្រុក អូយ៉ាដាវ ខេត្តរតនៈគីរី

អនុលោមតាមការប្រជុំពិគ្រោះយោបល់ជាមួយប្រជាជនមូលដ្ឋាន អាជ្ញាធរមូលដ្ឋាន និងមន្ទីរជំនាញនានារបស់ខេត្តបង្ហាញថា ៧៤%នៃអ្នកបានឆ្លើយនឹងសំណួរបានទទួលព័ត៌មានអំពីការវិនិយោគសម្បទានដីសេដ្ឋកិច្ចនៅក្នុងស្រុកអូយ៉ាដាវ។ ទោះបីជាយ៉ាងនេះក្តី ភាគច្រើននៃសហគមន៍ដែលរងផលប៉ះពាល់ពីគម្រោង ពិសេសជនជាតិដើមភាគតិចចារ៉ាយមិនបានទទួលព័ត៌មានអំពីទំហំដីដែលបានផ្តល់សម្បទាន គោលបំណងវិនិយោគ គោលការណ៍សំណង ព្រំប្រទល់សម្បទានដីសេដ្ឋកិច្ច និងផលប៉ះពាល់ដ៏មានសក្តានុពលដល់ជីវភាពរស់នៅរបស់ពួកគេ។ លើសពីនេះទៅទៀត សហគមន៍ អាជ្ញាធរមូលដ្ឋាន(កម្រិតឃុំ)មិនដែលបានចូលរួមនៅក្នុងដំណើរការផ្តល់សម្បទានដីសេដ្ឋកិច្ចនេះទេ។ មន្ត្រីរដ្ឋាភិបាលថ្នាក់ជាតិមួយចំនួនក៏បានត្អូញត្អែថា ក្រុមហ៊ុនមិនសហការល្អជាមួយពួកគាត់ដើម្បីផ្តល់ព័ត៌មានលម្អិតរបស់ក្រុមហ៊ុន ដូចជាដីព្រៃដែលបានឈូសឆាយ វឌ្ឍនភាពនៃការដាំដុះ របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ទំនាស់ដីធ្លី សារពើភ័ណ្ឌឈើ ការបង់ពន្ធ ជាដើម។ យោងតាមការអះអាងរបស់សហគមន៍ដែលរងផលប៉ះពាល់ពីគម្រោងរស់នៅជុំវិញក្រុមហ៊ុន ហេង ហ៊ាប បញ្ជាក់ថា មានការកាប់ឈើខុសច្បាប់ពីក្នុងតំបន់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចដឹកទៅកាន់ប្រទេសវៀតណាមនៅពេលយប់។

នៅក្នុងមាត្រា០៤នៃអនុក្រឹត្យលេខ១៤៦ ស្តីពីសម្បទានដីសេដ្ឋកិច្ចតម្រូវឱ្យសម្បទានិកទាំងអស់គោរពតាម

គោលការណ៍ប្រាំចំណុចរួមមាន ការធ្វើអនុប្បយោគ និងចំណាត់ថ្នាក់ដីជាដីឯកជនរបស់រដ្ឋ ផែនការប្រើប្រាស់ដីធ្លី ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គម ដីដែលបានដោះស្រាយបញ្ហាការតាំងទីលំនៅថ្មី ស្ថាប័នមានសត្ថកិច្ចចុះព្រមព្រៀងត្រូវធានាថានឹងមិនមានការតាំងទីលំនៅថ្មីដោយបង្ខិតបង្ខំ ការពិគ្រោះយោបល់ជាសាធារណៈ ជាមួយអាជ្ញាធរមូលដ្ឋាន និងប្រជាជនមូលដ្ឋាន។ ទោះបីជាយ៉ាងនេះក្តី ក្រុមហ៊ុនមិនបានអនុវត្តតាមក្របខណ្ឌច្បាប់ និងតម្រូវការនៃមាត្រា០៤ និងមាត្រា០៥នៃអនុក្រឹត្យលេខ១៤៦នោះទេ។ លើសពីនេះទៅទៀត ក្រុមហ៊ុន ហេង ហ៊ាប បានទទួលសម្បទានដី សេដ្ឋកិច្ចនៅក្នុងតំបន់ប្រាសាទតាណាងដែលមានទីតាំងស្ថិតនៅក្នុងតំបន់ជនជាតិដើមភាគតិចចារ៉ាយ(ករណីសិក្សាទី១) ខណៈដែលច្បាប់ស្តីពីការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថានមិនអញ្ញាតឱ្យធ្វើបែបនេះ។




ក្រាហ្វិច៧.១.១ ទស្សនៈរបស់សហគមន៍ដែលរងផលប៉ះពាល់ចំពោះអត្ថប្រយោជន៍ទទួលបានពីការនិរាសករណ៍សម្បទានដីសេដ្ឋកិច្ចនៅខេត្តរតនៈគីរី

យោងតាមការសម្ភាសជាមួយសហគមន៍ដែលរងផលប៉ះពាល់ពីគម្រោងសម្បទានបង្ហាញថា ការនិរាករណ៍សម្បទានដីសេដ្ឋកិច្ចបានផ្តល់ឱកាសឱ្យពួកគាត់អាចទៅរកផលអនុផលព្រៃឈើដែលនៅសល់នៅក្នុងតំបន់ព្រៃឈើដែលនៅសល់ពីការឈូសឆាយរបស់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច(២៧%) ខណៈដែលសហគមន៍ផ្សេងៗទៀត (១៧,៦%) សង្ឃឹមថារដ្ឋាភិបាលនឹងផ្តល់តំបន់ដីសម្បទានសេដ្ឋកិច្ចដែលបាននិរាសករណ៍នេះទៅសហគមន៍ ពិសេស គ្រួសារក្រីក្រ

ដែលមិនដីប្រើប្រាស់។ ១៦,២%នៃអ្នកបានឆ្លើយតបកត់សម្គាល់ថា តាំងពីនិរាសករណ៍សម្បទានដីសេដ្ឋកិច្ចតាំងពីឆ្នាំ ២០១៥មក សហគមន៍ដែលរងផលប៉ះពាល់ហើយធ្លាប់ចូលរួមនៅក្នុងយុទ្ធនាការស្វែងរកការដោះស្រាយទំនាស់ដីធ្លីប្រឆាំងនឹងក្រុមហ៊ុនសម្បទានកន្លងមក មានពេលគ្រប់គ្រាន់របស់គាត់ដើម្បីដាំដុះដំណាំកសិ ឧស្សាហកម្ម និងដំណាំប្រពៃណីរបស់គាត់ដូចជា ស្វាយចន្ទី ដំឡូង ស្វាយ ការប្រមូលទឹកឃ្មុំ កសិកម្មពនេចរ និងសកម្មភាពនានាសម្រាប់ជីវភាពរស់នៅ និងបង្កើនប្រាក់ចំណូលរបស់ពួកគាត់។ ដោយសារតែមានការបាត់បង់ព្រៃឈើ និងជីវៈចម្រុះ ១៤,៩%នៃអ្នកឆ្លើយតបបានបញ្ជាក់ថាតំបន់សម្បទានដីសេដ្ឋកិច្ចដែលបាននិរាករណ៍គួរតែរក្សាទុកសម្រាប់ការស្តារព្រៃ ឡើងវិញក្នុងគោលដៅរក្សាការពារជីវៈចម្រុះ និងបង្កើនគម្របព្រៃឈើ។ អ្នកឆ្លើយតប ១២,២% បានរំពឹងថាពួកគាត់នឹង ទទួលបានបណ្ណកម្មសិទ្ធិដីធ្លីពីរដ្ឋាភិបាលតាមរយៈយន្តការសមស្របដែលមានស្រាប់របស់រាជរដ្ឋាភិបាលដើម្បីដោះស្រាយរាល់ទំនាស់ដីធ្លី។ ទោះជាយ៉ាងនេះក៏ដោយ៥,៤%នៃអ្នកដែលបានឆ្លើយតបបានត្អូញត្អែថានិរាសករណ៍សម្បទានដីសេដ្ឋកិច្ចមិនបានផ្តល់ប្រយោជន៍អ្វីទាំងអស់ដល់សហគមន៍ ពីព្រោះក្រុមហ៊ុនបានឈូសឆាយគ្មានសល់អ្វីទាំងអស់រួមទាំងប្រភពចំណីអាហាររបស់ពួកគាត់។ ពួកគាត់បានបន្ថែមថា ជីវភាពរបស់សហគមន៍ជនជាតិដើមភាគតិច រំពឹងទាំងស្រុងលើព្រៃឈើធម្មជាតិ និងជីវៈចម្រុះសម្រាប់រកប្រាក់ចំណូល និងអាហារប្រចាំថ្ងៃ ប៉ុន្តែក្រុមហ៊ុនបានបំផ្លាញ អស់គ្មានសល់ ដោយគ្មានសំណង។

## ករណីសិក្សាទី១
## ក្រុមហ៊ុន ហេង ហ៊ាប វិនិយោគ

*សហគមន៍ជនជាតិដើមភាគតិចចារ៉ាយ "អាហារ និងជីវិតរបស់ពួកយើងពឹងផ្អែកទាំងស្រុងលើព្រៃឈើធម្មជាតិ"*

### សាវតា

ខេត្តរតនៈគីរីស្ថិតនៅតំបន់ភាគខាងជើងឈាងខាងកើតនៃប្រទេសកម្ពុជាដែលគ្របដណ្តប់លើផ្ទៃក្រឡាដីទំហំ ១០.៧៨២ គីឡូម៉ែត្រការ៉េ និងមានចំងាយពីក្រុងភ្នំពេញប្រវែង៥៨៨គីឡូម៉ែត្រ តាមផ្លូវជាតិលេខ៦A លេខ៧ និងលេខ៧៨។ មានទន្លេពីរសំខាន់គឺទន្លេសេសាន និងទន្លេស្រែពក ដែលហូរកាត់ខេត្តនេះ។ ខេត្តនេះបានបែងចែកជាក្រុង០១ និងស្រុកចំនួន០៨នៃតបន់ចំនួន០៤ មានឃុំចំនួន៤៦ និង២៤៣ភូមិ។ ក្រុងនៃខេត្តរតនៈគីរីគឺក្រុងបានឡុង។ ខេត្តនេះគឺជាខេត្តក្រីក្រមួយនៅក្នុងប្រទេសកម្ពុជា។ ទីតាំងនេះជាតំបន់ខ្ពង់រាបដ៏ល្អឥតខ្ចោះដែលមានព្រៃឈើដុះយ៉ាងក្រាស និងមានសីតុណ្ហភាពត្រជាក់។ ខេត្តនេះសំបូរដោយដីដែលមានដីជាតិព័ណ៌ក្រហមដែលមានសក្តានុពលសម្រាប់ដំណាំសេដ្ឋកិច្ច។ ខេត្តនេះគឺជាប្រភពវប្បធម៌ និងធនធានធម្មជាតិដែលផ្តល់ឱកាសដ៏សំបើមសម្រាប់ការអភិវឌ្ឍវិស័យទេសចរណ៍។ ខេត្តនេះមានជនជាតិភាគតិចដើមប្រមាណ៧៥% ដែលបែងចែកជា០៨ក្រុមជនជាតិភាគតិចរួមមានទំពួន គ្រឹង ចារ៉ាយ ភ្នៅ ព្នង កាវ៉ែត កាចក់ និងលន់។ ភាគច្រើនបំផុតនៃជីវភាពរស់ជនជាតិដើមភាគតិចពឹងផ្អែកលើអនុផលព្រៃឈើ។ ខេត្តនេះមានព្រំប្រទល់ជាប់នឹងប្រទេសវៀតណាម ដែលភ្ជាបតាមរយៈច្រកព្រំដែនអន្តរជាតិអូយ៉ាដាវដែលផ្តល់ឱកាសល្អបំផុតសម្រាប់ការធ្វើពាណិជ្ជកម្ម និងនិយោគ។

ការអភិវឌ្ឍដំណាំកសិ ឧស្សាហកម្ម ដូចជា កៅស៊ូ ដំឡូងមី ស្វាយចន្ទី ពោធ សណ្តែក ។ល។ បានរីកដុះដាលយ៉ាងឆាប់រហ័សដោយសារតែមានតម្លៃទីផ្សារខ្ពស់ទាំងនៅក្នុងស្រុក និងអន្តរជាតិ។ យោងតាមទិន្នន័យរបស់ខេត្តរតនៈគីរីមានក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចចំនួន២៨(ទំហំដីសរុប១៧៣.៦៦៨ហិកតា) បានវិនិយោគលើការដាំដុះដំណាំ

កៅស៊ូ ទេសចរណ៍ និងកន្លែងកំសាន្តនៅក្នុងស្រុកចំនួន១១ស្រុកនៃខេត្តរតនៈគីរី។ ពីរបីឆ្នាំកន្លងទៅ ខេត្តរតនៈគីរីធ្លាប់មានបទពិសោធន៍លើការកើនឡើងយ៉ាងឆាប់រហ័សបំផុតលើការអភិវឌ្ឍដោយប្រែក្លាយដីព្រៃធម្មជាតិទៅជាដីកសិកម្ម។ បន្ទាប់ពីនិរាសករណ៍សម្បទានដីសេដ្ឋកិច្ច នៅសល់តែ២៦ក្រុមហ៊ុនសម្បទានប៉ុណ្ណោះ (១៦ក្រុមហ៊ុនក្រោមក្រសួងកសិកម្ម និង១០នៅក្រោមក្រសួងបរិស្ថាន) កំពុងប្រតិបត្តការនៅក្នុងខេត្តរតនៈគីរី[19]។

**ក្របខណ្ឌច្បាប់របស់ក្រុមហ៊ុន ហេង ហ៊ាប**

ក្រុមហ៊ុន ហេង ហ៊ាប គឺជាក្រុមហ៊ុនមួយក្នុងចំណោមក្រុមហ៊ុន៣២ផ្សេងទៀតដែលត្រូវបាននិរាករណ៍ដែលមានទីតាំងស្ថិតនៅក្នុងឃុំយ៉ាទុង ស្រុកអូយ៉ាដាវ ខេត្តរតនៈគីរី។ ក្រុមហ៊ុន ហេង ហ៊ាប ជាក្រុមហ៊ុនឧបសម្ព័ន្ធរបស់ក្រុមហ៊ុន ម៉ែន សារុន។ ក្រុមហ៊ុននេះទទួលបានសិទ្ធវិនិយោគពីរដ្ឋាភិបាលសម្រាប់ដាំដុះដំណាំកសិ ឧស្សាហកម្ម តាមរយៈ ស.ជ.ណា លេខ១១៤៦ ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០០៦ និងសជណលេខ១៩៤ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១២ របស់ទីស្តីការគណៈរដ្ឋមន្ត្រី[20]។ យោងលើសិទ្ធិប្រទានពីរាជរដ្ឋាភិបាលជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ លេខ ១២៨ ថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៦ ក្រុមហ៊ុន ហេង ហ៊ាប បានចុះកិច្ចព្រមព្រៀង ជាមួយក្រសួងកសិកម្ម នៅថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៩ និងទទួលបានការអនុម័តលើផែនការមេនៅថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១២ លើផ្ទៃដីវិនិយោគដែលបានកាត់បន្ថយទំហំចំនួន ៥៦៦៧ហិកតា។

យោងតាមរបាយការណ៍វាយតម្លៃរបស់ក្រុមការងារក្រសួងកសិកម្ម បង្ហាញថាក្រុមហ៊ុនមិនបានបំពេញតាមលក្ខណ្ឌមួយចំនួនដែលបានកំណត់ដោយច្បាប់ ដូចជា គ្មានរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន មិនបានធ្វើអនុបយោគដីទៅជាដីឯកជនរបស់រដ្ឋ ការចុះបញ្ជីដីរដ្ឋ មិនបានពិគ្រោះយោបល់ជាមួយពលរដ្ឋដែលរងផលប៉ះពាល់ឱ្យបានសមស្រប ពិសេសជនជាតិដើមភាគតិចដែលកំពុងរស់នៅក្នុងតំបន់នោះ។ អនុលោមតាម សជណ លេខ៦២៦ ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៥ រាជរដ្ឋាភិបាលកម្ពុជាសម្រេចនិរាសករណ៍ក្រុមហ៊ុន ហេង ហ៊ាប និងបានផ្ទេរដីសម្បទាននេះទៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអាជ្ញាធរខេត្តរតនៈគីរីដើម្បីគ្រប់គ្រង។

**ការអនុវត្តន៍របស់ក្រុមហ៊ុនធៀបជាមួយកិច្ចព្រមព្រៀង និងផែនការមេ**

របាយការណ៍វាយតម្លៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានបញ្ជាក់ថា ក្រុមហ៊ុនបានពន្យាពេលអនុវត្តផែនការមេបន្ទាប់ពីឈូសឆាយព្រៃរួចរាល់។ មុនពេលផ្តល់សម្បទានដីសេដ្ឋកិច្ច តំបន់នេះគ្របដណ្តប់ដោយព្រៃស្រោង និងព្រៃពាក់កណ្តាលស្រោង ដែលជាកន្លែងសម្រាប់ទ្រទ្រង់ជីវភាពរស់នៅរបស់សហគមន៍។ មន្ត្រីរដ្ឋាភិបាល និងសហគមន៍បានត្អូញត្អែថា ក្រុមហ៊ុនមិនបានគោរពតាមច្បាប់ ហើយបានចូលរួមចំណែកដល់ការប្រព្រឹត្តបទល្មើសព្រៃឈើ រំលោភសិទ្ធមនុស្ស បង្កើតឱ្យមានជម្លោះដីធ្លីជាមួយសហគមន៍ជនជាតិដើមភាគតិច។

[19] ការសម្ភាសជាមួយអនុប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទថ្ងៃទី០៧ ខែមករា ឆ្នាំ២០១៧

[20] សជណ #៦២៦ ថ្ងៃទី០៨ ខែមថុនា ឆ្នាំ២០១៥




រូបថត ៧.២: ទិដ្ឋភាពក្រុមហ៊ុន ហេង ហ៊ាប វិនិយោគ នៅឃុំយ៉ាទុង ស្រុកអូយ៉ាដាវ ខេត្តរតនៈគីរី

សហគមន៍បានសង្កេតឃើញថា ម្ចាស់ក្រុមហ៊ុនមិនមានឆន្ទៈក្នុងការវិនិយោគនៅលើដីនេះទេ បន្ទាប់ពីឈូសឆាយព្រៃឈើរួចរាល់។ យោងតាមការអង្កេតនៅទីតាំងក្រុមហ៊ុន ក្រុមហ៊ុនដាំដុះដំណាំកៅស៊ូបានតិចតួចនិងដាំជំឡូងមីតាមបណ្តោយស្ទឹង និងផ្ទៃដីដែលនៅសល់យ៉ាងធំល្វឹងល្វើយមិនបានដាំដុះនោះទេ។




រូបភាពថតលើអេក្រង់៧.១ ទីតាំងព្រំប្រទល់ក្រុមហ៊ុន ហេង ហ៊ាប ដែលស្ថិតត្រួតលើទីតាំងព្រំដីឧទ្យានជាតិអូយ៉ាដាវ
ប្រភព៖ *ODC interactive mapping (ELCs, Forest Cover 2009 and National Park)*, ថតថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៧

**ជម្លោះដីធ្លីជាមួយសហគមន៍ជនជាតិដើមភាគតិច**

សហគមន៍ជនជាតិដើមភាគតិចចារ៉ាយមិនបានទទួលដំណឹងអំពីព័ត៌មាននៃការវិនិយោគរបស់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ដោយសារក្រុមហ៊ុនមិនបានពិគ្រោះយោបល់ជាមួយពួកគាត់ជាមុនលើការវិនិយោគនេះ[21]។ សហគមន៍ចារ៉ាយមិនគាំទ្រលើការវិនិយោគ និងមានការខកចិត្តយ៉ាងខ្លាំងនៅពេលដឹងថា ការផ្តល់សម្បទានដីសេដ្ឋកិច្ចនេះក្នុងព្រៃស្រោងដែលជីវភាពសហគមន៍ជនជាតិដើមភាគតិចពឹងផ្អែកទៅលើ។ "*ជីវិតនិងអាហាររបស់ពួកយើងពឹងផ្អែកទាំងស្រុងលើព្រៃធម្មជាតិ ពួកគេបានឈូសឆាយគ្មានសល់អ្វីទាំងអស់ ហើយបានដាំដំណាំកៅស៊ូមកជំនួសវិញ*" ប្រធានសហគមន៍បានលើកឡើង។ គាត់បន្ថែមថា " ខ្ញុំមានអារម្មណ៍សោកស្តាយណាស់ និងបាក់ទឹកចិត្តចំពោះការវិនិយោគរបស់ក្រុមហ៊ុនសម្បទាននៅក្នុងព្រៃស្រោងបែបនេះ. ការវិនិយោគនេះមិនបានផ្តល់ប្រយោជន៍ដល់ជីវភាពរស់នៅរបស់ពួកយើងទេ ប៉ុន្តែក្រុមហ៊ុនបានបំផ្លាញព្រៃឈើធម្មជាតិ និងវប្បធម៌ប្រពៃណីរបស់ពួកយើង"។

ក្រុមសហគមន៍ជនជាតិភាគតិចចារ៉ាយដែលរងផលប៉ះពាល់ពីគម្រោងបានលើកឡើងថា ពួកគាត់មិនបានដឹងព័ត៌មានជាមុនអំពីការវិនិយោគសម្បទានដីសេដ្ឋកិច្ចនៅក្នុងទីតាំងរបស់ពួកគាត់នោះទេ។ ពួកគាត់មានការភ្ញាក់ផ្អើលយ៉ាងខ្លាំងនៅពេលឃើញក្រុមហ៊ុន ហេង ហ៊ាប បានឈូសឆាយព្រៃឈើដ៏ក្រាស់របស់ពួកគាត់ដែលជាទីកន្លែងសម្រាប់រកអាហារ និងជីវភាពប្រចាំថ្ងៃ។ "*ពួកគេមកដល់ហើយឈូសឆាយគ្មានសល់អ្វីទាំងអស់ដោយគ្មានការជូនដំណឹងជាមុន ពួកគេមិនគោរពដល់សិទ្ធិ ប្រពៃណី វប្បធម៌ និងជីវភាពរបស់ពួកយើងនោះទេ*" សំដីរបស់សហគមន៍លើកឡើង។

សហគមន៍ចារ៉ាយបានចង្អុលបង្ហាញថា "មុនពេលវិនិយោគ ទីតាំងនេះគ្របដណ្តប់ដោយព្រៃស្រោង ដែលសហគមន៍ជនជាតិដើមភាគតិចចារ៉ាយស្វែងរកអាហារនៅទីនេះ តាមរយៈការចូលព្រៃដើម្បីស្វែងរកផល អនុផលព្រៃឈើ ការធ្វើកសិកម្មពនេចរ ស្រូវចំការ ប្រកពជីវៈចម្រុះ និងវប្បធម៌ប្រពៃណីជនជាតិចារ៉ាយ។ ក្រុមហ៊ុនបានរក្សាទុកព្រៃសហគមន៍ប្រមាណជា ៥០០ម៉ែត្រ គុណ ១០០០ម៉ែត្រ សម្រាប់សហគមន៍ស្វែងរកអនុផលធនធានធម្មជាតិ។ ទំហំនេះតិចតួចណាស់សម្រាប់តំបន់ព្រៃឈើគឺមិនគ្រប់គ្រាន់ទេសម្រាប់ជនជាតិចារ៉ាយរបស់យើង"។

នៅឆ្នាំ២០១៣ ការសែតឌឹកាំបូឌាដេលី បានចុះផ្សាយថា "ប្រាសាទរតនៈគីរីឥឡូវនេះស្ថិតនៅក្នុងដីសម្បទានសេដ្ឋកិច្ច[22]" បានបញ្ជាក់ថា ប្រាសាទបុរាណរបស់ជនជាតិចារ៉ាយឈ្មោះថា **ប្រាសាទតាណាង**[23] បានកសាងឡើងជាច្រើនសតវត្សមកហើយ ហើយមានទីតាំងស្ថិតនៅក្នុងតំបន់សម្បទានដីសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ហេង ហ៊ាប វិនិយោគ។ ម្ចាស់ក្រុមហ៊ុនក៏បានដឹងថាមានប្រាសាទនេះដែរតាមរយៈព័ត៌មានពីសាលាខេត្ត។ យោងលើច្បាប់ស្តីពីការការពារបេតិកភណ្ឌវប្បធម៌ ឆ្នាំ១៩៩៦ លើកឡើងថា "សកម្មភាពណាមួយ ឬការងារសាងសង់ត្រូវតែបញ្ឈប់នៅទីតាំងបេតិកភណ្ឌរហូតដល់មានការវាស់វែងតំបន់នោះចេញដើម្បីរក្សាទុកការពារ"[24]។

---

[21] សម្ភាសមេសហគមន៍ចារ៉ាយនៅឃុំយ៉ាទុង ស្រុកអូយ៉ាដាវ ថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៧

[22] https://www.cambodiadaily.com/archives/ratanakkiri-temple-now-in-land-concession-47779/

[23] We can view TaK Nang temple by this link: https://goo.gl/maps/g6n5f56hLGC2

[24] Article 37 of law on Protection of Cultural Heritage 1996



រូបថត ៧.២: ប្រាសាទ តាណាង ស្ថិតនៅក្នុងឃុំយ៉ាទុង ស្រុកអូយ៉ាដាវ ខេត្តរតនៈគីរី
ប្រភព: https://www.google.com.kh/maps/

## វិធីសាស្ត្រតស៊ូមតិរបស់សហគមន៍

យ៉ាងហោចណាស់សហគមន៍បានប្រមូលផ្តុំគ្នាចំនួនបីដង ដើម្បីធ្វើបាតុកម្មប្រឆាំងនឹងក្រុមហ៊ុនដើម្បីការពារ និងតស៊ូមតិលើបញ្ហាដីធ្លីរបស់គាត់ និងការបាត់បង់ព្រៃឈើ។ សហគមន៍ចារ៉ាយបានព្យាយាមស្វែងរកវិធីសាស្ត្រផ្សេងៗ ដើម្បីដោះស្រាយបញ្ហាទាំងនេះតាមរយៈការចូលរួមជាមួយអង្គការសង្គមស៊ីវិល សិក្ខាសាលាតស៊ូមតិពាក់ព័ន្ធនឹងសិទ្ធិជនជាតិដើមភាគតិច ទិវាបរិស្ថាន អភិបាលកិច្ចដីធ្លីនិងព្រៃឈើ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ពួកគាត់ក៏បានដាក់ពាក្យបណ្តឹងទៅអាជ្ញាធរមូលដ្ឋាន និងរដ្ឋបាលព្រៃឈើជាច្រើនលើក ប៉ុន្តែរដ្ឋបាលថ្នាកក្រោមជាតិមិនអាចបញ្ឈប់សកម្មភាពរបស់ក្រុមហ៊ុន ហេង ហ៊ាប នោះទេ។ ផ្អែកលើការវិភាគផ្នែកច្បាប់ និងឯកសារដែលមានស្រាប់ ក្រុមហ៊ុននេះ

មិនទាន់បានធ្វើអនុបយោគដីពីដីសាធារណៈរបស់រដ្ឋមកជាដីឯកជនរបស់រដ្ឋ មិនមានការធ្វើ EIA ឈូសឆាយដោយគ្មានលិខិតអនុញ្ញាត ចូលរួមបទល្មើសព្រៃឈើ មិនអនុវត្តតាមផែនការមេ និងកិច្ចព្រមព្រៀងជាមួយក្រសួងកសិកម្ម មិនមានហេដ្ឋារចនាសម្ព័ន្ធសមស្រប និងអនុវត្តខុសច្បាប់ផ្សេងៗទៀត[25]។

ពាក់ព័ន្ធនឹងដំណើរការនិរាសករណ៍សម្បទានដីសេដ្ឋកិច្ច សហគមន៍មិនបានចូលរួមក្នុងដំណើរការ និងមិនបានចូលរួមពិគ្រោះយោបល់ពីព្រោះរដ្ឋាភិបាលមិនអនុញ្ញាតពួកគាត់ចូលរួមពិនិត្យការអនុវត្តសម្បទានដីសេដ្ឋកិច្ចនេះទេ។ រហូតមកដល់ពេលនេះ ពួកគាត់មិនទាន់ដឹងអំពីព័ត៌នៃការនិរាសករណ៍សម្បទានដីសេដ្ឋកិច្ច របស់ក្រុមហ៊ុនវិនិយោគ ហេង ហ៊ាប នេះទេ។ ក្នុងករណីដែលរដ្ឋាភិបាលបាននិរាសករណ៍ក្រុមហ៊ុននេះ សហគមន៍មានសេចក្តីរីករាយណាស់ តែពួកគាត់សោកស្តាយបំផុតចំពោះការបាត់បង់ព្រៃឈើធម្មជាតិ និងជីវចម្រុះដោយសារសកម្មភាពក្រុមហ៊ុន។ ទោះជាយ៉ាងនេះក្តី អាជ្ញាធរមូលដ្ឋាន និងរដ្ឋបាលថ្នាក់ក្រោមជាតិហាក់ដូចជាមិនបានទទួលព័ត៌មានច្បាស់អំពីដំណើរការនិរាករណ៍និងផែនការទៅពេលអនាគតពាក់ព័ន្ធដីសម្បទាននោះទេ។

**លទ្ធផលនៃការតស៊ូមតិ**

ក្នុងឆ្នាំ២០១២-២០១៣ រដ្ឋាភិបាលបានអំពាវនាវផ្អាកការផ្តល់ដីសម្បទានសេដ្ឋកិច្ចក្នុងប្រទេសកម្ពុជា និងពិនិត្យមើលក្រុមហ៊ុនសម្បទានដែលមានស្រាប់ទូទាំងប្រទេស។ បន្ទាប់ពីការត្រួតពិនិត្យ និងវាយតម្លៃក្នុងឆ្នាំ២០១៤ ក្រុមហ៊ុន ហេង ហ៊ាប វិនិយោគត្រូវបានត្រួតពិនិត្យមើលយ៉ាងតឹងរឹងដោយក្រុមការងារក្រសួងកសិកម្ម។ មន្ទីរ អាជ្ញាធរមូលដ្ឋាន និងមន្ត្រីថ្នាក់ស្រុកបានលើកឡើងថា ក្រុមហ៊ុននេះមិនគោរពតាមច្បាប់របស់រដ្ឋាភិបាល បានចូលរួមប្រព្រឹត្តបទល្មើសព្រៃឈើ និងគ្មានឆន្ទៈក្នុងការវិនិយោគ។

សហគមន៍ដែលរងផលប៉ះពាល់ពីគម្រោងបានស្នើថា ក្រុមហ៊ុនសម្បទានដែលបាននិរាសករណ៍គួរតែផ្ទេរទៅឱ្យសហគមន៍ក្នុងរូបភាពជាដីសម្បទានសង្គមកិច្ច និងដើម្បីអភិរក្សព្រៃសហគមន៍។ បើសិនជារដ្ឋាភិបាលសម្រេចថានិរាសករណ៍ក្រុមហ៊ុននេះត្រូវតែសងនូវការកាប់ព្រៃឈើ ការហូរច្រោះដី ការបាត់បង់ជីវចម្រុះ ផលប៉ះពាល់ដល់ជីវភាពប្រចាំថ្ងៃ និងធនធានធម្មជាតិផ្សេងៗទៀត។

## ៧.១.២ ស្ថានភាពសម្បទានដីសេដ្ឋកិច្ចនៅក្នុងខេត្តស្ទឹងត្រែង

ខេត្តស្ទឹងត្រែងគឺជាខេត្តស្ថិតនៅតំបន់ដាច់ស្រយាលនៃភាគខាងជើងឈាងខាងកើតប្រទេសកម្ពុជា ដែលមានចំងាយប្រមាណជា៤៨១គីឡូម៉ែត្រពីទីក្រុងភ្នំពេញ។ ខេត្តនេះមានព្រំប្រទល់ខាងជើងជាប់ជាមួយសាធារណៈរដ្ឋប្រជាមានិតឡាវភាគ និងខាងកើតជាប់ខេត្តរតនៈគីរីភាគ ខាងត្បូងជាប់ខេត្តមណ្ឌលគីរី និងខាងលិចជាប់ខេត្តព្រះវិហារ ក្រចេះ និងកំពង់ធំ។ ខេត្តស្ទឹងត្រែងជាខេត្តតែមួយគត់ដែលជាបណ្តុំនៃទន្លេចំនួនសំខាន់ៗ (ទន្លេមេគង្គ ទន្លេសេកុង ទន្លេសេសាន និងទន្លេស្រែពក)។ សេដ្ឋកិច្ចខេត្តស្ទឹងត្រែងពឹងផ្អែកយ៉ាងធំលើវិស័យកសិកម្ម។ ដំណាំផ្សេងៗរួមមាន កៅស៊ូ វល្លិ៍ និងស្វាយចន្ទីត្រូវបានដាំដុះពាសពេញខេត្ត។ យោងតាមរបាយការណ៍សាលាខេត្តស្ទឹងត្រែង មានក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចចំនួន១២ស្ថិតនៅក្រោមដែនសមត្ថកិច្ចក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអាជ្ញាធរខេត្ត ដែលមានផ្ទៃដីសរុប១៧៨.៧១២ហិកតា។

[25] Interviewed with government officials and community consultation and field investigation

ក្រុមហ៊ុនវិនិយោគ សុខ ហេង ត្រូវបាននិរាសករណ៍ដោយរាជរដ្ឋាភិបាលនៅក្នុងឆ្នាំ២០១៥ ប៉ុន្តែនៅបន្តកិច្ចសន្យាលើផ្ទៃដីចំនួន៦២០ហិកតា ដែលបានដាំដុះដំណាំស្វាយចន្ទីរួចរាល់។ យោងលើការសម្ភាសន៍ជាមួយគ្រួសារចំនួន ២៦នាក់ ពួកគាត់ត្អូញត្អែថាម្ចាស់ក្រុមហ៊ុនបានបិទផ្លូវធ្វើដំណើររបស់ពួកគាត់ដែលភ្ជាប់ទៅផ្លូវជាតិលេខ០៧។ សហគមន៍រងផលប៉ះពាល់ពីគម្រោងសម្បទានបានលើកឡើងថា ក្រុមហ៊ុនមិនចង់ឱ្យប្រជាពលរដ្ឋឃើញសកម្មភាពកាប់ឈើខុសច្បាប់ដឹកនៅប្រទេសជិតខាង។ សហគមន៍បានលើកឡើងថាមុនពេលផ្តល់ដីសម្បទាន តំបន់នេះគ្របដណ្តប់ដោយព្រៃស្រោង និងពាក់កណ្តាលស្រោងដែលសហគមន៍អាចទៅរកធនធានធម្មជាតិដើម្បីបង្កើនប្រាក់ចំណូលសម្រាប់ជីវភាពប្រចាំថ្ងៃរបស់ពួកគាត់។ ព្រៃឈើត្រូវបានឈូកឆាយដោយគ្មានអន្តរាគមន៍ផ្លូវច្បាប់ពីរដ្ឋាភិបាល។ សហគមន៍ក៏បានលើកឡើងថាក្រុមហ៊ុនបានឈូសឆាយព្រៃនិងដីក្នុងទំហំមហិមា ប៉ុន្តែដាំដុះលើផ្ទៃដីតិចតួច(ដាំស្វាយចន្ទីជំនួស)។ បច្ចុប្បន្ននេះសហគមន៍ជួបការលំបាកក្នុងការធ្វើដំណើរទៅសាលារៀន ទីផ្សារ មណ្ឌលសុខភាព និងស្វែងរកចំណូលសម្រាប់ទ្រទ្រង់ជីវភាពប្រចាំថ្ងៃ។ ពួកគាត់បានប្តូរពីការធ្វើដំណើរលើផ្លូវគោកទៅជាការធ្វើដំណើរតាមផ្លូវទឹកដើម្បីដឹកកសិផលរបស់ពួកគាត់ទៅទីផ្សារខេត្តស្ទឹងត្រែង។

សរុបមក ការវិនិយោគរបស់ក្រុមហ៊ុន សុក ហេង មិនបានផ្តល់ផលប្រយោជន៍សម្រាប់សហគមន៍មូលដ្ឋាន តែផ្ទុយមកវិញ ក្រុមហ៊ុនបានផ្តល់នូវផលប៉ះពាល់អវិជ្ជមានដល់ជីវភាពសហគមន៍ដូចជាការការបំផ្លាញព្រៃធម្មជាតិ និងប្រព័ន្ធអេកូឡូស៊ីក្នុងតំបន់នោះ។ ខាងក្រោមនេះជាករណីសិក្សាទី២ ដែលបង្ហាញលម្អិតអំពីព័ត៌មានក្រុមហ៊ុន សុខ ហេង




ក្រាហ្វិច ៧.១.២: ទស្សនៈរបស់សហគមន៍រងផលប៉ះពាល់លើអត្ថប្រយោជន៍ពីនិរាសករណ៍សម្បទានដីសេដ្ឋកិច្ចនៅខេត្តស្ទឹងត្រែង

យោងតាមការសម្ភាសជាមួយប្រជាជនរងផលប៉ះពាល់ដែលរស់នៅជុំវិញគម្រោងសម្បទាន ដែលបាននិរាសករណ៍បង្ហាញថា ៤៧,៤%នៃអ្នកឆ្លើយតបត្អូញត្អែថានិរាសករណ៍សម្បទានដីសេដ្ឋកិច្ច(ក្រុមហ៊ុនវិនិយោគ សុខ ហេង) មិន

បានផ្តល់នូវអត្ថប្រយោជន៍ណាមួយសម្រាប់ពួកគាត់នោះទេពីព្រោះការវិនិយោគនេះបានធ្វើឱ្យបាត់បង់ប្រព័ន្ធអេកូឡូស៊ី និងជីវៈចម្រុះ និងការបាត់បង់ព្រៃឈើដែលជាទីកន្លែងសម្រាប់សហគមន៍អាចទៅរកចំណូលដើម្បីជីវភាពប្រចាំថ្ងៃ។ យ៉ាងហោចណាស់២២,១%នៃអ្នកឆ្លើយតបបានសំណូមពរថា សម្បទានដីសេដ្ឋកិច្ចដែលបាននិរាសករណ៍គួរតែរក្សាទុកសម្រាប់ស្តារព្រៃឈើ និងគម្របព្រៃឈើឡើងវិញ។ ទោះជាយ៉ាងនេះក្តី ១៦,៨%នៃអ្នកឆ្លើយតបបានស្នើថាសហគមន៍ដែលរងផលប៉ះពាល់ពីគម្រោងសម្បទានអាចប្រើប្រាស់ផ្លូវឆ្លងកាត់ក្រុមហ៊ុនដែលភ្ជាប់ទៅនឹងផ្លូវជាតិលេខ០៧ ដើម្បីធ្វើដំណើរទៅផ្សារ សាលារៀន មណ្ឌលសុខភាព ពិសេសសកម្មភាពលក់ដូរប្រចាំថ្ងៃ។

## ករណីសិក្សាទី២
## សហគមន៍រងគ្រោះលើកឡើងថា ពួកគេបានបិទផ្លូវធ្វើដំណើរដើម្បីកាប់ឈើខុសច្បាប់
### ក្រុមហ៊ុន សុខ ហេង វិនិយោគ

### សាវតា

ក្រុមហ៊ុន សុខ ហេង មានទីតាំងស្ថិតនៅក្នុងឃុំស្តៅ ស្រុកសេសាន ខេត្តស្ទឹងត្រែង។ វាមានចំងាយប្រមាណជា ៤៥គីឡូម៉ែត្រភាគខាងជើងឈាងខាងកើតទីរួមខេត្តស្ទឹងត្រែង។ គោលបំណងនៃការវិនិយោគគឺដើម្បីដាំអាកាស្យា និងសាងសង់រោងចក្រលើផ្ទៃដីសរុប ៧.១៧២ហិកតា។ ការវិនិយោគនេះមានរយៈពេល៧០ឆ្នាំដោយបានដាក់ប្រាក់កក់ចំនួន ៧.១៧២ដុល្លាអាមេរិច កាលពីថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០៦។ កិច្ចព្រមព្រៀងបានចុះហត្ថលេខាងរវាងក្រុមហ៊ុន និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ កាលពីថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០០៦។ ដីនេះបានមកពីការធ្វើអនុបយោគដីសាធារណៈរបស់រដ្ឋទៅជាដីឯកជនរបស់រដ្ឋ ដោយអនុលោមតាមមាត្រា០៤នៃអនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ច។ ក្រុមហ៊ុនវិនិយោគ សុខ ហេង នេះមិនបានធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គមកំឡុងពេលអនុវត្តគម្រោងនោះទេ។



**រូបថត ២.១**: ផែនទីក្រុមហ៊ុនវិនិយោគ សុខ ហេង លីមីតធីត ស្រុកសេសាន ខេត្តស្ទឹងត្រែង

## ការអនុវត្តក្របខណ្ឌច្បាប់របស់ក្រុមហ៊ុន

នៅថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០០៧ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានចេញលិខិតផ្លូវការលេខ ៦៥៧៦/៥៤៥កសក.នពពក ដើម្បីអនុញ្ញាតឱ្យក្រុមហ៊ុនឈូសឆាយដីក្នុងអនុតំបន់០១ ទំហំផ្ទៃដី២៥០០ហិកតា។ ទោះជាយ៉ាងនេះក្តី មានតែដីទំហំ២៥០ហិកតាប៉ុណ្ណោះដែលបានដាំដុះស្វាយចន្ទីនៃផ្ទៃដីដែលបានឈូសឆាយសរុប ៦២០ហិកតា។ បច្ចុប្បន្ននេះ ដីនេះត្រូវបានជួលឱ្យក្រុមហ៊ុន Trun Agriculture Fertilizer Investment ដើម្បីវិនិយោគដំណាំស្វាយចន្ទី។ យោងតាមច្បាប់គឺមិនអនុញ្ញាតឱ្យមានការផ្ទេរសម្បទានដីសេដ្ឋកិច្ចទៅអ្នកវិនិយោគផ្សេងដោយគ្មានការអនុញ្ញាត ឬអនុម័តពីរាជរដ្ឋាភិបាលនោះទេ។

នៅឆ្នាំ២០១៥រាជរដ្ឋាភិបាលកម្ពុជា តាមរយៈគណៈកម្មាធិការអន្តរក្រសួងបានសម្រេចបញ្ឈប់ និងនិរាសករណ៍កិច្ចព្រមព្រៀងជាមួយក្រុមហ៊ុនវិនិយោគ សុខ ហេង ពីព្រោះក្រុមហ៊ុននេះមិនគោរពតាមកិច្ចព្រមព្រៀងជាមួយរាជរដ្ឋាភិបាលនិងមិនអនុវត្តតាមផែនការមេ។ ទោះបីយ៉ាងណា ប្រជាពលរដ្ឋភាគច្រើនមិនបានដឹងថាក្រុមហ៊ុននេះត្រូវបាននិរាសករណ៍ដោយរដ្ឋាភិបាល ខណៈដែលក្រុមហ៊ុន Trun Agriculture Fertilizer Investment នៅតែបន្តសកម្មភាពដាំដុះដំណាំស្វាយចន្ទីរបស់ខ្លួនលើដីសម្បទាននេះ។

## ទំនាស់ដីធ្លីជាមួយសហគមន៍

កំឡុងពេលអនុវត្តគម្រោងក្នុងឆ្នាំ២០០៧ ក្រុមហ៊ុនបានដាក់បម្រាមដល់ប្រជាជនមិនឱ្យប្រើប្រាស់ផ្លូវដែលតភ្ជាប់

ទៅផ្លូវជាតិលេខ០៧ ទៅភូមិញ៉ីន។ ហេតុផលសំខាន់គឺក្រុមហ៊ុនមិនចង់ឱ្យពលរដ្ឋឃើញសកម្មភាពកាប់ឈើខុសច្បាប់ និងការធ្វើពាណិជ្ជកម្មក្នុងតំបន់របស់គេ។ លើសពីនេះទៅទៀត ក្រុមហ៊ុនខ្លាចក្រែងប្រជាពលរដ្ឋលួចសម្ភារៈ និងទ្រព្យសម្បត្តិរបស់ពួកគេ។ ក្នុងករណីនេះ មានតែមេភូមិញ៉ីន និងប្រពន្ធរបស់គាត់ប៉ុណ្ណោះដែលត្រូវបានអនុញ្ញាតឱ្យប្រើ ប្រាស់ផ្លូវនេះ។ ក្រុមហ៊ុនបានតម្រូវឱ្យគាត់ទូរស័ព្ទ និងជូនដំណឹងជាមុនដើម្បីហេតុផលសន្តិសុខ។ អ្នកភូមិខ្លះបានប្រើ ប្រាស់ទូកដើម្បីធ្វើដំណើរជំនួសឱ្យការធ្វើដំណើរតាមផ្លូវគោក។ ទោះបីយ៉ាងនេះក្តី មានតែគ្រួសារតិចតួចណាស់ដែលមាន ទូកផ្ទាល់ខ្លួននៅពេលនោះ។ ពេលនោះជាពេលវេលាដ៏លំបាកណាស់សម្រាប់អ្នកភូមិក្នុងការដឹកជញ្ជូនកសិផលរបស់ពួកគាត់ទៅលក់នៅទីផ្សារ ទៅពិនិត្យសុខភាព និងសាលារៀន។ អ្នកដើរតួនាទីសំខាន់នៅក្នុងទំនាស់នេះគឺប្រជាជនមូលដ្ឋាន ក្រុមហ៊ុន សុខ ហេង អាជ្ញាធរឃុំ ស្រុក និងខេត្ត។



រូបថត២.២: ស្វាយចន្ទីរបស់ក្រុមហ៊ុនវៀតណាមលើដីដែលបាននិរាសករណ៍របស់ក្រុមហ៊ុន សុខ ហេង និងការិល័យរបស់ក្រុមហ៊ុន

**អនុក្រមនៃការតស៊ូមតិរបស់សហគមន៍**

ប្រជាជនមានការខកចិត្តយ៉ាងខ្លាំងជាមួយក្រុមហ៊ុនកាលពីបួនឆ្នាំមុន ចាប់តាំងពីសំណើរបស់ពួកគាត់មិនបានត្រូវបានដោះស្រាយតាមរយៈនីតិវិធីរដ្ឋបាល។ ក្នុងឆ្នាំ២០១០ ប្រជាជនបានធ្វើការតវ៉ានៅក្នុងការិយាល័យក្រុមហ៊ុនដើម្បីឱ្យក្រុមហ៊ុនបើកផ្លូវធ្វើដំណើរដោយគ្មានលក្ខ័ណ្ឌ។ មានប្រជាជនប្រមាណជា៤០នាក់បានចូលរួមបាតុកម្មតវ៉ានេះដោយមានការខ្ចប់បាយ និងទឹកផងដែរ។

នៅឆ្នាំ២០១៥ រដ្ឋាភិបាលសម្រេចនិរាសករណ៍ក្រុមហ៊ុនវិនិយោគ សុខ ហេង និងបានកាត់បន្ថយទំហំនៅត្រឹម ៦២០ហិកតា (ដែលបានដាំដុះស្វាយចន្ទីរួចរាល់) ដើម្បីបន្តការវិនិយោគរបស់ពួកគេ[26]។ បន្ទាប់ពីការតវ៉ា និងចរចារ ក្រុមហ៊ុន សុខ ហេង បានអនុញ្ញាតឱ្យប្រជាពលរដ្ឋធ្វើដំណើរតាមផ្លូវដោយគ្មានលក្ខណ្ឌ។

ការទាមទារតម្រូវការរបស់ពួកគាត់ ប្រជាជនត្រូវការរៀបចំឱ្យបានល្អ ពិសេសចំណោមប្រជាជនរងគ្រោះក្នុងគោលបំណងដើម្បីតស៊ូមតិ និងទាមទារតម្រូវការរបស់ពួកគាត់ជាមួយក្រុមហ៊ុន។ លើសពីនេះ ការតវ៉ាគួរតែផ្អែកលើ

[26] Sar Chor Nar #35, on 09 Jan 2015

តម្រូវការរបស់មនុស្សដោយមានការគាំទ្រពីអាជ្ញាធរមូលដ្ឋាន។ ប្រជាពលរដ្ឋអាចអនុវត្តនូវការតស៊ូមតិតាមវិធីសាស្ត្រពីររួមទាំងវិធីសាស្ត្រត្រជាក់តាមរយៈការដាក់លិខិតទៅអាជ្ញាធរមូលដ្ឋាន និងធ្វើការតវ៉ាដើម្បីទាមទារសិទ្ធិនិងតម្រូវការរបស់ពួកគាត់។

**សំណូមពររបស់សហគមន៍ចំពោះសម្បទានដីសេដ្ឋកិច្ចដែលបាននិរាសករណ៍**

ភាគច្រើនបំផុតនៃអ្នកឆ្លើយតប(៣៥%)ស្នើសុំរាជរដ្ឋាភិបាលកម្ពុជាផ្តល់ដីសម្បទាននិរាសករណ៍នេះក្នុងទម្រង់ជាដីសម្បទានសង្គមកិច្ចដល់គ្រួសារក្រីក្រនិងគ្រួសារពុំមានដីប្រើប្រាស់ហើយ១៤%ទៀត ស្នើកែប្រែដីសម្បទាននិរាសករណ៍នេះទៅជាតំបន់ដែនជម្រកសត្វព្រៃសេសាន។ ភាគច្រើននៃអ្នកឆ្លើយតបស្នើសុំប្រើប្រាស់ផ្លូវនៅក្នុងដីសម្បទានដែលភ្ជាប់ទៅផ្លូវជាតិលេខ០៧។

## ៧.១.៣ ស្ថានភាពនៃសម្បទានដីសេដ្ឋកិច្ចនៅខេត្តឧត្តរមានជ័យ

នៅខែវិច្ឆិកា ឆ្នាំ២០១៤ សមាជិកក្រុមលេខាធិការដ្ឋានបច្ចេកទេសសម្បទានដីសេដ្ឋកិច្ចរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានចុះតាមដាន ត្រួតពិនិត្យ និងវាយតម្លៃក្រុមហ៊ុនអង្គរស៊ូហ្គ័រ ដែលមានទីតាំងស្ថិតនៅស្រុកសំរោង ខេត្តឧត្តរមានជ័យ។ បន្ទាប់ពីការផ្តល់សិទ្ធិប្រទានទៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ លេខ១២៩ ថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០០៧ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រុមហ៊ុនអង្គរស៊ូហ្គ័របានចុះកិច្ចព្រមព្រៀងបណ្តោះអាសន្នថ្ងៃទី២៤ ខែមករា ឆ្នាំ២០០៨ លើផ្ទៃដីទំហំ៦.៨២៣ហិកតា រយៈពេល៩០ឆ្នាំ ដោយយោងតាម ស.ជ.ណ របស់ទីស្តីការគណៈរដ្ឋមន្ត្រីលេខ១៤៧៥ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៧ ស្តីពីការឯកភាពជាគោលការណ៍សម្រាប់ការវិនិយោគរបស់ក្រុមហ៊ុនអង្គរស៊ូហ្គ័រ និងពីរក្រុមហ៊ុនទៀត(ទន្លេស៊ូហ្គ័រ ខេន អេនស៊ូហ្គ័រ)។ នាយកក្រុមហ៊ុនអង្គរស៊ូហ្គ័រលោក Tat Wanakornkul ជាជនជាតិថៃ។

ការធ្វើអនុបយោគដីសាធារណៈរបស់រដ្ឋទៅជាដីឯកជនរបស់រដ្ឋមិនបានអនុវត្តន៍ចំពោះក្រុមហ៊ុននេះទេដែលមិនអនុលោមតាមច្បាប់ភូមិបាលឆ្នាំ២០០១ មាត្រា៥៨ និងអនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ចឆ្នាំ២០០៥ មាត្រា៤។ អនុលោមតាមលិខិតលេខ៥៦០៤/៥៦៤ កសក នពពក ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានអនុម័តផែនការមេរបស់ក្រុមហ៊ុន ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០០៩។ ក្រុមហ៊ុនបានរក្សាព័ត៌មានទាំងនេះជាការសម្ងាត់ និងមានលំបាកក្នុងការទទួលបានព័ត៌មាន និងឯកសារផ្លូវច្បាប់ផ្សេងៗទៀត។ ក្រុមអ្នកសិក្សាស្រាវជ្រាវក៏ពុំអាចស្វែងរកលិខិតផ្លូវច្បាប់ពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានទេលើការឈូសឆាយដីអនុលោមតាមផែនការមេ ប៉ុន្តែនៅក្នុងឆ្នាំ២០១៣ ក្រុមហ៊ុនបានឈូសឆាយដីព្រៃឈើចំនួន២៤០ហិកតា[27]និងបន្តឈូសឆាយផ្ទៃដីនិងដីព្រៃទាំងអស់ដោយពុំគោរពតាមបទដ្ឋានគតិយុត្តនិងគោលនយោបាយរបស់ប្រទេសកម្ពុជា។

ទង្វើរបស់ក្រុមហ៊ុនបានបង្កឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សិទ្ធិដីធ្លីរបស់សហគមន៍ សិទ្ធិលំនៅដ្ឋាន ជីវភាពរស់នៅ សហគមន៍ព្រៃឈើ និងការរំលោភសិទ្ធិមនុស្ស។ ក្រុមហ៊ុនបានឈូសឆាយដីព្រៃឈើទាំងអស់ដោយគ្មានការអន្តរាគមន៍ពីអាជ្ញាធរខេត្ត និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ពាក់ព័ន្ធនឹងការអនុវត្ត

[27] Report of MAFF on evaluation, review and monitoring this company in 2013

ខុសច្បាប់។ សហគមន៍បានព្យាយាមធ្វើយុទ្ធនាការប្រឆាំងម្តងហើយម្តងទៀតដើម្បីការពារដីធ្លី ផ្ទះសំបែង និងទ្រព្យសម្បត្តិដោយរួមបញ្ចូលនូវស្រូវ ព្រៃឈើសហគមន៍ ផ្ទះ និងដីរបស់ពួកគាត់។

ជាអកុសល យុទ្ធនាការរបស់សហគមន៍ត្រូវបានទទួលរងការអន្តរាគមន៍ពីអាជ្ញាធរមូលដ្ឋាន ប៉ូលីស៍កងប្រដាប់អាវុធ និងក្រុមអង្គរក្សរបស់ក្រុមហ៊ុន។ ភាគច្រើននៃស្រូវ និងផ្ទះត្រូវបានដុតបំផ្លាញ និងអ្នកចូលរួមបាតុកម្មខ្លះត្រូវបានចាប់ខ្លួនដោយអាជ្ញាធរ។ មេដឹកនាំសហគមន៍ដែលធ្លាប់ជាមេភូមិបានត្អូញត្អែរថា *"អាជ្ញាធរបានផ្តល់សម្បទានដីកសិកម្មនិងដីផ្ទះដល់ពួកយើងដោយគ្មានលក្ខ័ណ្ឌ (ក្នុងរូបភាពជាដីសម្បទានសង្គមកិច្ច)។ យើងបានសាងសង់ផ្ទះ និងដាំដុះដំណាំស្រូវសម្រាប់អាហារ។ ឥឡូវនេះ យើងបានបាត់បង់អស់ហើយដោយសារតែអាជ្ញាធរ និងរដ្ឋាភិបាលថ្នាក់ជាតិបានផ្តល់ដីរបស់ពួកយើងទៅឱ្យក្រុមហ៊ុនឯកជនដើម្បីដាំដុះអំពៅដោយគ្មានសំណងអ្វីទាំងអស់។ ក្រុមហ៊ុន និងកងកម្លាំងប្រដាប់អាវុធ រួមទាំងប៉ូលីស៍បានដុតផ្ទះរបស់យើង និងស្រូវ ពួកគេមិនអនុញ្ញាតឱ្យពួកយើងប្រមូលផលស្រូវសិននោះទេ។ យើងលឺថារដ្ឋាភិបាលនិរាសករណ៍ក្រុមហ៊ុនសម្បទាននេះ ប៉ុន្តែពួកគេនៅតែមិនផ្តល់ដីត្រឡប់មកឱ្យយើងវិញទេ"* សហគមន៍រងគ្រោះបានលើកឡើង។

កំឡុងពេលចុះសិក្សាទៅទីវាល ក្រុមស្រាវជ្រាវបានសង្កេតឃើញថា មានរោងចក្រអារឈើចាស់មួយស្ថិតនៅក្នុងទីតាំងក្រុមហ៊ុន និងមានសំណល់ឈើដែលគេបោះបង់ចោលនៅទីនោះ។ មានការដាំដុះអំពៅតិចតួចដោយមិនមានការថែទាំ។




ក្រាហ្វិច ៧.១.៣: ទស្សនៈរបស់សហគមន៍រងផលប៉ះពាល់ពីលើប្រយោជន៍ពីការនិរាសករណ៍សម្បទានដីសេដ្ឋកិច្ច ខេត្តឧត្តរមានជ័យ

យោងតាមការសម្ភាសន៍ជាមួយប្រជាពលរដ្ឋរងផលប៉ះពាល់ដែលរស់នៅជុំវិញទីតាំងគម្រោងសម្បទាន បង្ហាញថា ៧០,៩%នៃអ្នកឆ្លើយតបបានបង្ហាញថាគាត់មិនឯកភាពទាំងស្រុងចំពោះអត្ថប្រយោជន៍ចំពោះជីវភាពសហគមន៍ ពីការ

និរាសករណ៍សម្បទានដីសេដ្ឋកិច្ច។ ប្រជាជនរងផលប៉ះពាល់បានត្អូញត្អែថាដីស្រែរបស់គាត់ត្រូវបានក្រុមហ៊ុនរំលោភយក ហើយដីទាំងនេះនឹងមិនត្រឡប់ឱ្យពួកគាត់វិញទេ បើទោះបីជាក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចនេះត្រូវបាននិរាសករណ៍ដោយរដ្ឋាភិបាលក៏ដោយ។ ប្រជាជនរងផលប៉ះពាល់បានអំពាវនាវយ៉ាងទទូចទៅរដ្ឋាភិបាល ពិសេសក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រគល់ដីសហគមន៍ទាំងអស់មកវិញដើម្បីឱ្យពួកគាត់ធ្វើកសិកម្ម និងបង្កើនប្រាក់ចំណូល។ ទោះបីយ៉ាងណា ២៧,៩% នៃអ្នកឆ្លើយតបបានស្នើឡើងថា សម្បទានដីសេដ្ឋកិច្ចដែលបាននិរាសករណ៍គួរតែរក្សាទុកសម្រាប់សម្បទានសង្គមកិច្ចដល់សហគមន៍ដែលមានដីស្រែតិចតួច ឬគ្រួសារមិនដី។ ពួកគាត់បានត្អូញត្អែថារាល់ដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុនអង្គរស៊ូហ្គ័រនឹងមិនមានតម្លៃសម្រាប់អេកូឡូស៊ី ឬធនធានធម្មជាតិសម្រាប់សហគមន៍នោះទេ ករណីសិក្សាទី៣ បង្ហាញនូវព័ត៌មានលម្អិតអំពីក្រុមហ៊ុនអង្គរស៊ូហ្គ័រ។

## ករណីសិក្សាទី៣

**"ពួកគេបានដុតផ្ទះ និងស្រូវរបស់ពួកយើងដោយគ្មានសំណាងអ្វីទាំងអស់"**

ស្រុកសំរោង និងស្រុកចុងកាល់ ខេត្តឧត្តរមានជ័យ

ក្រុមហ៊ុនផលិតស្ករសដ៏ធំបំផុតនៅក្នុងតំបន់អាស៊ីគឺក្រុមហ៊ុនសាជីវកម្មមិត្រផុលស៊ូហ្គើរ (Mitr Phol Sugar Corporation) របស់ប្រទេសថៃបានដកខ្លួនចេញពីក្រុមហ៊ុនបីរបស់ខ្លួននៅក្នុងខេត្តឧត្តរមានជ័យ ដោយសារតែមានការរិះគន់យ៉ាងធ្ងន់ធ្ងរលើការរំលោភសិទ្ធមនុស្ស និងទង្វើខុសច្បាប់នៅក្នុងតំបន់។ អនុលោមតាម សជណ លេខ១៤៧៥ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៧ ក្រុមហ៊ុនជាំជុះអំពៅចំនួនបីទទួលបានសម្បទានដីសេដ្ឋកិច្ចដែលមានផ្ទៃដីសរុប១៩.៧០០ហិកតា នៅក្នុងខេត្តឧត្តរមានជ័យ ក្រោមក្របខណ្ឌសម្បទានដីសេដ្ឋកិច្ចប្រទេសកម្ពុជាទៅក្រុមហ៊ុនអង្គរស៊ូហ្គ័រ ទន្លេស៊ូហ្គើរខេន និង ក្រុមហ៊ុន ខេន អែន ស៊ូហ្គើរវ៉ាឡី។

នៅក្នុងខេត្តឧត្តរមានជ័យ ភូមិអូបាត់មាន់ និងភូមិបុសបានទទួលរងគ្រោះជាងគេបំផុត។ មុនពេលផ្តល់សម្បទានដី កសិករនៅភូមិបុសបានសាងសង់ផ្ទះក្នុងឆ្នាំ១៩៩៨ បន្ទាប់ពីដីនេះត្រូវបានដោះមីនរួចរាល់មក។ ការចុះបញ្ជីដីធ្លីផ្លូវការសម្រាប់ដីភូមិ និងដីចំការត្រូវបានផ្តល់ដល់អ្នកភូមិ និងកម្មវិធីចែកប័ណ្ណដីធ្លីក៏បានរៀបចំឡើងដោយមានការចូលរួមពីមន្ត្រី និងរដ្ឋបាលព្រៃឈើ។ នៅក្នុងឆ្នាំ២០០៦ សហគមន៍ព្រៃឈើ រតនៈសម្បត្តិ និងរតនៈរុក្ខាត្រូវបានបង្កើតឡើង ដោយមានការគាំទ្រដោយសហគមន៍អឺរ៉ុប ដែលមានសមាជិក១៦ភូមិ រួមទាំងភូមិបុសផងដែរ។




រូបថត៣.១: ផែនទីក្រុមហ៊ុន អង្គរស៊ូហ្គើរ នៅឧត្តរមានជ័យ

**ការផ្លាស់ប្តូរជីវិតាពរបស់សហគមន៍**

គ្រប់យ៉ាងត្រូវបានផ្លាស់ប្តូរទាំងស្រុងនៅក្នុងឆ្នាំ២០០៨-២០០៩ នៅពេលដែលដីត្រូវបានឈូសឆាយ និងអ្នកភូមិត្រូវបានបណ្តេញដោយបង្ខំដោយគ្មានការពិគ្រោះយោបល់ជាមុន គ្មានការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គម និងគ្មានដីកាតុលាការ។ នៅក្នុងឆ្នាំ២០០៨ បុគ្គលិកក្រុមហ៊ុនអង្គរស៊ូហ្គើរបានមកភូមិបុស ដោយមានការណែនាំពីអាជ្ញាធរមូលដ្ឋាន និងបានបំផ្លាញផ្ទះអស់១៥៤ខ្នង។ អ្នកភូមិត្រូវបានគំរាមកំហែងដើម្បីឱ្យទទួលយកសំណងដែលបានផ្តល់ឱ្យ ឬពួកគាត់នឹងប្រឈមមុខនឹងការស៊ើបអង្កេតពីបទឧក្រិដ្ឋ។ ការផ្តល់សំណងមិនសមរម្យ និងតូចជាងប្លង់ដីដែលគាត់ជាម្ចាស់ពីមុនមក។

នៅក្នុងខែតុលា ឆ្នាំ២០០៩ ភូមិអូបាត់មាន់ ត្រូវបានហាមឃាត់ដោយមន្រ្តីរដ្ឋបាលព្រៃឈើ និងកងយោធពលខេមរភូមិន្ទដោយមិនអនុញ្ញាតឱ្យក្រុមការងារសិទ្ធិមនុស្ស និងអ្នកសែតចូលទៅទីនោះទេ។ ប៉ូលីស្ត៍ ទាហាន កងទ័ព និងទាហានការពារក្រុមហ៊ុនឯកជនប្រហែល១០០នាក់បានចូលទៅក្នុងភូមិ ហើយបានដុតបំផ្លាញផ្ទះសំបែងប្រជាជនប្រហែល១០០ខ្នង។ កសិករមួយចំនួនត្រូវបានចាប់ខ្លួន និងអ្នកភូមិក្មេងៗត្រូវបានដួលសន្លប់មិនដឹងខ្លួន។ អ្នកភូមិត្រូវបានបង្ខំឱ្យផ្តិតមេដៃលើក្រដាសដែលបានថ្លែងការថា ពួកគេបានស្ម័គ្រចិត្តឱ្យដុតផ្ទះ និងទទួលយកសំណង អ្នកដែលរឹងទទឹងនឹងទទួលរងដោយអំពើហឹង្សា។ យ៉ាងហោចណាស់ គ្រួសារចំនួន២០០គ្រួសារបានបាត់បង់ផ្ទះសំបែង និងត្រូវបានសាងសង់លំនៅដ្ឋានថ្មីនៅទីតាំងដែលមិនសមរម្យ ដែលជាទីកន្លែងសំបូរដោយចំការមីន។

ការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរដ៏ធំនេះត្រូវបានរក្សាទុកជាឯកសារ និងផលប៉ះពាល់លើជីវភាពត្រូវបានបំផ្លាញ ការបណ្តេញដោយបង្ខំនេះបានកើតឡើងមុនពេលប្រមូលផលស្រូវ ទុកគ្រួសារដែលត្រូវបានបង្ខំឱ្យចាកចេញនេះដោយគ្មានអាហារនិងប្រាក់ចំណូល។ តំបន់ដែលតាំងទីលំនៅថ្មីមិនមានផ្ទះសំបែង មិនមានហេដ្ឋារចនាសម្ព័ន្ធសមស្រប ដូចជាផ្លូវធ្វើដំណើរសមរម្យ ការទទួលបានការអប់រំ និងសេវាថែទាំសុខភាពមានការលំបាក។ ធនធានទ្រព្យសម្បត្តិរួមដូចជាព្រៃ

ឈើត្រូវបានបំផ្លាញ។ កសិករបានបាត់បង់ទ្រព្យសម្បត្តិដ៏សំខាន់សម្រាប់ជីវភាពរស់នៅដូចជាដីធ្លី ហើយប្រជាជនភាគច្រើនបានសម្រេចចិត្តធ្វើចំណាកស្រុកដោយខុសច្បាប់ទៅប្រទេសថៃដើម្បីស្វែងរកឱកាសការងារផ្សេងៗ។

**ការអន្តរាគមន៍ពីតាតីទី៣**

នៅក្នុងខែមីនា ឆ្នាំ២០១៣ ក្រុមសវនកម្មពីក្រុមហ៊ុនកូកាកូឡា ដែលក្រុមហ៊ុន Mitr Phol ជាអ្នកផ្គត់ផ្គង់ធំបំផុតទី៣ ត្រូវបានអនុញ្ញាតចុះមើលតំបន់ក្រុមហ៊ុនដោយមានប៉ូលីស្ដីអមដំណើរ ដែលធ្វើឱ្យការស៊ើបអង្កេតណាមួយមិនអាចកើតមានឡើងបាន។ នៅក្នុងខែកញ្ញា-តុលា ឆ្នាំ២០១៤ បុគ្គលិកមកពីអង្គការសមធម៌កម្ពុជា(EC) អង្គការ និងអ្នកស៊ើបអង្កេតដែលបានចុះទៅមើលអ្នកភូមិលើដំណើរការរៀបចំពាក្យបណ្ដឹងផ្លូវការប្រឆាំងក្រុមហ៊ុន ត្រូវបានរារាំងដោយប៉ូលីស្ដី និងឃាត់ខ្លួនពេញមួយយប់នៅប៉ុស្ដិ៍ប៉ូលីស។ ការសម្ភាសន៍ជាមួយអ្នកភូមិត្រូវបានបញ្ឈប់ និងអង្គការសមធម៌កម្ពុជាមិនត្រូវបានអនុញ្ញាតឱ្យជួបជាមួយអ្នកភូមិបើមិនមានលិខិតអនុញ្ញាតជាផ្លូវការពីអាជ្ញាធរមូលដ្ឋាន ខណៈដែលនេះគឺមិនមានចែងនៅក្នុងច្បាប់ណាមួយរបស់ប្រទេសកម្ពុជា។

**ក្របខណ្ឌច្បាប់របស់ក្រុមហ៊ុន**

អនុលោមតាមលទ្ធផលនៃការត្រួតពិនិត្យ និងការវាយតម្លៃស៊ីជម្រៅរបស់រាជរដ្ឋាភិបាលលើការអនុវត្តសម្បទានដីសេដ្ឋកិច្ច ក្រុមការងារវាយតម្លៃរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានចុះត្រួតពិនិត្យក្រុមហ៊ុនដល់ទីវាល និង ក្រុមហ៊ុនផ្សេងៗទៀតដែលមានទីតាំងស្ថិតនៅក្នុងខេត្តឧត្ដរមានជ័យ។ ជាលទ្ធផលនៃការវាយតម្លៃបង្ហាញថា ក្រុមហ៊ុន អង្គរស៊ូហ្គើរបានចុះកិច្ចសន្យាជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនៅថ្ងៃទី២៤ ខែមករា ឆ្នាំ២០០៨ លើផ្ទៃដី៦៦១៨ហិកតា រយៈពេល៩០ឆ្នាំ បន្ទាប់ពីទទួលការឯកភាពជាគោលការពីទីស្ដីការគណៈរដ្ឋមន្ត្រី តាមរយៈ សជណ លេខ៨៥ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០០៨ និងអនុក្រឹត្យស្ដីពីសិទ្ធប្រទានពីរាជរដ្ឋាភិបាលទៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ លេខ០៣១ ថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០០៧។




រូបថត ៣.២: រោងចក្រអារឈើ និងការិយាល័យក្រុមហ៊ុន មានទីតាំងស្ថិតនៅក្នុងក្រុមហ៊ុនអង្គរស៊ូហ្គើរ

មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តឧត្តរមានជ័យ បានរាយការណ៍ថា ក្រុមហ៊ុនមិនដែលបង្ហាញពួកគាត់អំពីលិខិតអនុញ្ញាតដើម្បីឈូសឆាយដី និងព្រៃពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទទេ តែក្រុមហ៊ុនបានឈូសឆាយព្រៃឈើទាំងអស់គ្មានសល់នៅក្នុងតំបន់សម្បទានដីសេដ្ឋកិច្ច។ ទោះបីយ៉ាងណា នៅក្នុងលេខាធិការដ្ឋានក្រសួងកសិកម្ម

រុក្ខាប្រមាញ់ និងនេសាទ មានលិខិតលេខ៥៦០៣/៥៦៣ កសក នពពក ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០០៩ បានអនុម័តលើផែនការមេរបស់ក្រុមហ៊ុន និងមានការអនុញ្ញាតឱ្យឈូសឆាយដីក្នុងតំបន់ខ្លះ។ ផ្អែកតាមរបាយការណ៍វាយតម្លៃឆ្នាំ ២០១៣ របស់ក្រសួងកសិកម្ម ក្រុមហ៊ុននេះបានឈូសឆាយដី និងបានផ្លាស់ប្តូរមុខដំណាំពីការដាំអំពៅ ទៅជាការដាំដំឡូងមីវិញដោយសារដីពុំមានជីជាតិគ្រប់គ្រាន់។

**ព្រៃឈើត្រូវបានឈូសឆាយទាំងស្រុង**

គួរឱ្យភ្ញាក់ផ្អើលបន្ទាប់ពីការឈូសឆាយព្រៃឈើអស់ គ្រប់យ៉ាងត្រូវប្រគល់ឱ្យរដ្ឋាភិបាលវិញដោយគ្មានសំណង ឬការដាក់ទណ្ឌកម្មផ្លូវច្បាប់ណាមួយក្នុងគោលបំណងបញ្ចប់នូវទំនាស់ដីធ្លីដ៏រ៉ាំរ៉ៃ និងការរិះគន់ធ្ងន់ធ្ងររវាងក្រុមហ៊ុន និងសហគមន៍ដែលរងផលប៉ះពាល់។ ហេតុផលចម្បងនៃការបង្វិលដីជូនរដ្ឋវិញដោយសារតែទំនាស់ដីធ្លីជាមួយពលរដ្ឋ និងសាវនាការតុលាការ ពិសេសក្រុមហ៊ុនមិនចង់ឱ្យទំនាស់ដីធ្លីនេះប៉ះពាល់ដល់កេរ្តិ៍ឈ្មោះរបស់ក្រុមហ៊ុនរបស់ពួកគេ។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានអញ្ជើញក្រុមហ៊ុននេះទៅពិភាក្សាលើបញ្ហាទាំងនេះកាលពីថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៤ តាមរយៈលិខិតលេខ៧៣៨០/៤៤៨ កសក នពពក។

គួរកត់សម្គាល់ថា ក្រុមហ៊ុនបានតម្លើងរោងចក្រអារឈើក្នុងទីតាំងក្រុមហ៊ុនអង្គរស៊ូហ្គើរ ប៉ុន្តែរដ្ឋាភិបាលបានលើកឡើងថា ម៉ាស៊ីននេះហួសសុពលភាព។ ទោះជាយ៉ាងណា ព្រៃឈើលើដីសម្បទានដែលមានទំហំផ្ទៃដីចំនួន៦៦១៨ ហិកតា ត្រូវបានឈូសឆាយអស់។ តាំងពីឆ្នាំ២០១១ ក្រុមហ៊ុនមិនបានអនុវត្តសកម្មភាពអ្វីទាំងអស់នៅលើដីសម្បទាននេះ។ ជាទូទៅ ក្រុមហ៊ុនមិនបានសហការល្អជាមួយក្រុមលេខាធិការដ្ឋានសម្បទានដីសេដ្ឋកិច្ចក្នុងការផ្តល់ឯកសារផ្លូវច្បាប់ និងព័ត៌មាននោះទេ។ មុនពេលបង្វិលដីជូនរដ្ឋវិញ ក្រុមហ៊ុនបានបញ្ឈប់បុគ្គលិកទាំងអស់ ដឹកជញ្ជូនគ្រឿងចក្រ អេស្កាវ៉ាទ័រ និងឧបករណ៍ផ្សេងៗចេញពីទីតាំងដីសម្បទាន។ នៅឆ្នាំ២០១៥ ទីស្តីការគណៈរដ្ឋមន្ត្រីបានទទួលយកសំណើរបស់ក្រុម ហ៊ុនដើម្បីបង្វិលដីសម្បទានជូនរដ្ឋាភិបាលវិញ។

## ៧.១.៤ ស្ថានភាពសម្បទានដីសេដ្ឋកិច្ចនៅក្នុងខេត្តក្រចេះ

ជាច្រើនទសវត្សមកហើយតំបន់ដែនជម្រកសត្វព្រៃស្នួលដែលមានទីតាំងស្ថិតនៅក្នុងខេត្តក្រចេះប្រទេសកម្ពុជាបានទទួលរងសកម្មភាពកាប់ឈើខុសច្បាប់ និងជម្លោះដ៏រ៉ាំរ៉ៃ។ ដែនជម្រកសត្វព្រៃស្នួលជាទីតាំងយុទ្ធសាស្ត្រសម្រាប់អ្នកកាប់ឈើ និងអ្នកធ្វើពាណិជ្ជកម្មឈើ ពីព្រោះវាស្ថិតនៅជាប់ព្រំដែនដែលបង្កលក្ខណៈងាយស្រួលសម្រាប់ពាណិជ្ជកម្មឈើស្របច្បាប់ និងខុសច្បាប់ ជាពិសេសឈើប្រណិត ទៅវៀតណាម។ ការវិភាគរបស់ទស្សនាវដ្តីបរិស្ថានអន្តរជាតិមួយបានលើកឡើងថា ការប្រើប្រាស់ដីក្នុងដែនជម្រកសត្វព្រៃស្នួលដោយការផ្តល់សម្បទានដីសេដ្ឋកិច្ចថ្មីៗជារឿងគួរឱ្យអស់សំណើច និងបរាជ័យ។ បច្ចុប្បន្ននេះ ផ្ទៃដីដែនជម្រកសត្វព្រៃទាំងមូល(៧៥.០០០ហិកតា) ត្រូវបានគ្របដណ្តប់ដោយក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច(១២៦.០០០ហិកតា) បង្កើតឱ្យមានការបណ្តេញដោយបង្ខំចំពោះប្រជាជន បង្កើនសកម្មភាពកាប់ព្រៃឈើខុសច្បាប់ ដោយបានកែប្រែពីការការពារព្រៃឈើទាំងស្រុងទៅជាតំបន់អាជីវកម្មព្រៃឈើ និងកសិឧស្សាហកម្ម។

យោងតាមរបាយការណ៍របស់រដ្ឋបាលព្រៃឈើឆ្នាំ២០១៥ មានក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចចំនួន៤២ (៤៧ទីតាំង)ដែលមានទំហំផ្ទៃដីសរុប ៤៧៤១០៣ហិកតា។ ដីសម្បទានសេដ្ឋកិច្ចទាំងអស់ស្ថិតនៅក្នុងស្រុកចំនួន០៥ ដែលរួមមានស្រុកស្នួល ស្រុកឆ្លូង ស្រុកចិត្របុរី ស្រុកសំបូ និងស្រុកព្រែកប្រសប់។ ក្រុមហ៊ុនចំនួន០៩ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងបរិស្ថាន ដែលមានទំហំផ្ទៃដី៥៣.៣៤១ហិកតា។




ក្រាហ្វិច ៧.១.៤ ទស្សនៈរបស់សហគមន៍រងផលប៉ះពាល់លើអត្ថប្រយោជន៍ពីការនិរាសករណ៍សម្បទានដីសេដ្ឋកិច្ច នៅក្នុងខេត្តក្រចេះ

ដោយមានការគាំទ្រពីបទបញ្ជា០១បប និងមានការគាំទ្រពីអាជ្ញាធរដែនដីនៅក្នុងឆ្នាំ២០១២ នេះជាឱកាសក្នុងការទទួលបានបណ្ណកម្មសិទ្ធដីថ្មីចំពោះគ្រួសារ ដែលកំពុងរស់នៅដោយគ្មានឯកសារច្បាប់ច្បាស់លាស់លើដីរដ្ឋក្នុងរូបភាពជាសម្បទានសេដ្ឋកិច្ច ឬព្រៃសម្បទាន។ យោងតាមរបាយការណ៍របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (មិថុនា ២០១៣) មានប្លង់កម្មសិទ្ធដីចំនួន៣៨០.០០០សន្លឹកត្រូវបានបែងចែកទៅឱ្យសហគមន៍។ ភាគច្រើននៃក្រុមហ៊ុនឯកជននៅទីនោះមិនសប្បាយចិត្តចំពោះគោលនយោបាយនេះទេ ខណៈដែលប្រជាជនបានអបអរសាទរចំពោះវិធានការរបស់រាជរដ្ឋាភិបាល(បទបញ្ជា០១បប)។ ក្នុងរវាងឆ្នាំ២០១២-២០១៣ សហគមន៍ដែលរងគ្រោះបានទទួលជោគជ័យលើការងារតស៊ូមតិរបស់ពួកគាត់ប្រឆាំងនឹងក្រុមហ៊ុន ហួត សម្បត្តិ ដែលមានទីតាំងស្ថិតនៅក្នុងដែនជម្រកសត្វព្រៃស្នួល ឃុំ២ធ្នូ ស្រុកស្នួល ខេត្តក្រចេះ។

អនុលោមតាមអនុក្រឹត្យលេខ០១ អនក្រ.បករបស់រាជរដ្ឋាភិបាលកម្ពុជា ភាគច្រើននៃដីសម្បទានសេដ្ឋកិច្ចត្រូវបានផ្តល់ទៅសហគមន៍ប្រមាណជា ១.៧៩៩គ្រួសារ ដែលមានផ្ទៃដីសរុបច្រើនជាង៤០០០ហិកតា។ យោងតាមការសម្ភាសន៍ជាមួយប្រជាជនរងផលប៉ះពាល់ដែលបាន និងកំពុងរស់នៅលើអតីតដីសម្បទានរបស់ក្រុមហ៊ុន ហួត សម្បត្តិ ៥៧,១% នៃអ្នកឆ្លើយតបមានសេចក្តីសប្បាយរីករាយណាស់ដែលបានលឺអំពីសេចក្តីសម្រេចរបស់រដ្ឋាភិបាលបានលុបចោលក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច បើទោះបីជាពួកគាត់បានទទួលបណ្ណកម្មសិទ្ធដីមុនពេលនិរាសករណ៍នេះក៏ដោយ។

ការនិរាសករណ៍សម្បទានដីសេដ្ឋកិច្ចបានធ្វើឱ្យពួកគាត់មានភាពរឹងមាំជាងមុនលើការគ្រប់គ្រងដី និងវិនិយោគដំណាំកសិកម្ម។ ពួកគាត់ក៏បានអបអរសាទរចំពោះការនិរាសករណ៍សម្បទានដីសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ហួត សម្បត្តិ ក្នុងឆ្នាំ ២០១៥នេះផងដែរ។ លទ្ធផលនៃការពិគ្រោះយោបល់ថ្នាក់ឃុំជាមួយក្រុមអ្នកស្រាវជ្រាវបង្ហាញថា ដីដែលនៅសល់ពីការនិរាសករណ៍សម្បទានដីសេដ្ឋកិច្ចប្រមាណជា១៣០០ហិកតា ត្រូវបានបាត់បង់ទាំងស្រុងទៅសហគមន៍ដោយសារពួកគាត់ពង្រីកព្រំដី។ ឃុំនិងមេភូមិមិនបានដឹងអំពីទីតាំងដី និងព្រំដីនៃដីសាធារណៈរបស់រដ្ឋដែលស្ថិតនៅក្នុងតំបន់ក្រុមហ៊ុន ហួត សម្បត្តិនោះទេ។ ទោះបីយ៉ាងណា ៣០%នៃអ្នកឆ្លើយតបបញ្ជាក់ថា តាំងពីឆ្នាំ២០១៥មក ប្រាក់ចំណូលរបស់ពួកគាត់មានភាពប្រសើរឡើង ពីព្រោះពួកគាត់អាចរកចំណូលបានតាមរយៈការធ្វើដំណាំកសិកម្ម ដំណាំកសិឧស្សាហកម្ម ការធ្វើអាជីវកម្មខ្នាតតូច និងជម្រើសមុខរបរចិញ្ចឹមជីវិតផ្សេងៗទៀត។ មានតែ៧%នៃអ្នកឆ្លើយតបបានរាយការណ៍ថានិរាសករណ៍សប្បទានដីសេដ្ឋកិច្ចមិនបានផ្ដល់ផលប្រយោជន៍ណាមួយដល់ពួកគាត់ទេដែលរស់នៅអចិន្ត្រៃយ៍នោះទេ ពីព្រោះភាគច្រើនបំផុតនៃអ្នកដែលទទួលបានបណ្ណកម្មសិទ្ធដីពីរដ្ឋាភិបាលគឺសុទ្ធសឹងតែអ្នកចំណាកស្រុកពីខេត្តផ្សេងៗ ដូចជា កំពង់ចាម ត្បូងឃ្មុំ និងព្រៃវែង។ អ្នកភូមិដែលរស់នៅអចិន្ត្រៃខ្លះបានបន្ថែមថាភាគច្រើននៃដីរបស់ពួកគេបានលក់ទៅឱ្យអ្នកមានទ្រព្យសម្បត្តិច្រើនដែលមកពីភ្នំពេញ និងខេត្តផ្សេងៗក្នុងតម្លៃប្រហែល ៣៥០០ទៅ៥០០០ដុល្លាអាមេរិចក្នុងមួយហិកតា។ ខាងក្រោមនេះ ជាករណីសិក្សាទី៤ ដែលបង្ហាញអំពីព័ត៌មានលម្អិតនៃស្ថានភាពនិរាសករណ៍សម្បទានដីសេដ្ឋកិច្ចក្នុងស្រុកស្នួល ខេត្តក្រចេះ។

## ករណីសិក្សាទី៤

### សហគមន៍រងគ្រោះបានទទួលបណ្ណកម្មសិទ្ធដីធ្លី និងទទួលបានប្រាក់ចំណូលប្រសើរឡើងបន្ទាប់ពីនិរាសករណ៍សម្បទានដីសេដ្ឋកិច្ច ក្រុមហ៊ុន ហួត សម្បត្តិ

**សាវតា**

ក្រុមហ៊ុន ហួត សម្បត្តិ ជាក្រុមហ៊ុនដែលទទួលបានសម្បទានដីសេដ្ឋកិច្ចដែលមានស្ថិតនៅភូមិជ្រោះជ្រៅពោធិ៍សាល ឃុំ២ធ្នូ ស្រុកស្នួល ខេត្តក្រចេះ។ ក្រុមហ៊ុនទទួលបានការឯកភាពជាគោលការណ៍ពីទីស្ដីការគណៈរដ្ឋមន្ត្រី (សជណ) លេខ៤៦១ ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០០៩ ដើម្បីអភិវឌ្ឍន៍ដំណាំកៅស៊ូ និងដំណាំកសិឧស្សាហកម្ម លើទំហំផ្ទៃដីសរុប ៦៤៣២ហិកតារយៈពេល៩០ឆ្នាំ។ ក្រុមហ៊ុននេះស្ថិតនៅក្រោមដែនសមត្ថកិច្ចគ្រប់គ្រងរបស់ក្រសួងបរិស្ថាន។ អនុលោមតាមអនុក្រឹត្យលេខ១២៨ អនក្រ បក ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០០៩ រាជរដ្ឋាភិបាលកម្ពុជា បានកំណត់យកតំបន់គ្រប់គ្រងនៃដែនជម្រកសត្វព្រៃស្នួលទៅជាតំបន់ប្រើប្រាស់ដោយចីរភាពក្នុងភូមិសាស្ត្រឃុំ២ធ្នូ ស្រុកស្នួល ខេត្តក្រចេះ ដើម្បីសម្បទានទៅក្រុមហ៊ុន ហួត សម្បត្តិ។

ក្របខណ្ឌច្បាប់របស់ក្រុមហ៊ុន

នៅថ្ងៃទី៣០ ខែតុលា ឆ្នាំ២០០៩ រាជរដ្ឋាភិបាលកម្ពុជាបានចុះហត្ថលេខាលើអនុក្រឹត្យស្ដីពីការធ្វើអនុបយោគដីសាធារណៈរបស់រដ្ឋនៃដែនជម្រកសត្វព្រៃស្នួលទៅជាដីឯកជនរបស់រដ្ឋដែលមានទីតាំងស្ថិតនៅឃុំ០២ធ្នូ ស្រុកស្នួល ទំហំផ្ទៃដី៦.៤៣២ហិកតា ដើម្បីសម្បទានទៅឱ្យក្រុមហ៊ុន ហួត សម្បត្តិ ដើម្បីវិនិយោគដំណាំកៅស៊ូ និងដំណាំកសិ

ឧស្សាហកម្មផ្សេងៗទៀត។ នៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០០៩ រាជរដ្ឋាភិបាលកម្ពុជាបានចេញអនុក្រឹត្យលេខ១៨៣ ស្ដីពីសិទ្ធិប្រទានទៅក្រសួង បរិស្ថានដើម្បីចុះកិច្ចព្រមព្រៀងជាមួយក្រុមហ៊ុន ហួត សម្បត្តិ។ ប្រាំបីខែក្រោយមក ក្រុមហ៊ុន ហួត សម្បត្តិ និងក្រសួងបរិស្ថានបានចុះកិច្ចព្រមព្រៀងនៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១០។


ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ០១ អនក្រ.បក

អនុក្រឹត្យ
ស្តីពី

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នស ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល

អនុលោមតាមគោលនយោបាយចាស់ សកម្មភាពថ្មី បទបញ្ជាលេខ០១បប ថ្ងៃទី០១ ខែមករា ឆ្នាំ២០១៣ សម្រេចកាត់ដីទំហំ៤.៩៩៨ហិកតា នៃផ្ទៃដីសរុប៦.៤៣២ហិកតា របស់ក្រុមហ៊ុន ហួត សម្បត្តិ ដើម្បីធ្វើប្រទានកម្មជាកម្មសិទ្ធិជូនពលរដ្ឋភូមិជ្រោះជ្រោយពោធិ៍សាលចំនួន១.៧៩៩គ្រួសារ[28] និងរក្សាដីទំហំកាត់បន្ថយទំហំចំនួន៣០៥,៤២ហិកតា ជាដីសាធារណៈរបស់រដ្ឋ។ ចុងក្រោយ ទំហំផ្ទៃដីសរុបរបស់ក្រុមហ៊ុននេះនៅសល់ត្រឹមតែ ១.៣៣៣,៨៧ហិកតា សម្រាប់វិនិយោគ។ បន្ទាប់ពីការវាយតម្លៃសម្បទានដីសេដ្ឋកិច្ចក្នុងឆ្នាំ២០១៤ និង២០១៥ រដ្ឋាភិបាលសម្រេចនិរាសករណ៍ក្រុមហ៊ុននេះតាមរយៈសជណ លេខ២៣៣ ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៥ និងនិរាសករណ៍រាល់លិខិតបទដ្ឋានគតិយុត្តទាំងអស់របស់ក្រុមហ៊ុននេះ។ យោងលើផែនការគ្រប់គ្រងព្រៃឈើឆ្នាំ២០១៥-២០១៩ របស់ខណ្ឌរដ្ឋបាលព្រៃឈើបង្ហាញថា រដ្ឋាភិបាលបានផ្ដល់សម្បទានដីសេដ្ឋកិច្ចទៅក្រុមហ៊ុន ចំនួន ៤២ ដោយមានទំហំផ្ទៃដីសរុប៤៧.៤១០ហិកតា ក្នុងខេត្តក្រចេះ។ ក្រុមហ៊ុនទាំងនេះស្ថិតនៅក្នុងស្រុកចំនួនប្រាំ ដូចជា ស្នួល ឆ្លូង ចិត្របូរី សំបូរ និងព្រែកប្រសប់។ ប្រាបួនក្រុមហ៊ុនក្នុងចំណោម៤២ ស្ថិតនៅក្រោមដែនសមត្ថកិច្ចក្រសួងបរិស្ថាន[29]។ ភាគច្រើននៃក្រុមហ៊ុនទាំងនោះស្ថិតនៅក្រោមដែនសមត្ថកិច្ចក្រសួងបរិស្ថានស្ថិតនៅក្នុងតំបន់ដែនជម្រកសត្វព្រៃស្នួល[30]។

## សម្បទានដីសង្គមកិច្ច និងជីវភាពរបស់សហគមន៍

ក្រុមហ៊ុន ហួត សម្បត្តិ គឺជាក្រុមហ៊ុនមួយក្នុងចំណោមក្រុមហ៊ុន០៩ទៀតដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងបរិស្ថានដែលមានទីតាំងស្ថិតនៅតំបន់ដែនជម្រកសត្វព្រៃស្នួល។ សមាជិកក្រុមប្រឹក្សាឃុំ២ធ្នូ ប្រធានភូមិនានា និងប្រធានការិយាល័យកសិកម្មស្រុកបានបញ្ជាក់ថាដីសម្បទានរបស់ក្រុមហ៊ុន ហួត សម្បត្តិ បានទទួលរងផលប៉ះពាល់ពីបទបញ្ជា០១បបក្នុងឆ្នាំ២០១២-២០១៣។ បន្ទាប់ពីកាត់បន្ថយទំហំផ្ទៃដី រាជរដ្ឋាភិបាលបានប្រទានកម្មដីនេះទៅឱ្យគ្រួសារចំនួន១.៧៩១គ្រួសាររស់នៅក្នុងភូមិជ្រោះជ្រៅពោធិសាល ដែលមានផ្ទៃដីសរុប៦៩៩៨ហិកតា។ អាជ្ញាធរមូលដ្ឋានបានអះអាងថា៧០-៨០% នៃអ្នកភូមិរស់នៅក្នុងភូមិជ្រោះជ្រៅពោធិសាលជាប្រជាពលរដ្ឋដែលចំណាកស្រុកមកពីខេត្តកំពង់ចាម ព្រៃវែង ស្វាយរៀង និងខេត្តផ្សេងៗទៀត។ បន្ទាប់ពីទទួលបានបណ្ណកម្មសិទ្ធិដីធ្លីពីរាជរដ្ឋាភិបាលតាមរយៈការអន្តរាគមន៍ពីបទបញ្ជា០១បប អ្នកភូមិមួយចំនួនបានខ្ចីលុយពីស្ថាប័នមីក្រូហិរញ្ញវត្ថុដើម្បីវិនិយោគដំណាំកសិកម្ម

[28] Sub decree #01 ANKR BK on 01 Jan 2013

[29] Provincial Forestry Administration of Kratie, forestry management planning 2015-2019, p53

[30] Result of commune consultative meeting with local authority and district office at Pithnou commune, 25 Mar 2017.

របស់ពួកគាត់ ដូចជា ស្វាយចន្ទី កៅស៊ូ ម្រេច និងអំពៅ។




រូបថត៤.១:សម្បទានទានដីសេដ្ឋកិច្ចដែលបាននិរាសករណ៍នៅភូមិជ្រោះជ្រៅពោធិសាល ឃុំ២ធ្នូ

ជាអនុសល្យ ប្រជាជនបានបរាជ័យក្នុងការដាំដុះដំណាំកសិកម្មដោយសារតែរាំងស្ងួត មិនមានការគាំទ្របច្ចេកទេសកសិកម្ម និងតម្លៃទីផ្សារកសិផលទាប។ អ្នកភូមិមិនអាចរកចំណូលពីដំណាំកសិកម្មរបស់ពួកគាត់ដើម្បីសងបំណុលមីក្រូហិរញ្ញវត្ថុបានទេ។ គ្រួសារខ្លះបានសម្រេចចិត្តធ្វើចំណាកស្រុកទៅប្រទេសជិតខាង និងតំបន់ផ្សេងៗដើម្បីស្វែងរកប្រាក់ចំណូល។ កំឡុងពេលចុះសិក្សាទីវាល និងសម្ភាសជាមួយអ្នកភូមិនៅទីនោះ ពួកគាត់ហាក់ដូចជាមានការភ័យខ្លាច និងមិនមានជំហរឹងមាំក្នុងការផ្តល់ព័ត៌មានពាក់ព័ន្ធនឹងទំនាស់ដីធ្លី ការកាន់កាប់ដី លក្ខណៈនៃការកាប់ព្រៃឈើ និងការកាន់កាប់ដីធ្លី និងដំណើរការសម្បទានដីសេដ្ឋកិច្ច។ យោងតាមប្រសាសន៍របស់អ្នកភូមិ ភាគច្រើននៃដី និងផ្ទះរបស់អ្នកភូមិជ្រោះជ្រៅពោធិសាល បានលក់ក្នុងតម្លៃពី៥.០០០ ទៅ១០.០០០ដុល្លាអាមេរិច/ហិកតា។ វាហាក់ដូចជាមានអ្វីនៅខាងក្រោយនៃការកាន់កាប់ដីស្របច្បាប់នេះ ពីព្រោះមិនមានមនុស្សច្រើនរស់នៅទីនោះទេ កំឡុងពេលចុះសិក្សានៅទីវាល។ យោងតាមពុទ្ធដីកាព្រះសង្ឃមួយអង្គគង់ចាំនៅវត្តពោធិសាលលើកឡើងថា "*ភាគច្រើននៃម្ចាស់ដី ឬអ្នកកាន់កាប់ដីធ្លីនៅក្នុងភូមិពោធិសាលនេះមកពីស្រុក និងខេត្តផ្សេងៗ។ ពួកគាត់សុទ្ធតែមានអ្នកនៅពីក្រោយខ្នងដែលជាជនមានអំណាច។ អ្នកភូមិខ្លះបានទទួលដីតែសម្រាប់លក់ មិនមែនសម្រាប់ការប្រកបមុខរបរចិញ្ចឹមជីវិតនោះទេ*"។




រូបថត ៣.២៖ វត្តថ្មីដែលមានទីតាំងស្ថិតនៅក្នុងអតីតដីក្រុមហ៊ុន ហួត សម្បត្តិ ដែលបានទទួលបានបណ្ណកម្មសិទ្ធ៦,៣ហិកតា

**ការតស៊ូមតិ និងជីវភាពរបស់សហគមន៍**

សហគមន៍ចាប់ផ្តើមតស៊ូមតិប្រឆាំងនឹងក្រុមហ៊ុនសម្បទានមុនពេលចេញបទបញ្ជា០១បប។ ក្នុងកំឡុងឆ្នាំ ២០០៩-២០១២ សហគមន៍បានប្រមូលផ្តុំគ្នាជាច្រើនដងដើម្បីការពារដីរបស់គាត់ និងព្រៃឈើ។ សហគមន៍បានធ្វើពិធីបន់ស្រន់ ដាក់បណ្តឹងទៅអាជ្ញាធរ និងជួនកាលមានអំពើហឹង្សាកើតឡើងផងដែរ។ ស្របពេលនេះដែរ សហគមន៍បានព្យាយាមកាប់ឆ្ការព្រៃលើដីដែលគាត់កាន់កាប់ឱ្យបានយ៉ាងឆាប់តាមដែលអាចធ្វើទៅបាន។ គ្រួសារដែលមានសមាជិកច្រើនអាចកាប់ឆ្ការព្រៃបានរហូតដល់១០ហិកតា ខណៈដែលគ្រួសារតូចអាចកាប់ឆ្ការបានប្រហែល៣ទៅ៥ហិកតា។ យោងលើពុទ្ធដីកាព្រះសង្ឃថា ទីកន្លែងដែលសហគមន៍បាននាំគ្នាប្រមូលផ្តុំដើម្បីបន់ស្រន់ និងធ្វើយុទ្ធនាការតស៊ូមតិបានក្លាយជាវត្ត ដោយសារពួកគាត់មានជំនឿលើព្រះពុទ្ធដែលជួយដល់ពួកគាត់។

អនុលោមតាមអនុក្រឹត្យលេខ០១ អនក្រ បក ចុះថ្ងៃទី០១ ខែមករា ឆ្នាំ២០១៣ រាជរដ្ឋាភិបាលបានសម្រេចកាត់បន្ថយទំហំផ្ទៃដីក្រុមហ៊ុន ហួត សម្បត្តិ សរុប៤.៩៩៨,១៣ហិកតាដើម្បីធ្វើប្រទានកម្មទៅគ្រួសារចំនួន១៧៩៩ គ្រួសារនៅក្នុងភូមិជ្រោះជ្រៅ ដែលរួមទាំងវត្តអារាមចំនួន០២ផងដែរ។ ដីដែលនៅសល់បន្ទាប់ពីកាត់បន្ថយទំហំផ្ទៃដី ត្រូវបានរក្សាទុកជាដីសាធារណៈរបស់រដ្ឋ។ បច្ចុប្បន្ននេះ សហគមន៍ដែលកំពុងរស់នៅទីនោះបានទទួលបណ្ណកម្មសិទ្ធិដីធ្លីពីមន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ខេត្តក្រចេះ តាមរយៈបទបញ្ជាលេខ០១បប។ ពីរបីឆ្នាំក្រោយមក ការនិរាសករណ៍សម្បទានដីសេដ្ឋកិច្ចបានកែលម្អជីវភាពរស់នៅរបស់ប្រជាជនដោយបានបង្កើននូវប្រាក់ចំណូលតាមរយៈដំណាំកសិឧស្សាហកម្ម ដូចជា ស្វាយចន្ទី កៅស៊ូ អំពៅ ម្រេច និងអាជីវកម្មខ្នាតតូច។





រូបថត៣.៣ ៖ ចំការម្រេច និងស្វាយចន្ទីរបស់កសិករតូចតាចបន្ទាប់ពីនិរាសករណ៍សម្បទានដីសេដ្ឋកិច្ច(ក្រុមហ៊ុន ហួតសម្បត្តិ)

## ៧.២ ចំនួនសម្បទានដីសេដ្ឋកិច្ចដែលកំពុងប្រតិបត្តិការនៅក្នុងប្រទេសកម្ពុជា និងករណីទំនាស់ដីធ្លីដែលបានកើតឡើង

រហូតមកដល់ឆ្នាំ២០១៧នេះ មានក្រុមហ៊ុន ចំនួនពី២២៩ ទៅ២៣០ បានទទួលសម្បទានដីសេដ្ឋកិច្ច និងបានចុះកិច្ចព្រមព្រៀងជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (រួមបញ្ចូលនូវក្រុមហ៊ុនសម្បទានដែលស្ថិតនៅក្រោមដែនសមត្ថកិច្ចក្រសួងបរិស្ថាន)។ សរុបទំហំផ្ទៃដីសម្បទានទាំងអស់ច្រើនជាង១,៥០លានហិកតា (បន្ទាប់ពីនិរាសករណ៍ក្រុមហ៊ុនសម្បទានចំនួន៣៥) ដែលមានទីតាំងស្ថិតនៅក្នុងខេត្តចំនួន១៨ (មន្ត្រីក្រសួងកសិកម្មលើកឡើងឆ្នាំ

២០១៦)។ យោងតាមរបាយការណ៍ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទផ្ញើជូនទៅអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សកម្ពុជា(OHCHR) កាលពីខែឧសភា ឆ្នាំ២០១៧ បង្ហាញថា ទំហំផ្ទៃសម្បទានដីសេដ្ឋកិច្ចដែលបានដែលបានឈូសឆាយរួចមានទំហំ ៥០៤.៦៥៨ ហិកតា បានដាំដុះចំនួន៤៣០.៦៣១ហិកតា (ប្រហែល២៨,១៤%នៃផ្ទៃដីសម្បទានសរុប) ផ្តល់ការងារជាកម្មករខ្មែរមាន១៣.០៦៥នាក់ ជនបរទេសមាន ១៧៦៦នាក់ បុគ្គលិកខ្មែរ ១៣.៤៧០នាក់ និងតម្រូវការកម្មករតាមរដូវកាលមាន ២០.៨០៤នាក់។ សូមមើលតារាងបច្ចុប្បន្នភាពក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចដែលបានកែសម្រួល និងរៀបចំដោយក្រុមការងារអ្នកស្រាវជ្រាវនៅក្នុងឧបសម្ព័ន្ធ១។

### ៧.២.១ ទស្សនៈរបស់សហគមន៍មូលដ្ឋានលើការនិរាសករណ៍សម្បទានដីសេដ្ឋកិច្ច

បើពិនិត្យមើល សេចក្តីជូនដំណឹង(សជណ)ឆ្នាំ២០១៥ទាំងអស់ ក្នុងលិខិតបញ្ជាក់មិនបានបង្ហាញអំពីមូលហេតុដែលឈានដល់ការនិរាករណ៍ការកាត់បន្ថយទំហំ និងការបង្វែរសម្បទានដីសេដ្ឋកិច្ចនោះទេ។ មន្ត្រីរដ្ឋាភិបាលថ្នាក់ជាតិបានលើកឡើងថា "*ការនិរាសករណ៍សម្បទានដីសេដ្ឋកិច្ចជាលទ្ធផលនៃការវាស់វែងនិងវាយតម្លៃពីគណៈកម្មាធិការអន្តរក្រសួង អនុលោមតាមអនុសាសន៍របស់រាជរដ្ឋាភិបាលកម្ពុជា និងដោយសារតែក្រុមហ៊ុនមិនគោរពតាមច្បាប់ជាធរមានរបស់ប្រទេសកម្ពុជា*"។ ម្យ៉ាងវិញទៀត ព័ត៌មានអំពីក្រុមហ៊ុនសម្បទានដែលបាននិរាសករណ៍រួចហើយនៅតែមិនទាន់ច្បាស់ ថាតើពួកគេនៅតែបន្តប្រតិបត្តិការ ឬឈប់ហើយ? ករណីសិក្សាពីរក្នុងចំណោមបួនខាងលើបានបង្ហាញថាពួកគេនៅតែបន្តសកម្មភាពវិនិយោគរបស់គេលើដីដែលបាននិរាករណ៍ប៉ុន្តែមិនបានពង្រីកផ្ទៃដីដាំដុះទៅទីកន្លែងផ្សេងទៀតនោះទេ។ ទាក់ទងនឹងករណីទំនាស់ដីធ្លីនៅក្នុងខេត្តឧត្តរមានជ័យ រដ្ឋាភិបាលថ្នាក់ក្រោមជាតិនៅតែមិនអនុញ្ញាតឱ្យសហគមន៍ដែលរងផលប៉ះពាល់ដើម្បីទទួលបានអតីតដីកសិកម្មរបស់ពួកគាត់នោះទេ បើទោះបីជាក្រុមហ៊ុនសម្បទាន អង្គរស៊ូហ្គើរ ទន្លេស៊ូហ្គើរ និងស៊ូហ្គើរ អែនខេន ត្រូវបាននិរាសករណ៍ដោយរដ្ឋាភិបាលក៏ដោយ។ ករណីនៅខេត្តស្ទឹងត្រែង ក្រុមហ៊ុនបានផ្ទេរ ជួល ឬកាត់បន្ថយទំហំផ្ទៃដីសម្បទាន ទៅឱ្យក្រុមហ៊ុនវៀតណាមដើម្បីដាំដំណាំស្វាយចន្ទី។ នៅខេត្តក្រចេះ ដីក្រុមហ៊ុនសម្បទាន ហួត សម្បត្តិ ដែលបាននិរាសករណ៍ត្រូវបានធ្វើអនុបយោគជាដីសម្បទានសង្គមកិច្ចដើម្បីប្រទានកម្មជូនពលរដ្ឋចំនួន១៧៩៩គ្រួសារ។

អនុលោមតាមលិខិតរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទទៅនាយករដ្ឋមន្ត្រីអំពីលទ្ធផលនៃការវាយតម្លៃសម្បទានដីសេដ្ឋកិច្ច មានមូលហេតុមួយចំនួនដែលធ្វើឱ្យក្រសួងកសិកម្មសម្រេចនិរាសករណ៍សម្បទានដីសេដ្ឋកិច្ចដែលស្ថិតនៅក្រោមដែនសមត្ថកិច្ចក្រសួងកសិកម្មដោយសារ មិនមានភាពសកម្ម និងមិនអនុវត្តកាតព្វកិច្ចតាមកិច្ចព្រមព្រៀង និងផែនការមេ ការចូលរួមប្រព្រឹត្តបទល្មើសព្រៃឈើ ការទន្ទ្រានយកដីនៅក្នុងតំបន់ដីសម្បទាន ជាដើម។




ក្រាហ្វិច ៧.២.១៖ ទស្សនៈរបស់សហគមន៍មូលដ្ឋានលើមូលហេតុដែលនាំឱ្យនិរាសករណ៍សម្បទានដីសេដ្ឋកិច្ចនៅកម្ពុជា

ទោះបីយ៉ាងណាក៏ដោយ ភាគច្រើនបំផុតនៃអ្នកឆ្លើយតប មិនបានដឹងអំពីមូលហេតុដែលនាំឱ្យមានការនិរាសករណ៍សម្បទានដីសេដ្ឋកិច្ចនៅក្នុងប្រទេសកម្ពុជានោះទេ។ ៤៦%នៃអ្នកឆ្លើយតបមិនបានដឹងអំពីព័ត៌មាននៃនិរាសករណ៍សម្បទានដីសេដ្ឋកិច្ច។ សហគមន៍ខ្លះបានលើកឡើងថា *"ខ្ញុំអត់ដឹងអ្វីទាំងអស់.......ពួកគេមិនដែលចែករំលែកព័ត៌មានណាមួយអំពីសម្បទានដីសេដ្ឋកិច្ចជាមួយសហគមន៍នោះទេ...........គ្មានប្រភពព័ត៌មាន"* ខណៈដែលសហគមន៍រងផលប៉ះពាល់ខ្លះប្រហែលជា២៤%នៃអ្នកឆ្លើយតបបានគិតថា បញ្ហាទំនាស់ដីធ្លីជាមូលហេតុចម្បងនៃការនិរាករណ៍សម្បទានដីសេដ្ឋកិច្ច។ សហគមន៍ខ្លះបានលើកឡើងថា *"ភាគច្រើនក្រុមហ៊ុនមិនគោរពសិទ្ធិរបស់សហគមន៍មូលដ្ឋានដើម្បីចូលទៅកេធនធានធម្មជាតិដែលជាប្រភពចំណូល និងជីវភាពប្រចាំថ្ងៃ...........ពួកគេតែងតែរំលោភយកដីធ្លីរបស់អ្នកភូមិដែលកំពុងរស់នៅជុំវិញដីសម្បទាន .......ដោយសារតែជម្លោះដីធ្លីជាមួយសហគមន៍"* និង១១%ផ្សេងទៀតបាននិយាយថា *"ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចមិនអនុវត្ត/គោរពច្បាប់ប្រទេសកម្ពុជាដោយរួមទាំងបានចូលរួមបទល្មើស ព្រៃឈើផងដែរ"*។

## ៧.២.២ ទំនាស់ដីធ្លី និងជីវភាពរបស់សហគមន៍

ផ្ទៃដីសម្បទានសរុបទាំងមូលមានចំនួន១,៥លានហិកតា(១០-១២%នៃផ្ទៃដីទាំងមូលរបស់ប្រទេសកម្ពុជា)។ ភាគច្រើននៃទីតាំងសម្បទានដីសេដ្ឋកិច្ចស្ថិតនៅក្នុងតំបន់ព្រៃឈើ។ ការកែប្រែដីព្រៃឈើទៅជាដីសម្រាប់ដាំដុះដំណាំ កសិ-ឧស្សាហកម្ម ផ្តល់ផលប្រយោជន៍តិចតួចណាស់ដល់ អេកូឡូស៊ី ជីវៈចម្រុះ តម្លៃបរិស្ថាន និងសង្គម។ សហគមន៍ដែលមានជីវភាពរស់នៅពឹងផ្អែកទាំងស្រុងលើផលអនុផលព្រៃឈើ និងធនធានធម្មជាតិតែងតែប្រឈមនឹងជម្លោះជាមួយក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច។ ក្រាហ្វិចបង្ហាញថា ៧៤%នៃអ្នកឆ្លើយតបធ្លាប់មានជម្រោះជាមួយក្រុមហ៊ុនសម្បទាន។

*"ពួកគេ(ក្រុមហ៊ុនសម្បទាន) មិនខ្វល់នឹងវប្បធម៌របស់យើង ពួកគេចង់ប្រមូលព្រៃឈើ មិនមែនវិនិយោគនោះទេ ពួកគេបានឈូសឆាយដោយគ្មានការពិគ្រោះយោបល់ជាមួយយើង ការវិនិយោគរបស់ពួកគេមិនត្រឹមតែមិនបានផ្តល់ផលប្រយោជន៍ដល់យើងទេ ប៉ុន្តែថែមទាំងរំលោភយកដី និងព្រៃឈើរបស់ពួកយើងទៀត"* ក្រុមសហគមន៍ដែលបានលើកឡើងកំឡុងពេលពិគ្រោះយោបល់នៅខេត្តស្ទឹងត្រែង។




ក្រាហ្វិច៧.២.២ ចំនួនករណីជម្លោះដីធ្លីរវាងសហគមន៍ និងក្រុមហ៊ុនសម្បទាន

ទាក់ទងនឹងការត្អូញត្អែររបស់សហគមន៍ខាងលើ អាជ្ញាធរខេត្ត និងអាជ្ញាធរមូលដ្ឋាន មិនឯកភាពជាមួយទស្សនៈរបស់សហគមន៍នោះទេ។អាជ្ញាមូលដ្ឋានបានបញ្ជាក់ថា*"ភាគច្រើនសហគមន៍បានកាន់កាប់ដីខុសច្បាប់លើដីសាធារណៈរបស់រដ្ឋនិងដីឯកជនរបស់រដ្ឋដែលរដ្ឋាភិបាលបានផ្តល់ទៅឱ្យក្រុមហ៊ុនសម្បទាន"*។ មុនពេលនិរាសករណ៍សម្បទានដីសេដ្ឋកិច្ច ៣១%នៃអ្នកឆ្លើយតបបានលើនិយាយថា សហគមន៍ធ្លាប់មានជម្លោះដីធ្លីជាមួយក្រុមហ៊ុនសម្បទានប្រមាណជា៧ទៅ១០ដង ខណៈដែល១៦%នៃអ្នកឆ្លើយតបថា មានជម្លោះប្រហែល៤ទៅ៦ដង។

## ៧.៣ ឥទ្ធិពលនៃការនិរាសករណ៍សម្បទានដីសេដ្ឋកិច្ចលើជីវភាពសហគមន៍មូលដ្ឋាន

អនុលោមតាមគោលបំណងនៃអនុក្រឹត្យលេខ១៤៦ មាត្រា៣ បានលើកឡើងថា "[……..] ដើម្បីបង្កើនភាពមានការងារនៅជនបទនៅក្នុងក្របខ័ណ្ឌនៃពិពិធកម្ម និងពិពិធភាវូនីយកម្មកសិកម្ម និងការធ្វើឱ្យមានកាលានុវត្តភាពជីវភាពរស់នៅ និងនៅក្នុងក្របខ័ណ្ឌនៃការគ្រប់គ្រងធនធានធម្មជាតិផ្អែកលើប្រព័ន្ធអេកូឡូស៊ីដែលសមស្រប[…..]"។ ដូចដែលបានពិពណ៌នាខាងលើ សម្បទានដីសេដ្ឋកិច្ចចំនួន៣៥ក្រុមហ៊ុនត្រូវបាននិរាសករណ៍ដោយរាជរដ្ឋាភិបាលកម្ពុជាដោយសារហេតុផលដូចជា មិនគោរពច្បាប់ មិនបានបំពេញតាមលក្ខ័ណ្ឌនៃច្បាប់ ចូលរួមចំណែកបទល្មើសព្រៃឈើ ជម្លោះដីធ្លី គ្មានឆន្ទៈក្នុងការវិនិយោគ បង្វិលដីមកឱ្យរដ្ឋវិញ ជាដើម។ ពីរបីឆ្នាំក្រោយការនិរាសករណ៍សម្បទានដីសេដ្ឋកិច្ច មិនមានព័ត៌មានណាមួយលើស្ថានភាពនៃជីវភាពរស់នៅរបស់ពលរដ្ឋជុំវិញតំបន់សម្បទានដីសេដ្ឋកិច្ចនោះទេ។

ការសិក្សានេះបានបញ្ចូលនូវទស្សនៈផ្សេងៗរបស់អ្នកពាក់ព័ន្ធដែលទទួលបានកំឡុងពេលធ្វើការសម្ភាសន៍ ការ

ពិគ្រោះយោបល់ និងពិភាក្សាកម្រិតឃុំ បញ្ជីសំណួរសង្កេតសម្រាប់គ្រួសារ។ ជាលទ្ធផលនៃការសម្ភាសន៍អ្នកផ្តល់ព័ត៌មានសំខាន់ៗ ការពិគ្រោះយោបល់ជាមួយសហគមន៍រងគ្រោះ និងអាជ្ញាធរមូលដ្ឋានបានបង្ហាញថា សហគមន៍ដែលរស់នៅជុំវិញតំបន់សម្បទានដីសេដ្ឋកិច្ចគឺជាគ្រួសារដែលងាយរងគ្រោះ និងមានជីវភាពក្រីក្រ។ ជម្លោះដីធ្លី និងការប្រើប្រាស់ធនធានព្រៃឈើបានកើនឡើងរវាងសហគមន៍ និងក្រុមហ៊ុនសម្បទាននៅក្នុងតំបន់សិក្សា។ ការឈូសឆាយដី និងបទល្មើសព្រៃឈើនៅក្នុងតំបន់សម្បទានបានកើនឡើងគួរឱ្យកត់សម្គាល់ ពិសេសនៅពេលកណ្តាលយប់។ អនុក្រឹត្យលេខ១៤៦ តម្រូវឱ្យក្រុមហ៊ុនសម្បទានទាំងអស់ធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមមុនពេលឈូសឆាយដីសម្បទានសេដ្ឋកិច្ច និងព្រៃឈើនៅក្នុងតំបន់ដីសម្បទាន។ ការអនុវត្តជាក់ស្តែង ក្រុមហ៊ុនសម្បទានខ្លះបានធ្វើការសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមកំឡុងពេលប្រតិបត្តការគម្រោង។ ករណីខ្លះ សម្បទានិកបានប្រតិបត្តិការឈូសឆាយដីនិងតំបន់ព្រៃឈើដោយគ្មានការធ្វើរបាយការណ៍ EIA គ្មានអនុបយោគ គ្មានផែនការមេ សំណង និងឯកសារផ្លូវច្បាប់ដទៃទៀតដើម្បីគាំទ្រដល់ការវិនិយោគរបស់ពួកគេ។ នេះជាការខ្វះចន្លោះដ៏ធំក្នុងការអភិវឌ្ឍន៍សម្បទានដីសេដ្ឋកិច្ចនៅក្នុងប្រទេសកម្ពុជា ដែលនាំឱ្យជះឥទ្ធិពលដល់ជីវភាពរស់នៅរបស់ពលរដ្ឋដែលរស់នៅជុំវិញទីតាំងគម្រោ។ ជាលទ្ធផលនៃការពិភាក្សា និងសម្ភាសន៍ជាមួយសហគមន៍រងផលប៉ះពាល់ក្នុងករណីសិក្សាចំនួន៤បង្ហាញថា សហគមន៍មិនមានឱកាសចូលរួមពិគ្រោះយោបល់ជាសាធារណៈ មិនអាចទទួលបានព័ត៌មានអំពីការវិនិយោគ មិនបានទទួលសំណង មិនមានការពិភាក្សាពេញលេញ ប៉ុន្តែបានទទួលរងគ្រោះយ៉ាងធ្ងន់ធ្ងរពីការរំលោភយកដីធ្លី និងការរំលោភសិទ្ធិមនុស្ស។

ការវិនិយោគដែលមិនសមស្របបានបណ្តាលឱ្យបាត់បង់ដី និងធនធានធម្មជាតិដែលជាប្រភពធនធានសម្រាប់ទ្រទ្រង់ជីវភាពរស់នៅរបស់សហគមន៍ ពិសេសជនជាតិដើមភាគតិច។ ករណីសិក្សាចំនួន៤ខាងលើបានឆ្លុះបញ្ចាំងអំពីក្រុមហ៊ុនសម្បទានដែលបាននិរាសករណ៍មិនមានតម្លៃផ្នែកបរិស្ថាន និងអេកូឡូស៊ី ពីព្រោះក្រុមហ៊ុនបានឈូសឆាយគ្មានសល់អ្វីទាំងអស់មុនពេលបង្វិលដីត្រឡប់មករដ្ឋវិញ និងនិរាសករណ៍ដោយរដ្ឋាភិបាល។

ខេត្តរតនៈគីរី សហគមន៍ចារ៉ាយនិយាយថា "......ពួកគេបានឈូសឆាយអស់រលីងដោយគ្មានពិគ្រោះយោបល់ជាមួយពួកយើង.......ពួកគេរំលោភយកព្រៃឈើរបស់យើងដែលជាទីកន្លែងរកអាហារប្រចាំថ្ងៃ និងការធ្វើកសិកម្មប្រពៃណី.........."។

មន្ត្រីរដ្ឋាភិបាលថ្នាក់ជាតិនិយាយថា "..... ពួកគេមិនបានផ្តល់ព័ត៌មានលម្អិត និងឯកសារផ្លូវច្បាប់នៃការវិនិយោគដល់យើង.......ពួកគេព្យាយាមពន្យាពេលដាំដុះម្តងហើយ ម្តងទៀត...........ពួកគេគ្មានឆន្ទៈក្នុងការវិនិយោគដំណាំនោះទេ"។

មន្ត្រីរដ្ឋាភិបាលខេត្តរតនៈគីរី "..............ខ្ញុំមិនដឹងព័ត៌មានលម្អិតរបស់ក្រុមហ៊ុននេះទេ តែខ្ញុំតែងតែចូលរួមដំណើរការត្រួតពិនិត្យ វាយតម្លៃ និងត្រួតពិនិត្យក្រុមហ៊ុនសម្បទាន.......ខ្ញុំមិនដឹងអ្វីទាំងអស់ទាក់ទងនឹងដំណើរការធ្វើសេចក្តីសម្រេចិត្ត...........គ្រប់យ៉ាងអាស្រ័យលើការសម្រេចចិត្តរបស់រដ្ឋាភិបាលថ្នាក់ជាតិ......."។

សហគមន៍ខេត្តស្ទឹងត្រែងនិយាយថា "ខ្ញុំអត់ដឹងព័ត៌មានអ្វីទាំង..........ខ្ញុំឃើញក្រុមហ៊ុនបិទផ្លូវឆ្លងកាត់តំបន់ដី

សម្បទានសេដ្ឋកិច្ចដែលតភ្ជាប់ទៅផ្លូវជាតិលេខ៧...........ខ្ញុំពិបាកទៅផ្សារ ទៅមណ្ឌលសុខភាព សាលារៀន.....” សហគមន៍ផ្សេងទៀតលើកឡើងថា “........ពួកគេបិទផ្លូវដើម្បីកាប់ឈើ មិនមែនសម្រាប់ដាំកៅស៊ូនោះទេ...........”។

សហគមន៍នៅខេត្តក្រចេះនិយាយថា “.......ខ្ញុំព្យាយាមតស៊ូមតិជាមួយសហគមន៍ផ្សេងៗរហូតទទួលបានដីមកវិញ........ខ្ញុំបានការគាំទ្រពីអាជ្ញាធរខេត្ត និងមូលដ្ឋានដើម្បីទទួលបានបណ្ណកម្មសិទ្ធិដីធ្លី តាមរយៈបទបញ្ជាលេខ០១បប ជីវភាពរបស់ខ្ញុំកាន់តែប្រសើរឡើង និងមានការប្រែប្រួលបើប្រៀបធៀបនឹងពីមុន........ពីព្រោះខ្ញុំជាម្ចាស់កម្មសិទ្ធលើដីនេះ ខ្ញុំអាចដាំដុះដំណាំកសិកម្ម និងកសិ ឧស្សាហកម្មដើម្បីបង្កើនប្រាក់ចំណូល.......”។

ព្រះសង្ឃមួយអង្គដែលតែងតែសង្កេតមើលការតស៊ូមតិរបស់សហគមន៍បានលើកឡើងថា “.........សហគមន៍សប្បាយចិត្តណាស់ដែលទទួលបានបណ្ណកម្មសិទ្ធិ និងអាចរកប្រាក់ចំណូលបន្ថែមតាមរយៈការធ្វើកសិកម្ម ការលក់ដីទៅអ្នកមានទ្រព្យសម្បត្តិដែលមកពីភ្នំពេញ និងខេត្តផ្សេងៗ.........”។ ព្រះអង្គបន្ថែមថា “.........ពួកគាត់បានខ្ចីប្រាក់ពីមីក្រូហិរញ្ញវត្ថុដើម្បីធ្វើកសិពាណិជ្ជកម្ម ប៉ុន្តែពួកគាត់បានបរាជ័យដោយសាររាំងស្ងួត កង្វះបច្ចេកទេស និងមិនមានការគាំទ្របច្ចេកទេសពីមន្ទីរជំនាញ.........”។

សហគមន៍នៅខេត្តឧត្តរមានជ័យបានលើកឡើងថា “.......អាជ្ញាមូលដ្ឋានបានផ្តល់ដីសង្គមកិច្ចមកពួកយើងដោយគ្មានលក្ខ័ណ្ឌដើម្បីសាងសង់ផ្ទះ និងធ្វើស្រែចំការ.......ពីរបីឆ្នាំក្រោយមក ក្រុមហ៊ុន អង្គរស៊ូហ្គើរ បានចូលមក និងរំលោភយកដីរបស់ពួកយើងដោយគ្មានការពិគ្រោះយោបល់ ហើយមានការគាំទ្រដោយអាជ្ញាធរមូលដ្ឋានទៀត.......”។ សហគមន៍ផ្សេងទៀតបាននិយាយថា “.........ពួកគេមិនឱ្យយើងប្រមូលផលស្រូវសិនទេ ពួកគេបានដុតផ្ទះរបស់យើង និងចាប់ខ្លួនពួកយើង.......ជីវភាពរបស់ពួកយើងកាន់តែធ្លាក់ធ្ងន់ធ្ងរ និងក្រីក្រឡើង ស្ត្រីម្នាក់ដែលមានផ្ទៃពោះត្រូវបានកាត់ទោសឱ្យជាប់គុក ដោយសារតែគាត់ការពារដីរបស់គាត់.......”។ សហគមន៍ប្រមាណជា១០០គ្រួសារត្រូវអត់ផ្ទះសំបែង ហើយសម្រេចចិត្តចំណាកស្រុកទៅប្រទេសថៃដើម្បីស្វែងរកប្រាក់ចំណូលទ្រទ្រង់ជីវភាពប្រចាំថ្ងៃ។ សហគមន៍រងផលប៉ះពាល់អស់សង្ឃឹមយ៉ាងខ្លាំងចំពោះការទទួលបានដី និងផ្ទះត្រឡប់មកវិញដោយសារពុំមានវិធានការណាមួយពីរដ្ឋាភិបាលថ្នាក់ជាតិ។ សហគមន៍បានព្យាយាមដាក់ពាក្យបណ្តឹងទៅសាលាដំបូងខេត្ត ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងទីស្តីការគណៈរដ្ឋមន្ត្រី ប៉ុន្តែមិនមានវិធានការច្បាប់ណាមួយចំពោះក្រុមហ៊ុននេះទេ។

រហូតមកដល់ពេលនេះ សហគមន៍នៅតែមិនមានដីប្រើប្រាស់ និងមិនទាន់បានដីមកវិញ បើទោះបីជារដ្ឋាភិបាលបានទទួលយកដីដែលក្រុមហ៊ុនបានប្រគល់មកវិញក៏ដោយ។ មន្ត្រីរដ្ឋាភិបាលថ្នាក់ជាតិបានលើកឡើងថា “.......វានៅតែមិនទាន់ច្បាស់លាស់អំពីជំហានបន្តចំពោះដីសម្បទានដែលបានិរាសករណ៍នៅកម្ពុជា ប៉ុន្តែ......វាប្រហែលជាកែប្រែទៅជាដីសម្បទានសង្គមកិច្ច ដីសម្រាប់ស្តារព្រៃឈើ និងតំបន់អាទិភាពផ្សេងៗទៀតរបស់រដ្ឋាភិបាល...... ទោះបីយ៉ាងណាក្រុមការងារសម្បទានដីសេដ្ឋកិច្ចនឹងបន្តពិនិត្យការអនុវត្តសម្បទានដីសេដ្ឋកិច្ចផ្សេងៗទៀត”។

ផ្អែកលើករណីសិក្សាទាំងបួន និងការសម្ភាសន៍ជាមួយអ្នកផ្តល់ព័ត៌មានសំខាន់ៗ ការនិរាសករណ៍សម្បទានដីសេដ្ឋកិច្ចមិនបានចូលរួមចំណែកច្រើនដល់ការកែលម្អជីវភាពរស់នៅរបស់ប្រជាជនមូលដ្ឋាន ការកាន់កាប់ដី និងប្រាក់ចំណូល ពីព្រោះភាគច្រើននៃសហគមន៍ពឹងផ្អែកលើធនធានធម្មជាតិ និងព្រៃឈើ។ ការនិរាសករណ៍សម្បទានដីសេដ្ឋកិច្ចមិន

បានផ្តល់តម្លៃផ្នែកបរិស្ថាន និងអេកូឡូស៊ីសម្រាប់ប្រាក់ចំណូលរបស់សហគមន៍នោះទេ។ បញ្ហាផ្សេងទៀត រដ្ឋាភិបាលហាក់ដូចជាមិនទាន់មានផែនការជាក់លាក់នៅឡើយសម្រាប់ដីដែលបានមកពីនិរាសករណ៍ទាំងនេះទេ។ រហូតមក ដល់ពេលនេះ អាជ្ញាធរខេត្ត មន្ទីរជំនាញ និងសហគមន៍មូលដ្ឋានបានយល់អំពីយន្តការរបស់រដ្ឋាភិបាលថ្នាក់ជាតិសម្រាប់ផែនការនិរាសករណ៍សម្បទានដីសេដ្ឋកិច្ចនៅពេលអនាគត។ ទោះជាយ៉ាងណា ក្រសួងកសិកម្មបានបង្កើតក្រុមការងារដើម្បីត្រួតពិនិត្យ និងវាយតម្លៃសម្បទានដីសេដ្ឋកិច្ចដែលបាននិរាសករណ៍រួចហើយទូទាំងប្រទេស និងលើកជាអនុសាសន៍ដើម្បីកែលម្អនៅពេលអនាគត។

### ៧.៨ សំណូមពររបស់សហគមន៍ចំពោះរាជរដ្ឋាភិបាលសម្រាប់សម្បទានដីសេដ្ឋកិច្ចដែលបាននិរាសករណ៍បច្ចុប្បន្ន

នៅថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០១៧[31] ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានបង្កើតក្រុមការងារមួយដែលដឹកនាំដោយរដ្ឋលេខាធិការ និងមន្ត្រីជាន់ខ្ពស់ពីរដ្ឋបាលព្រៃឈើជាសមាជិកដើម្បីចុះសិក្សាអង្កេត និងវាយតម្លៃទិតាំងសម្បទានដីសេដ្ឋកិច្ចដែលបាននិរាសករណ៍។ អាណត្តការងាររបស់ក្រុមការងារនេះគឺសម្របសម្រួលជាមួយអាជ្ញាធរខេត្តដែលពាក់ព័ន្ធដើម្បីពិនិត្យ វាយតម្លៃ ធ្វើផែនទី បោះបង្គោលព្រំ អនុបយោគ និងចុះបញ្ជីដីរដ្ឋ និងរាយការណ៍ដោយមានអនុសាសន៍ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទដើម្បីអភិវឌ្ឍន៍ និងស្តារព្រៃឈើឡើងវិញនៅពេលអនាគត។

[31] MAFF, decision #115 SSR, on 06 February 2017.




ក្រាហ្វិច៧.៤.១៖ សំណូមពររបស់សហគមន៍រងផលប៉ះពាល់លើការកែប្រែសម្បទានដីសេដ្ឋកិច្ចដែលបាននិវាសករណ៍សម្រាប់ពេលអនាគត

អនុលោមតាមការសម្ភាសជាមួយប្រជាជនរងគ្រោះនៅក្នុងខេត្តចំនួន០៤ បង្ហាញថា ១៥-២២%នៃអ្នកឆ្លើយតបក្នុងខេត្តស្ទឹងត្រែង និងឧត្តរមានជ័យបានស្នើសុំប្រគល់អតីតដីរបស់គាត់មកវិញដោយគ្មានលក្ខណ្ឌដើម្បីបន្តការដាំដុះដំណាំកសិកម្ម និងជម្រើសមុខរបរសម្រាប់ជីវភាពរស់នៅ។ អ្នកឆ្លើយតបផ្សេងទៀតចំនួន៨-១៨% នៅក្នុងខេត្តក្រចេះ និងខេត្តឧត្តរមានជ័យបានស្នើដល់រាជរដ្ឋាភិបាលពិចារណាផ្តល់ដីសម្បទានសេដ្ឋកិច្ចដែលបាននិវាសករណ៍ទៅគ្រួសារក្រីក្របំផុត និងគ្រួសារគ្មានដី តាមរយៈយន្តការដែលមានស្រាប់របស់រាជរដ្ឋាភិបាលដូចជា យន្តការផ្តល់សម្បទានដីសង្គមកិច្ច។ ទោះជាយ៉ាងនេះក្តី អ្នកឆ្លើយតបតិចតួច(៣-៦%) បានស្នើថាដីសម្បទានដែលបាននិវាសករណ៍គួរតែរក្សាទុកដើម្បីស្តារគម្របព្រៃឈើឡើងវិញ សម្រាប់អភិរក្សជីវៈចម្រុះ និងតំបន់ការពារធម្មជាតិ។

## ៨. សេចក្តីសន្និដ្ឋាន និងអនុសាសន៍

### ៨.១ សន្និដ្ឋាន

យោងតាមការវិភាគ និងករណីសិក្សាទាំងបួន ចំនួនក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចដែលកំពុងប្រតិបត្តិការស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានចំនួន២២៩ក្រុមហ៊ុនដោយមានផ្ទៃដីសម្បទានសរុបចំនួន១,៥៣លានហិកតា នៅទូទាំងប្រទេសកម្ពុជា។ ចំនួនក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចដែលបាននិរាសករណ៍សរុប៣៤ក្រុមហ៊ុន (១១ក្រុមហ៊ុនស្ថិតនៅក្រោមក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង២៣ក្រុមហ៊ុនស្ថិតនៅក្រោមក្រសួងបរិស្ថាន)។ ការទទួលបានព័ត៌មានសម្បទានដីសេដ្ឋកិច្ច និងឯកសារផ្លូវច្បាប់មានតម្លាភាពតិចតួចបំផុត។ បើពិនិត្យលើសិទ្ធិមនុស្ស សហគមន៍ដែលរងផលប៉ះពាល់ពីសម្បទានដីសេដ្ឋកិច្ចមិនអាចទទួលបានព័ត៌មាន និងមិនបានចូលរួមពេញលេញក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្ត។ ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចមួយចំនួនមិនបានអនុវត្តតាមលក្ខណ្ឌតម្រូវរបស់ច្បាប់ប្រទេសកម្ពុជា ដូចជា របាយការណ៍ EIA ការធ្វើអនុបយោគដី ការចុះបញ្ជីដីរដ្ឋ បទល្មើសព្រៃឈើ និងការត្រួតគ្នាលើព្រំដីរបស់សហគមន៍ ជាដើម។ ភាគច្រើននៃការផ្តល់សម្បទានដីសេដ្ឋកិច្ចស្ថិតនៅក្នុងតំបន់ព្រៃឈើ និងតំបន់ការពារធម្មជាតិ។ ការផ្តល់សំណងរបស់ក្រុមហ៊ុនទៅសហគមន៍មិនអាចទទួលយកបាន ពីព្រោះមានតម្លៃទាប ជាងទីផ្សារ ទំហំដីតូចជាង ដីគ្មានជីជាតិ និងតំបន់ដែលគ្មានព្រៃឈើ។ ភាគច្រើននៃក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចដែលបាននិរាសករណ៍មិនគោរពតាមច្បាប់របស់ប្រទេសកម្ពុជា និងបានចូលរួមចំណែកប្រព្រឹត្តបទល្មើសព្រៃឈើ និងរំលោភសិទ្ធិមនុស្ស។

### ៨.២ អនុសាសន៍

**សម្រាប់ក្រសួងពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល**

1. ពង្រឹង និងជំរុញការអនុវត្តច្បាប់របស់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចនីមួយៗ ពាក់ព័ន្ធនឹងការធ្វើអនុបយោគដីសាធារណៈរបស់រដ្ឋ វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ការចុះបញ្ជីដីឯកជនរបស់រដ្ឋជាមួយក្រសួងរៀប ចំដែនដី នគរូបនីយកម្ម និងសំណង់ ការកាប់ឈើខុសច្បាប់ក្នុងតំបន់ជុំវិញគម្រោងសម្បទានដីសេដ្ឋកិច្ច។ល។
2. ក្រុមហ៊ុនទីប្រឹក្សាឯករាជ្យទាំងអស់ដែលនឹងធ្វើការសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម (SEIA) គួរតែពិនិត្យមើលឡើងវិញ និងធានាគុណភាពដោយក្រសួងបរិស្ថាន។ សហគមន៍រងផលប៉ះពាល់ អង្គការមិនមែនរដ្ឋាភិបាល អង្គការមូលដ្ឋាន និងអ្នកពាក់ព័ន្ធផ្សេងៗទៀតគួរតែចូលរួមពិគ្រោះយោបល់ ចរចារ និងដាក់បញ្ចូល នូវមតិយោបល់របស់ពួកគេឱ្យបានពេញលេញនៅគ្រប់ដំណាក់កាលទាំងអស់នៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម។ ធានាថា លទ្ធផលនៃរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមគួរតែអាចរកបានជាសាធារណៈ ការផ្សព្វផ្សាយឱ្យបានទូលំទូលាយ ប្រជាជនមូលដ្ឋានអាចយល់ខ្លឹមសារបានអាចរកបាននៅលើក្តាព័ត៌មានមូលដ្ឋានដែលស្ថិតនៅជិតទីតាំងគម្រោងសម្បទានដីសេដ្ឋកិច្ច ព្រមទាំងដាក់លើគេហទំព័រ។

3. អនុលោមតាមកិច្ចសន្យា និងផែនការមេថ្មីរបស់ក្រុមហ៊ុននីមួយៗ ក្រសួងពាក់ព័ន្ធរបស់រាជរដ្ឋាភិបាលគួរតែបន្ត តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តប្រចាំឆ្នាំឱ្យបានម៉ត់ចត់។ ផ្តល់ឱកាសដល់សហគមន៍ដែលរងផល ប៉ះពាល់ដើម្បីចូលរួមក្នុងដំណើរការវាយតម្លៃការអនុវត្តប្រចាំឆ្នាំ និងផ្តល់ភស្តុតាង/ជាតុចូលដើម្បីគាំទ្រដំណើរ ការធ្វើសេចក្តីសម្រេចចិត្ត។
4. ទំនាស់ដីធ្លីរវាងសហគមន៍ និងក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចគួរតែដោះស្រាយឱ្យបានរួចរាល់ មុនពេលឈូសឆាយព្រៃឈើ។ ការឈូសឆាយដីនិងព្រៃគួរតែទទួលបានការអនុម័តដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទជាមុនសិន។
5. មុខរបរចិញ្ចឹមជីវិតតាមបែបប្រពៃណី ទំនៀមទំលាប់សហគមន៍ជនជាតិដើមភាគតិច និងតំបន់បេតិកភណ្ឌ គួរតែរៀបចំផែនទី និងបោះបង្គោលព្រំសម្រាប់គោលបំណងអភិរក្ស និងផែនការ។ ការផ្តល់សម្បទានដីសេដ្ឋកិច្ច គួរតែជៀសវាងនៅទីកន្លែងនោះ ឬជិតទីតាំងនោះ។
6. ដើម្បីជៀសវាងការបកស្រាយខុសគ្នារបស់អ្នកពាក់ព័ន្ធ ជាពិសេស អង្គការសង្គមស៊ីវិល និងរដ្ឋាភិបាលលើស្ថិតិ សម្បទានដីសេដ្ឋកិច្ច ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គួរតែធ្វើបច្ចុប្បន្នភាព និងបំពេញព័ត៌មានក្នុងបញ្ជីក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច និងព្រៃសម្បទានដែលនៅមានសកម្មភាពឱ្យបានពេញលេញ ដោយរួមបញ្ចូលនូវវឌ្ឍនភាពនៃប្រតិបត្តិការគម្រោង និងដាក់ជូនឱ្យសាធារណៈជនអាចរកបាននៅពេលណាមួយសមស្រប។ បញ្ជីឈ្មោះក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចគួរតែមានព័ត៌មានពេញលេញ រួមមានព័ត៌មានលម្អិតរបស់ម្ចាស់ក្រុមហ៊ុន ភាគហ៊ុន ម្ចាស់ដើមរបស់ក្រុមហ៊ុន និងអាសយដ្ឋានទំនាក់ទំនងលម្អិតរបស់ក្រុមហ៊ុននៅក្នុងស្រុក (ការិយាល័យក្នុងប្រទេស និងទីតាំងដែលអាចរកឃើញ) ការបង់ថ្លៃឈ្នួលសម្បទាន និងចំណូលបានពី សម្បទានដីសេដ្ឋកិច្ច។ ព័ត៌មានទាំងនេះគួរតែមានទាំងភាសាខ្មែរ និងអង់គ្លេស។
7. យោងតាមសំណូមពររបស់សហគមន៍ដែលរងផលប៉ះពាល់ពីគម្រោង សម្បទានដីសេដ្ឋកិច្ចដែលបាននិរាសករណ៍គួរតែសម្បទានទៅគ្រួសារក្រីក្រដែលពុំមានដី និងគ្រួសារទីទាល់ក្រដើម្បីដាំដុះដំណាំកសិកម្ម និងបង្កើនប្រាក់ចំណូល ដោយអនុលោមតាមយន្តការរបស់រាជរដ្ឋាភិបាលដែលមានស្រាប់។ ផ្ទៃដីព្រៃដែលនៅសល់ពីការនិរាសករណ៍សម្បទានដីសេដ្ឋកិច្ចគួរតែរក្សាទុកជាតំបន់អភិរក្សព្រៃឈើ ឬតំបន់ស្តារព្រៃឈើឡើងវិញ។ ក្រសួងពាក់ព័ន្ធគួរតែផ្តល់នូវការគាំទ្របច្ចេកទេសដល់ការងារទាំងនេះ។
8. ការបាត់បង់ ឬចំរើលបរិស្ថាន ការហូរច្រោះដី ផលប៉ះពាល់សេដ្ឋកិច្ច និងសង្គម ការបាត់បង់ជីវៈចម្រុះនិងប្រព័ន្ធ អេកូឡូស៊ីដោយសារតែការអនុវត្តមិនស្របតាមច្បាប់ និងសម្មភាពរបស់ក្រុមហ៊ុនសម្បទានគួរតែផ្តល់សំណងសមរម្យ និងមានវិធានការតាមផ្លូវច្បាប់។

## សម្រាប់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច

1) ស្តង់ដានៃការទទួលខុសត្រូវសង្គម(CSR) គួរតែអនុវត្តដោយក្រុមហ៊ុនទាំងអស់។ ការតាំងទីលំនៅថ្មីគួរតែពិគ្រោះយោបល់ជាមួយប្រជាជនរងផលប៉ះពាល់ឱ្យបានពេញលេញ និងគោលរពតាមស្តង់ដាសិទ្ធិមនុស្ស និងតម្រូវការជាមូលដ្ឋានរបស់មនុស្ស។ ស្តង់ដាដោយសេរី ជាមុនដោយមានព័ត៌មានគ្រប់គ្រាន់(FPIC) គួរតែអនុវត្តឱ្យបានម៉ឺងម៉ាត់នៅពេលពិគ្រោះយោបល់ជាមួយជនជាតិដើមភាគតិច។

2) ដើម្បីចូលរួមចំណែកក្នុងគោលនយោបាយកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាល ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចគួរតែផ្តល់ការងារដល់ប្រជាជនមូលដ្ឋានឱ្យបានច្រើនដើម្បីធ្វើការជាមួយក្រុមហ៊ុនដោយទទួលបានប្រាក់ឈ្នួល/ប្រាក់បៀវត្សសមរម្យ។ លក្ខណ្ឌការងារគួរតែអនុលោមតាមច្បាប់ស្តីពីការងារនៃប្រទេសកម្ពុជា។
3) សហគមន៍ដែលរស់នៅជុំវិញសម្បទានដីសេដ្ឋកិច្ចគួរតែអាចប្រើប្រាស់ផ្លូវថ្មី និងមិនហាមឃាត់ការធ្វើដំណើរនៅក្នុងទីតាំងដីសម្បទានសេដ្ឋកិច្ច។
4) ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចគួរតែផ្តល់ការគាំទ្រដើម្បីជាប្រយោជន៍សង្គម ដូចជា សេវាសុខភាព ឱកាសអប់រំ និងវិធានការការពារបរិស្ថាន ព្រមទាំងចូលរួមចំណែកដល់សកម្មភាពអភិវឌ្ឍន៍សហគមន៍។

**សម្រាប់អង្គការមិនមែនរដ្ឋាភិបាល/អង្គការសង្គមស៊ីវិល**

6) ជូនដំណឹង និងចែករំលែកព័ត៌មានស្តីពីផលប៉ះពាល់ជាសក្តានុពលលើជីវភាពរស់នៅរបស់សហគមន៍ដែលរងផលប៉ះពាល់តាមរយៈការគាំទ្រផ្នែកបច្ចេកទេស និងផ្នែកច្បាប់ទៅតាមការចាំបាច់។
7) អនុលោមតាមច្បាប់នៃក្រមបរិស្ថាន និងធនធានធម្មជាតិ(ថ្មី) លើកកម្ពស់ និងពង្រឹងការពិគ្រោះយោបល់ជាសាធារណៈលើការអភិវឌ្ឍសម្បទានដីសេដ្ឋកិច្ច ការរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ការអនុវត្តលិខិតបទដ្ឋានគតិយុត្ត និងលក្ខណ្ឌតម្រូវផ្សេងៗនៃច្បាប់ផ្សេងៗ ចំពោះក្រុមហ៊ុនដែលកំពុងដំណើរការដើម្បី កែលម្អការអភិវឌ្ឍកសិ ឧស្សាហកម្មកាន់តែប្រសើរចំពោះជីវភាពរស់នៅមូលដ្ឋានដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្រនៅក្នុងប្រទេសកម្ពុជា។
8) លើកកម្ពស់ការយល់ដឹងជាសាធារណៈ និងអភិវឌ្ឍន៍សមត្ថភាពសហគមន៍មូលដ្ឋានលើសិទ្ធិមនុស្ស ក្របខណ្ឌច្បាប់ សិទ្ធិដីធ្លី ដំណើការចុះបញ្ជីដីធ្លី យុទ្ធសាស្រ្តតស៊ូមតិ និងជំនាញចាំបាច់នានាទៀត។
9) អនុវត្តតាមរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងប្រភពព័ត៌មានផ្សេងៗទៀតអំពីក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច គួររៀបចំជាឯកសារការពិត ឬសម្ភារៈផ្សព្វផ្សាយសម្រាប់សហគមន៍ដែលរងផលប៉ះពាល់ពីគម្រោងដើម្បីជាព័ត៌មានសម្រាប់ពួកគាត់។

# ឯកសារយោង


1. អង្គការអោដហុក(២០១៤), ស្ថានភាពដីនៅកម្ពុជា២០១៣ ប្រទេសកម្ពុជា
2. ទីភ្នាក់ងារការសែតកម្ពុជា(២០១៥),ក្រសួងកសិកម្មនឹងបញ្ចប់ការវាយតម្លៃសម្បទានដីសេដ្ឋកិច្ចនៅកម្ពុជា ការសែតចុះថ្ងៃទី៣០ ខែកញ្ញា ២០១៥
3. អង្គការ CEA និង CDRI (២០១៥),ការគ្រប់គ្រងសម្បទានដីសេដ្ឋកិច្ច កម្ពុជា
4. អង្គការ CLEC, អង្គការ SVC និងផ្សេងៗ (២០១៣), បញ្ហា និងផលប៉ះពាល់ពីការចុះបញ្ជីដីឯកជននៅក្នុងសហគមន៍ជនជាតិដើមភាគតិច ខេត្តរតនៈគីរី កម្ពុជា
5. អង្គការ CDRI (២០១២), ការវិនិយោគបរទេសក្នុងវិស័យកសិកម្មប្រទេសកម្ពុជា
6. មជ្ឈមណ្ឌលកាណាដាសម្រាប់ការអប់រំ និងវិទ្យាសាស្ត្រ (២០១៤)ផលប៉ះពាល់ពីការពង្រីកកសិកម្មលើគម្របព្រៃឈើក្នុងខេត្តរតនៈគីរី ប្រទេសកម្ពុជា
7. សហភាពអឺរ៉ុប(២០១២), ឯកសារបរិស្ថានកម្ពុជា
8. អង្គការទិន្នាការព្រៃឈើ (២០១៥), ការប្រែប្រួលផលព្រៃឈើ ការត្រួតពិនិត្យព្រៃឈើ និងអភិបាលកិច្ចដីធ្លីនៅក្នុងប្រទេសកម្ពុជា
9. សេវាកម្មព្រៃឈើសាកល រដ្ឋបាលព្រៃឈើ និងផ្សេងៗ (២០១៤) ស្វែងយល់អំពីការនាំឈើ និងការត្រួតពិនិត្យនៅក្នុងប្រទេសកម្ពុជា ក្នុងបរិបទ FLECT
10. អង្គការ Heinrich Boll Sufting (២០១៥) ការរំលោភដីខ្នាតធំនៅក្នុងប្រទេសកម្ពុជា ការបរាជ័យនៃគោលនយោបាយជាតិ និងអន្តរជាតិដើម្បីធានាសិទ្ធិជនជាតិដើមភាគតិច ដើម្បីទទួលបានការប្រើប្រាស់ដី និងធនធានធម្មជាតិ សហរដ្ឋអាមេរិច
11. ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (២០១៦),របាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ២០១៦ និងផែនការបន្ត ប្រទេសកម្ពុជា
12. ក្រសួងបរិស្ថាន (២០១៥); របាយការណ៍ពាក់កណ្ដាលអាណត្តិ (កញ្ញា ២០១៣ ដល់ មេសា ២០១៥)
13. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ(២០១០), កម្មវិធីព្រៃឈើជាតិ ២០១០-២០១៩
14. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ(២០១៤), ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ២០១៤-២០១៨
15. កម្មវិធីប្រើប្រាស់ប្រកបដោយចីរភាព និងអភិរក្សជីវៈចម្រុះតំបន់ដីសើមមេគង្គ (២០០៦) ការវិភាគស្ថានភាពខេត្តស្ទឹងត្រែង កម្ពុជា
16. វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្ដីពីកម្ពុជា និងផ្សេងៗ (២០១៥) របាយការណ៍ស៊ើបអង្កេតផលប៉ះពាល់ពីគម្រោងអភិវឌ្ឍន៍ ខេត្តក្រចេះ
17. អង្គការ NEPcon និងអង្គការនិន្នាការព្រៃឈើ(២០១៤) ការប្រែប្រួលដីព្រៃឈើ និងការប៉ាន់ស្មានផលព្រៃឈើករណីសិក្សាពីប្រទេសកម្ពុជា ប្រទេសដាណឺម៉ាក

18. វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា(២០១៥)គោលនយោបាយចាស់សកម្មភាពថ្មី(បទបញ្ជា០១បប)
19. រាជរដ្ឋាភិបាលកម្ពុជា (២០០១), ច្បាប់ភូមិបាល២០០១
20. រាជរដ្ឋាភិបាលកម្ពុជា (២០០៥), អនុក្រឹត្យលេខ១៤៦ ស្តីពីសម្បទានដីសេដ្ឋកិច្ច
21. រាជរដ្ឋាភិបាលកម្ពុជា (១៩៩៩), ប្រកាសលេខ៧២ស្តីពីគោលការណ៍ណែនាំការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន
22. រាជរដ្ឋាភិបាលកម្ពុជា (២០១៤),ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨
23. រាជរដ្ឋាភិបាលកម្ពុជា (២០១៣) ផែនការយុទ្ធសាស្ត្រចតុកោណជំហានទី៣
24. រាជរដ្ឋាភិបាលកម្ពុជា (២០១២),បទបញ្ជា០១បប និង០២បប
25. ប៉ែន ប្រាជ្ញវុទ្ធី(២០១១),ផលប៉ះពាល់ពីសម្បទានដីសេដ្ឋកិច្ចលើជនជាតិដើមភាគតិចនៅខេត្តភូមិភាគឥសាន ប្រទេសកម្ពុជា
26. អង្គការ PIC (២០១៥), ការចុះបញ្ជីដីសមូហភាព និងសេចក្តីសង្ខេបដីសម្បទានសេដ្ឋកិច្ច កម្ពុជា

## គេហទំព័រ

- E-International Relations: ELC and law in Cambodia: http://www.e-ir.info/2013/06/18/economic-land-concessions-and-the-law-in-cambodia/
- LICADHO (viewed on May 2017): visualizing ELC by timing http://www.licadho-cambodia.org/concession_timelapse/
- Open Development Cambodia (download December 2016): Economic Land concession meta data https://opendevelopmentcambodia.net/profiles/economic-land-concessions/
- Springer link (viewed March 2017): The Politics and Ethics of Land Concessions in Rural Cambodia https://link.springer.com/article/10.1007/s10806-013-9446

## ឧបសម្ព័ន្ធ១៖ បច្ចុប្បន្នភាពបញ្ជីក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចក្នុងខេត្តចំនួន០៤(រតនៈគិរី ស្ទឹងត្រែង ក្រចេះ និងឧត្តរមានជ័យ)

| ល.រ | ស្ថានភាពបច្ចុប្បន្ន | រយៈពេលថ្មី(ឆ្នាំ) | ឈ្មោះក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច | ទំហំផ្ទៃដីសរុប (ហត) | ទំហំផ្ទៃដីថ្មី(ហត) | កាលបរិច្ឆេទចុះកិច្ចសន្យា | នាយកក្រុមហ៊ុន | សញ្ជាតិ | ខេត្ត | ស្រុក | ឃុំ | ដែនសមត្ថកិច្ច (មុនពេលផ្ទេរ) | អនុបយោគដី |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| 1 | កាត់បន្ថយទំហំផ្ទៃដី | 50 | ក្រុមហ៊ុន ៧មករា ផារី (7 Makara Phary Co. Ltd.) ពីមុនឈ្មោះ Heng Development Co. Ltd.) | 8655 | | | គឹម សុផានី | | រតនៈគិរី | អណ្ដូងមាស | | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (កសក) | |
| 2 | កាត់បន្ថយទំហំផ្ទៃដី | 50 | ក្រុមហ៊ុន ម្កុដពេជ្រ អភិវឌ្ឍន៍កសិ ឧស្សាហកម្ម ( Mkod Pich Development Agro-Industry | 1950 | | | | | រតនៈគិរី | លំផាត់ | | ក្រសួងបរិស្ថាន | ដែនជម្រកសត្វព្រៃលំផាត់ |
| 3 | កាត់បន្ថយទំហំផ្ទៃដី | 50 | ក្រុមហ៊ុន ហួង អាញ់ អណ្ដូងមាស(Hoang Anh Andong Meas Co. Ltd) | 9775 | | | Nguyen Van Thu | វៀតណាម | រតនៈគិរី | តាវែង | | ក្រសួងបរិស្ថាន | ឧទ្យានជាតិវីរៈជ័យ |
| 4 | កាត់បន្ថយទំហំផ្ទៃដី | 50 | ក្រុមហ៊ុន អានុភាព សុភី វិនិយោគ(Noupheap Sophy Investment Co. Ltd.) | 9000 | | | អាន សុភី | | រតនៈគិរី | អណ្ដូងមាស តាវែង | | ក្រសួងបរិស្ថាន | ឧទ្យានជាតិវីរៈជ័យ |
| 5 | កាត់បន្ថយទំហំផ្ទៃដី | 50 | ក្រុមហ៊ុន ចាង លី វិនិយោគ (Chuang Li Investment Co. Ltd.) | 1900 | 200 | 3/29/2011 | ចាង ហុងវៃ CHANG HON WAI | ចិន | រតនៈគិរី | អណ្ដូងមាស | ញ៉ាន ម៉ាលិក | កសក | |
| 6 | កាត់បន្ថយទំហំផ្ទៃដី | 50 | ដូនពេញ អាហ្គ្រីកូ (Daun Penh Agrico Co. Ltd.) | 8825 | | | ជា ចាន់ពៅ | | រតនៈគិរី | លំផាត់ | | ក្រសួងបរិស្ថាន | ដែនជម្រកសត្វព្រៃលំផាត់ |
| *7* | *និរសករណ៍* | *50* | *ក្រុមហ៊ុន ជីង សួងធាន (Jing Zoung Tian Co. Ltd.)* | *9936* | | | | | រតនៈគិរី | | | ក្រសួងបរិស្ថាន | ឧទ្យានជាតិវីរៈជ័យ |
| 8 | កាត់បន្ថយទំហំផ្ទៃដី | 50 | ហ័ងអាន់ អូយ៉ាដាវ (Hoang Anh Oyadav Co. Ltd.) | 9000 | | 9/22/2011 | ម៉ៃឌិញហុង Mai Dinh Hong | វៀតណាម | រតនៈគិរី | Andoung Meas | Nhang;Ta Lao | កសក | |
| 9 | កាត់បន្ថយ | 50 | ស៊ី អា ឌី (CRD Co. Ltd.) | 7591 | 3174 | 3/25/2011 | ង្វៀន វ៉ាន់មិញ | វៀតណាម | រតនៈគិរី | អណ្ដូងមាស បាកែវ អូជុំ | | កសក | |

| ល.រ | ស្ថានភាពបច្ចុប្បន្ន | រយៈពេលថ្មី(ឆ្នាំ) | ឈ្មោះក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច | ទំហំផ្ទៃដីសរុប (ហត) | ទំហំផ្ទៃដីថ្មី(ហត) | កាលបរិច្ឆេទចុះកិច្ចសន្យា | នាយកក្រុមហ៊ុន | សញ្ជាតិ | ខេត្ត | ស្រុក | ឃុំ | ដែនសមត្ថកិច្ច (មុនពេលផ្ទេរ) | អនុបយោគដី |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ទំហំផ្ទៃដី | | | | | | Nguyen Van Minh | | | | | | |
| 10 | *និរាសករណ៍* | 50 | ហ្វុយ សៀងហៃ Fu Sheng Hai (Cambodia) Co. Ltd. | 7079 | | | ម៉ាស៊ាងចេង Ma Shuang Cheng | ចិន | រតនៈគីរី | តាវែង អណ្តូងមាស | | ក្រសួងបរិស្ថាន | ឧទ្យានជាតិវីរៈជ័យ |
| 11 | កាត់បន្ថយទំហំផ្ទៃដី | 50 | វាសនា វិនិយោគ Veasna Investment | 5080 | | 3/25/2011 | តុន វាសនា | | រតនៈគីរី | អណ្តូងមាស បរកែវ | | កសក | |
| 12 | *កែសម្រួល* | 50 | ទ្រី ភាព អារហ័ណនីហរណេ Try Pheap Import Export Co. Ltd. | 9709 | | | ទ្រី ភាព | | រតនៈគីរី | តាវែង | | ក្រសួងបរិស្ថាន | |
| 13 | កាត់បន្ថយទំហំផ្ទៃដី | 50 | ស្រ៊ុន សុវណ្ណភូមិ វិនិយោគ Srun Sovannaphoum Investment Co. Ltd. | 8998 | | | អាំង សុផានិត Ang Sophanit | | រតនៈគីរី | តាវែង | | ក្រសួងបរិស្ថាន | ឧទ្យានជាតិវីរៈជ័យ |
| 14 | កាត់បន្ថយទំហំផ្ទៃដី | 50 | ក្រុមហ៊ុន DM Group | 749 | 190 | 1/26/2012 | | | រតនៈគីរី | អណ្តូងមាស | ញ៉ាង | កសក | |
| 15 | កាត់បន្ថយទំហំផ្ទៃដី | 50 | ក្រុមហ៊ុន អេស ខេ ផ្លានថេសិន SK Plantation (Cambodia) Pte. | 8000 | | | សូរិនដ្រា កុមាផុដា Surendra Kumar Poddar | | រតនៈគីរី | វើនសៃ កូនមាន់ | | កសក | |
| 16 | កាត់បន្ថយទំហំផ្ទៃដី | 50 | ក្រុមហ៊ុន Holley Eco-industrial (Cambodia) Co.,LTD) | 7497 | | 8/17/2011 | ហ្សាគ ហ្សីជីង Xiaq Qijing | ចិន | រតនៈគីរី | កូនមាន់ | ត្រពាំងក្រហម និងត្រពាំងច្រេស | កសក | |
| 17 | កាត់បន្ថយទំហំផ្ទៃដី | 50 | ក្រុមហ៊ុន Rat Sokhorn Incorporation Co. Ltd. | 9000 | | | រ័ត្ន សុខន | | រតនៈគីរី | លំផាត់ | | ក្រសួងបរិស្ថាន | ដែនជម្រកសត្វព្រៃលំផាត់ |

| ល.រ | ស្ថានភាពបច្ចុប្បន្ន | រយៈពេលថ្មី(ឆ្នាំ) | ឈ្មោះក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច | ទំហំផ្ទៃដីសរុប (ហត) | ទំហំផ្ទៃដីថ្មី(ហត) | កាលបរិច្ឆេទចុះកិច្ចសន្យា | នាយកក្រុមហ៊ុន | សញ្ជាតិ | ខេត្ត | ស្រុក | ឃុំ | ដែនសមត្ថកិច្ច (មុនពេលផ្ទេរ) | អនុបយោគដី |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| 18 | កាត់បន្ថយទំហំផ្ទៃដី | 50 | ក្រុមហ៊ុន Kausu Eahleo ក្រុមហ៊ុន BM Joint Stock Co.,LTD | 8400 | | 10/5/2011 | Le Van Thuan | វៀតណាម | រតនៈគីរី | លំផាត់ | សេដា | ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | |
| 19 | កាត់បន្ថយទំហំផ្ទៃដី | 50 | ក្រុមហ៊ុន Global Tech Sdn., Bhd, Rama Khmer International and Men Sarun Friendship | 20000 | 1300 | 12/21/1999 | ម៉ែន សារុន | ខ្មែរ | រតនៈគីរី | អូយ៉ាដាវ | | កសក | |
| 20 | កាត់បន្ថយទំហំផ្ទៃដី | 50 | ក្រុមហ៊ុន ជា ច័ន្ទរិទ្ធ អភិវឌ្ឍន៍ Chea Chanrith Aphivath | 5124 | | 11/12/2007 | Nguyen Canh Quang | | រតនៈគីរី | បរកែវ អូយ៉ាដាវ | | កសក | |
| 21 | កាត់បន្ថយទំហំផ្ទៃដី | 50 | ក្រុមហ៊ុន ហេង ប្រាឌ័រ Heng Brother Co.Ltd. | 2361 | | 7/31/2009 | Nguyen Tuan Linh | វៀតណាម | រតនៈគីរី | អណ្តូងមាស | | កសក | |
| 22 | *និរាសករណ៍* | 70 | ក្រុមហ៊ុន ហេង ហ៊ាប វិនិយោគ Heng Heap Investment | 7000 | | 7/31/2009 | ហេង ហ៊ាប | ខ្មែរ | រតនៈគីរី | អូយ៉ាដាវ | | កសក | |
| 23 | កាត់បន្ថយទំហំផ្ទៃដី | 50 | ក្រុមហ៊ុន Hong An Mang Yang K Rubber Development | 6891 | | 9/25/2009 | Le Dinh Buu | វៀតណាម | រតនៈគីរី | វើនសៃ | | កសក | |
| 24 | កាត់បន្ថយទំហំផ្ទៃដី | 50 | ក្រុមហ៊ុន គីរីអភិវឌ្ឍន៍ Kiri Development | 807 | | 7/31/2009 | ឆេង ហុក | ខ្មែរ | រតនៈគីរី | វើនសៃ | | កសក | |
| 25 | កាត់បន្ថយទំហំផ្ទៃដី | 50 | ក្រុងបូក រតនៈគីរី អភិវឌ្ឍន៍ កៅស៊ូ Krong Buk Ratanakiri Aphivath Caoutchouc Co. Ltd. | 6695 | | 4/9/2010 | Nguyen Van Thanh | វៀតណាម | រតនៈគីរី | តាវែង អណ្តូងមាស | | កសក | |
| 26 | កាត់បន្ថយទំហំផ្ទៃដី | 50 | ក្រុមហ៊ុន Dai Dong Yoeun Commercial Joint-stock Company | 4889 | | 1/29/2010 | | | រតនៈគីរី | អូយ៉ាដាវ | | កសក | |
| 27 | កាត់បន្ថយ | 50 | ក្រុមហ៊ុន Jing Zhong Ri Co. Ltd. | 9224 | | | Li Qing Xian | | រតនៈគីរី | លំផាត់ | | ក្រសួងបរិស្ថាន | ដែនជម្រកសត្វ |

| ល.រ | ស្ថានភាពបច្ចុប្បន្ន | រយៈពេលថ្មី(ឆ្នាំ) | ឈ្មោះក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច | ទំហំផ្ទៃដីសរុប (ហត) | ទំហំផ្ទៃដីថ្មី(ហត) | កាលបរិច្ឆេទចុះកិច្ចសន្យា | នាយកក្រុមហ៊ុន | សញ្ជាតិ | ខេត្ត | ស្រុក | ឃុំ | ដែនសមត្ថកិច្ច (មុនពេលផ្ទេរ) | អនុបយោគដី |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ទំហំផ្ទៃដី | | | | | | | | | | | | ព្រៃលំផាត់ |
| 28 | កាត់បន្ថយទំហំផ្ទៃដី | 50 | ក្រុមហ៊ុន ហ័ង អាញ់ អណ្ដូងមាស Hoang Anh Andong Meas Co. Ltd. | 9470 | | 11/8/2011 | Nguyen Van Thu | វៀតណាម | រតនៈគីរី | អណ្ដូងមាស | | ក្រសួងបរិស្ថាន | ដែនជម្រកសត្វព្រៃលំផាត់ |
| 29 | *កែសម្រួល* | 50 | ក្រុមហ៊ុន ភីឌីអេ PDA (Cambodia) Co. Ltd. | 5256 | | 10/22/2009 | Han Tae Woo | កូរ៉េ | ក្រចេះ |ស្នួល | ស្វាយជ្រះ | កសក | |
| 30 | *និរាសករណ៍* | 70 | CIV Development Agro Industry | 1000 | 108 | 11/1/2008 | | | ក្រចេះ | ស្នួល | ខ្ពបស្រែចារ | កសក | |
| 31 | កាត់បន្ថយទំហំផ្ទៃដី | 50 | Hai Yong Investment Agro Industry Company | 701 | | | | | ក្រចេះ | ស្នួល | ខ្ពប | កសក | |
| 32 | *និរាសករណ៍* | 50 | Huot Sambat Co. Ltd. | 6432 | | | Keo Vannary | | ក្រចេះ | ស្នួល | ខ្ពប | ក្រសួងបរិស្ថាន | ដែនជម្រកសត្វព្រៃស្នួល |
| 33 | កាត់បន្ថយទំហំផ្ទៃដី | 50 | ក្រុមហ៊ុន Dau Thieng-Kratie Rubber Development Co. Ltd. | 6592 | | 1/3/2011 | | | ក្រចេះ | ស្នួល ឆ្លូង | ដំរីផុងព្រែកសាមានស្វាយជ្រេស | កសក និងខេត្ត | អនុក្រឹត្យ#174, 30-12-2010 |
| 34 | កាត់បន្ថយទំហំផ្ទៃដី | 50 | ក្រុមហ៊ុន Dau Thieng (Cambodia) Rubber Development Co. Ltd. | 7972 | | 1/3/2011 | | | ក្រចេះ | ស្នួល ឆ្លូង | កំពង់ដំរីស្វាយជ្រេស ដំរីផុង | កសក និងខេត្ត | |
| 35 | កាត់បន្ថយទំហំផ្ទៃដី | 50 | ក្រុមហ៊ុន ច័ន្ទ សុភា អភិវឌ្ឍ Chan Sophea Aphivath Co. Ltd. | 5088 | | 1/3/2011 | ម៉ៅ ច័ន្ទសុភា | | ក្រចេះ | ឆ្លូង | កំពង់ដំរីដំរីផុង | កសក | |
| 36 | *កែសម្រួល* | 50 | ក្រុមហ៊ុន JPE Co. Ltd. | 678 | | | ប៉ុល សុធាវី | | ក្រចេះ | ស្នួល | ខ្ពប | កសក | |
| 37 | *កែសម្រួល* | 50 | ក្រុមហ៊ុន Therak Viniyo (previously SL International Ltd.) | 520 | | | | | ក្រចេះ | ស្នួល | ខ្ពប | កសក | |

| ល.រ | ស្ថានភាពបច្ចុប្បន្ន | រយៈពេលថ្មី(ឆ្នាំ) | ឈ្មោះក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច | ទំហំផ្ទៃដីសរុប (ហត) | ទំហំផ្ទៃដីថ្មី(ហត) | កាលបរិច្ឆេទចុះកិច្ចសន្យា | នាយកក្រុមហ៊ុន | សញ្ជាតិ | ខេត្ត | ស្រុក | ឃុំ | ដែនសមត្ថកិច្ច (មុនពេលផ្ទេរ) | អនុបយោគដី |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| 38 | *កែសម្រួល* | 50 | ក្រុមហ៊ុន Rattanak Stone Cambodia Development Co.,ltd | 479 | | | | | ក្រចេះ | ស្នួល | ២ធ្នូ | កសក | |
| 39 | កាត់បន្ថយទំហំផ្ទៃដី | 50 | ក្រុមហ៊ុន Trach Niem Huu Han Dau Tu-Phat Trien Dai Nam (Cambodia) Co. Ltd. | 4468 | | | Lau Duc Duy | វៀតណាម | ក្រចេះ | ស្នួល | | ក្រសួងបរិស្ថាន | ដែនជម្រកសត្វព្រៃស្នួល |
| 40 | កាត់បន្ថយទំហំផ្ទៃដី | 50 | ក្រុមហ៊ុន Vietnam Kampuchia Economy, Trade and Industry Company Ltd. (VKETI) Co. Ltd. | 5059 | | | | វៀតណាម | ក្រចេះ | ស្នួល | | ក្រសួងបរិស្ថាន | ដែនជម្រកសត្វព្រៃស្នួល |
| 41 | កាត់បន្ថយទំហំផ្ទៃដី | 50 | ក្រុមហ៊ុន សុវណ្ណ រាជសី Sovann Reachsey Co. Ltd. | 6525 | | | Nguyen Duc Minh | | ក្រចេះ | ស្នួល | | ក្រសួងបរិស្ថាន | ដែនជម្រកសត្វព្រៃស្នួល |
| 42 | *កែសម្រួល* | 50 | ក្រុមហ៊ុន NK Agri (Cambodia) Co., Ltd. | 8892 | | 11/11/2010 | Kumar Arunachal ammoman | | ក្រចេះ | សំបូរ | កោះខ្ញែរ ក្បាលដំរី សណ្ដាន | កសក | |
| 43 | កាត់បន្ថយទំហំផ្ទៃដី | 50 | ក្រុមហ៊ុន សុវណ្ណ វុទ្ធី Sovann Vuthy Co. Ltd. | 5000 | 1279 | | Nguyen Cong Thanh | វៀតណាម | ក្រចេះ | ស្នួល | ២ធ្នូ | ក្រសួងបរិស្ថាន | ដែនជម្រកសត្វព្រៃស្នួល |
| 44 | *និរាសករណ៍* | 70 | ក្រុមហ៊ុន តៃនិញ ក្រចេះ ស៊ូហ្គើរ Tai Ninh Kratie Sugar | 8725 | | | Nguyen Van Loc | | ក្រចេះ | សំបូរ | ល្វេស មានជ័យ ស្រែជី ក្បាលដំរី | កសក | |
| 45 | *កែសម្រួល* | 50 | ក្រុមហ៊ុន Asia World Agricultural Development (Cambodia) Co. Ltd. | 10000 | 7767 | 3/15/2006 | Wan Ylu Ming | ចិន | ក្រចេះ | សំបូរ | | កសក | |
| 46 | កាត់បន្ថយទំហំផ្ទៃដី | 50 | ក្រុមហ៊ុន Green Island Agricultural Development | 9583 | | 3/15/2006 | Kwok Stan Ley Kor | អាមេរិច | ក្រចេះ | សំបូរ | | កសក | |

| ល.រ | ស្ថានភាពបច្ចុប្បន្ន | រយៈពេលថ្មី(ឆ្នាំ) | ឈ្មោះក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច | ទំហំផ្ទៃដីសរុប (ហត) | ទំហំផ្ទៃដីថ្មី(ហត) | កាលបរិច្ឆេទចុះកិច្ចសន្យា | នាយកក្រុមហ៊ុន | សញ្ជាតិ | ខេត្ត | ស្រុក | ឃុំ | ដែនសមត្ថកិច្ច (មុនពេលផ្ទេរ) | អនុបយោគដី |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | (Cambodia) Co. Ltd. | | | | Kuen | | | | | | |
| 47 | កាត់បន្ថយទំហំផ្ទៃដី | 50 | ក្រុមហ៊ុន Great Wonder Agricultural Development (Cambodia) Ltd. | 8231 | 8178 | 8/11/2006 | Kwok Wing | ចិន | ក្រចេះ | សំបូរ | | កសក | |
| 48 | កាត់បន្ថយទំហំផ្ទៃដី | 50 | ក្រុមហ៊ុន Horizon Agriculture Development Co. Ltd. | 9996 | | | | កូរ៉េ | ក្រចេះ | Snuol | ខ្សឹម | កសក | |
| 49 | កាត់បន្ថយទំហំផ្ទៃដី | 50 | ក្រុមហ៊ុន Dau Tu Saigon-Binh Phuoc (SBK) | 6436 | | 7/18/2007 | Dang Tanh Tam | វៀតណាម | ក្រចេះ | Chet Borei | ថ្មី កន្ទួត | កសក | |
| 50 | កាត់បន្ថយទំហំផ្ទៃដី | 50 | ក្រុមហ៊ុន (Cambodia) Tong Min Group Engineering | 7465 | | 12/8/2008 | Zhang Zhen Zhong | ចិន | ក្រចេះ | ក្រចេះ | | កសក | |
| 51 | កាត់បន្ថយទំហំផ្ទៃដី | 50 | ក្រុមហ៊ុន Agri-Industrial Crops Development | 7000 | | 12/8/2008 | Zhang Zheng Wei | ចិន | ក្រចេះ | សំបូរ | ស្រែជី ក្បាលដំរី | កសក | |
| 52 | កាត់បន្ថយទំហំផ្ទៃដី | 50 | ក្រុមហ៊ុន Carmadhenu Venture (Cambodia) Ltd. | 7635 | | 11/13/2009 | Arunachal am Nandaa Kumar | ឥណ្ឌា | ក្រចេះ | សំបូរ | | កសក | |
| 53 | កាត់បន្ថយទំហំផ្ទៃដី | 50 | ក្រុមហ៊ុន ឈុន ហុង រ៉ាប័រ Chhun Hong Rubber Better Co. Ltd | 8202 | | 1/29/2010 | ទី ពិសិដ្ឋ | ខ្មែរ | ក្រចេះ | សំបូរ | កំពង់ចាម | កសក | |
| 54 | កាត់បន្ថយទំហំផ្ទៃដី | 50 | ក្រុមហ៊ុន Crops & Land Development (Cambodia) | 7200 | | 12/8/2008 | Mao Wenjun | ចិន | ក្រចេះ | សំបូរ | ស្រែជី | កសក | |
| 55 | *កែសម្រួល* | 50 | ក្រុមហ៊ុន ស៊ី &វី គ្រុប C&V Group Co., Ltd | 7000 | | 1/29/2010 | Le Muoi | វៀតណាម | ក្រចេះ | សំបូរ | ស្រែជី រលួស | កសក | |
| 56 | កាត់បន្ថយ | 50 | ក្រុមហ៊ុន CHPB Development co.,Ltd | 8686 | | 1/29/2010 | ឆាយ គឹម ផាក | ខ្មែរ | ក្រចេះ | ព្រែកប្រសប់ សំបូរ | ជ្រោយ បន្ទាយ វ | កសក | |

| ល.រ | ស្ថានភាពបច្ចុប្បន្ន | រយៈពេលថ្មី(ឆ្នាំ) | ឈ្មោះក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច | ទំហំផ្ទៃដីសរុប (ហត) | ទំហំផ្ទៃដីថ្មី(ហត) | កាលបរិច្ឆេទចុះកិច្ចសន្យា | នាយកក្រុមហ៊ុន | សញ្ជាតិ | ខេត្ត | ស្រុក | ឃុំ | ដែនសមត្ថកិច្ច (មុនពេលផ្ទេរ) | អនុបយោគដី |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ទំហំផ្ទៃដី | | | | | | Chhay Kim Pak | | | | ឈ្លូនះ កំពង់ចាម | | |
| 57 | កាត់បន្ថយទំហំផ្ទៃដី | 50 | ក្រុមហ៊ុន Mega Star Investment and Forestry Development | 8000 | | 7/31/2009 | Nguyen Trung Kien | វៀតណាម | ក្រចេះ | ក្រចេះ | សំបុក្រ ចង្រ្កង | កសក | |
| 58 | កាត់បន្ថយទំហំផ្ទៃដី | 50 | ក្រុមហ៊ុន Dong Nai Kratie Aphivath Caoutchouc Co. Ltd.( project #2 ) | 4588 | | 1/29/2010 | NGO Toan | វៀតណាម | ក្រចេះ | សំបូរ | អូគ្រាង រលួស មានជ័យ | កសក | |
| 59 | កាត់បន្ថយទំហំផ្ទៃដី | 50 | ក្រុមហ៊ុន Phu Rieng Kratie Aphivath Caoutchouc Co. Ltd. | 6434 | 747 | 7/4/2008 | Nguyen Hong Phu | វៀតណាម | ក្រចេះ | ស្នួល | ស្វាយ ច្រេស | កសក | |
| 60 | កាត់បន្ថយទំហំផ្ទៃដី | 50 | ក្រុមហ៊ុន Phu Rieng Kratie Aphivath Caoutchouc Co. Ltd. II | 915 | | 3/11/2007 | Nguyen Hou Nam | វៀតណាម | ក្រចេះ | ស្នួល | ស្វាយ ច្រេស | កសក | |
| 61 | កាត់បន្ថយទំហំផ្ទៃដី | 50 | ក្រុមហ៊ុន Dong Phu Kratie Aphivath Caoutchouc Co. Ltd. | 9194 | | 7/4/2008 | Huynh Van Tu | វៀតណាម | ក្រចេះ | សំបូរ | រលួស មានជ័យ | កសក | |
| 62 | កាត់បន្ថយទំហំផ្ទៃដី | 50 | ក្រុមហ៊ុន Megastar Produce & Import Export | 8000 | | 7/31/2009 | Lai Phu Chien | វៀតណាម | ក្រចេះ | សំបូរ | អូគ្រាង រលួស មានជ័យ ក្បាលដំរី | កសក | |
| 63 | កាត់បន្ថយទំហំផ្ទៃដី | 50 | ក្រុមហ៊ុន China Dynamic Investment | 6600 | | 1/29/2010 | Wang Zhu Qing | | ក្រចេះ | សំបូរ | រលួស មានជ័យ ស្រែជី | កសក | |
| 64 | *និរាសករណ៍* | 50 | ក្រុមហ៊ុន IPD Insten Pro Trading | 987 | | 4/2/2010 | | | ក្រចេះ | សំបូរ | ក្បាលដំរី | កសក | |
| 65 | កាត់បន្ថយទំហំផ្ទៃដី | 50 | ក្រុមហ៊ុន New Line Cam Pty Co. Ltd. | 8977 | 8461 | 3/29/2011 | ជូ សេចូវ Chau Sechov | ខ្មែរ | ក្រចេះ | សំបូរ | រលួស មានជ័យ | កសក | អនុក្រឹត្យ#147, 30 វិច្ឆិកា 2010 |
| 66 | កាត់បន្ថយ | 50 | ក្រុមហ៊ុន E-Investment | 6450 | | 9/14/2011 | ឡាយ | ខ្មែរ | ក្រចេះ | ស្នួល | ២ធ្នូ | ក្រសួង | ដែនជម្រកសត្វ |

| ល.រ | ស្ថានភាពបច្ចុប្បន្ន | រយៈពេលថ្មី(ឆ្នាំ) | ឈ្មោះក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច | ទំហំផ្ទៃដីសរុប (ហត) | ទំហំផ្ទៃដីថ្មី(ហត) | កាលបរិច្ឆេទចុះកិច្ចសន្យា | នាយកក្រុមហ៊ុន | សញ្ជាតិ | ខេត្ត | ស្រុក | ឃុំ | ដែនសមត្ថកិច្ច (មុនពេលផ្ទេរ) | អនុបយោគដី |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ទំហំផ្ទៃដី | | Co. Ltd. | | | | ប្រហស្ដ Lay Prohors | | | | | បរិស្ថាន | ព្រៃស្នួល |
| 67 | *កែសម្រួល* | 50 | ក្រុមហ៊ុន មេម៉ត់ រ៉ាប៉រ ផ្លានថេសិន Memot Rubber Plantation Co. Ltd. | 9855 | | 9/28/2010 | សេង ទូច/ លឹម ស៊ុន លាង | ខ្មែរ | ក្រចេះ | ស្នួល | | ក្រសួងបរិស្ថាន | ដែនជម្រកសត្វព្រៃស្នួល |
| 68 | កាត់បន្ថយទំហំផ្ទៃដី | 50 | ក្រុមហ៊ុន Binh Phuk Kratie Rubber 2 Co. Ltd. | 10000 | | 1/3/2011 | | វៀតណាម | ក្រចេះ | កែវសីម៉ា | | កសក | |
| 69 | កាត់បន្ថយទំហំផ្ទៃដី | 50 | ក្រុមហ៊ុនសំណាង អង្គរ អភិវឌ្ឍន Samnang Angkor Development Ltd. | 1225 | | 8/13/2009 | គង់ សំណាង | ខ្មែរ | ក្រចេះ | ស្នួល | ២ធ្នូ | ក្រសួងបរិស្ថាន | ដែនជម្រកសត្វព្រៃស្នួល |
| 70 | កាត់បន្ថយទំហំផ្ទៃដី | 50 | ក្រុមហ៊ុន ធី ធី វ៉ាយ TTY Agriculture Plant Development Co. Ltd. | 9780 | | | | | ក្រចេះ | ស្នួល | ២ធ្នូ | ក្រសួងបរិស្ថាន | ដែនជម្រកសត្វព្រៃស្នួល |
| 71 | *កែសម្រួល* | 50 | ក្រុមហ៊ុន Dong Phu Kratie Aphivath Caoutchouc Co. Ltd. (គម្រោងទី ១) | 2349 | | 7/4/2008 | Nguyen Thanh Hai, old director HUYNH TRONG THUY | វៀតណាម | ក្រចេះ | សំបូរ | អូគ្រាង រលួស មានជ័យ | កសក | |
| 72 | *កែសម្រួល* | 50 | ក្រុមហ៊ុន Dong Nai Kratie Aphivath Caoutchouc Co. Ltd. (គម្រោងទី ១) | 2502 | | 7/4/2008 | NGO Toan | វៀតណាម | ក្រចេះ | សំបូរ | អូគ្រាង រលួស មានជ័យ | កសក | |
| 73 | *កែសម្រួល* | 50 | ក្រុមហ៊ុន Dong Phu Kratie Aphivath Caoutchouc Co. Ltd. (គម្រោងទី ២) | 4563 | | 1/29/2010 | Nguyen Thanh Hai, old director HUYNH TRONG THUY | វៀតណាម | ក្រចេះ | សំបូរ | អូគ្រាង រលួស មានជ័យ | កសក | |

| ល.រ | ស្ថានភាពបច្ចុប្បន្ន | រយៈពេលថ្មី(ឆ្នាំ) | ឈ្មោះក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច | ទំហំផ្ទៃដីសរុប (ហត) | ទំហំផ្ទៃដីថ្មី(ហត) | កាលបរិច្ឆេទចុះកិច្ចសន្យា | នាយកក្រុមហ៊ុន | សញ្ជាតិ | ខេត្ត | ស្រុក | ឃុំ | ដែនសមត្ថកិច្ច (មុនពេលផ្ទេរ) | អនុបយោគដី |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| 74 | កាត់បន្ថយទំហំផ្ទៃដី | 50 | ក្រុមហ៊ុន Dong Phu Kratie Aphivath Caoutchouc Co. Ltd.(គម្រោងទី ៣) | 2282 | | 3/7/2011 | Nguyen Thanh Hai, old director HUYNH TRONG THUY | វៀតណាម | ក្រចេះ | សំបូរ | អូរគ្រាង រលួស មានជ័យ | កសក | |
| 75 | *កែសម្រួល* | 50 | ក្រុមហ៊ុន Dong Nai Kratie Aphivath Caoutchouc Co. Ltd. | 5179 | | 7/5/2008 | Huynh Van Tu | វៀតណាម | ក្រចេះ | | | កសក | |
| 76 | កាត់បន្ថយទំហំផ្ទៃដី | 50 | ក្រុមហ៊ុន Eastern Rubber (Cambodia) | 10000 | 5000 | 10/24/2011 | Hoang The Cuong | | ក្រចេះ | ស្នួល កែវសីម៉ា | | កសក | តំបន់អភិរក្សដីវៈចម្រុះកែវសីម៉ា |
| 77 | *កែសម្រួល* | 50 | ក្រុមហ៊ុន Sun Kuy Ty Import-Export Co.,Ltd | 903 | | | | | ក្រចេះ | សំបូរ | ក្បាលដំរី | កសក | |
| 78 | កាត់បន្ថយទំហំផ្ទៃដី | 50 | ក្រុមហ៊ុន Heng Heng Sambath Chamka Kao chou (second project) | 1491 | | | | | ក្រចេះ | ស្នួល | | កសក | |
| 79 | *កែសម្រួល* | 50 | ក្រុមហ៊ុន Thy Vin (Cambodia) LTD | 768 | | | | | ក្រចេះ | ចិត្របុរី | ចង្ក្រង | កសក | |
| 80 | កាត់បន្ថយទំហំផ្ទៃដី | 50 | ក្រុមហ៊ុន Kho KSM Lin Co., ltd | 671 | 100 | | | | ក្រចេះ | ចិត្របុរី | ចង្ក្រង | កសក | |
| 81 | *និរាសករណ៍* | 70 | ក្រុមហ៊ុន Hamony Plantation Co.,LTD | 623 | | | | | ក្រចេះ | ក្រចេះ | ចង្ក្រង | កសក | កសក#2721/277, 30-05-2008 |
| 82 | កាត់បន្ថយទំហំផ្ទៃដី | | ក្រុមហ៊ុន Xay Dung Caout Chouc Duc Dung Co., Ltd[32] | | | | | | ក្រចេះ | ស្នួល | | ក្រសួងបរិស្ថាន | ដែនជម្រកសត្វព្រៃស្នួល |
| 83 | កាត់បន្ថយ | 50 | ក្រុមហ៊ុន Heng Heng Sambath Chamka Kao | 833 | | 9/27/2007 | Minh Rinath | ខ្មែរ | ក្រចេះ | Snoul, | Svay Chreah | កសក | |

[32]It is mention in sar char nar 2015 of council of ministers but no mention the total land size(downsize)

| ល.រ | ស្ថានភាពបច្ចុប្បន្ន | រយៈពេលថ្មី(ឆ្នាំ) | ឈ្មោះក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច | ទំហំផ្ទៃដីសរុប (ហត) | ទំហំផ្ទៃដីថ្មី(ហត) | កាលបរិច្ឆេទចុះកិច្ចសន្យា | នាយកក្រុមហ៊ុន | សញ្ជាតិ | ខេត្ត | ស្រុក | ឃុំ | ដែនសមត្ថកិច្ច (មុនពេលផ្ទេរ) | អនុបយោគដី |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ទំហំផ្ទៃដី | | chou | | | | | | | | | | |
| 84 | កាត់បន្ថយទំហំផ្ទៃដី | 50 | ក្រុមហ៊ុន Data Rubber (Cambodia) Co. Ltd. | 7700 | | | Kitttrol Luckchai | ថៃ | ឧត្តរមានជ័យ | អន្លង់វែង | | ក្រសួងបរិស្ថាន | ដែនជម្រកសត្វព្រៃគូលេនព្រហ្មទេព |
| 85 | កាត់បន្ថយទំហំផ្ទៃដី | 50 | ក្រុមហ៊ុន Best Royal (K) Co. Ltd. | 6500 | | | Tran Thai Ninh | វៀតណាម | ឧត្តរមានជ័យ | | | ក្រសួងបរិស្ថាន | ដែនជម្រកសត្វព្រៃគូលេនព្រហ្មទេព |
| 86 | កាត់បន្ថយទំហំផ្ទៃដី | 50 | ក្រុមហ៊ុន National Plantation (K.H) Co. Ltd. | 9020 | | | ឈឿម សុវណ្ណារី Chhoeum Sovannary | | ឧត្តរមានជ័យ | ត្រពាំងប្រាសាទ | | ក្រសួងបរិស្ថាន | ដែនជម្រកសត្វព្រៃគូលេនព្រហ្មទេព |
| 87 | *និរាសករណ៍* | 70 | ក្រុមហ៊ុន Tonle Sugar Cane Co. Ltd. | 6618 | | 2/24/2008 | Buntoeng Vongkusolkit | ថៃ | ឧត្តរមានជ័យ | ចុងកាល់ | ពង្រ ចុងកាល់ | កសក | |
| 88 | *និរាសករណ៍* | 70 | ក្រុមហ៊ុន Angkor Sugar | 6523 | | 2/24/2008 | Tai Wanakornkul | ថៃ | ឧត្តរមានជ័យ | សំរោង | កូនក្រាល | កសក | |
| 89 | *និរាសករណ៍* | 70 | ក្រុមហ៊ុន (Cambodia) Cane and Sugar Valley | 6595 | | 2/24/2008 | Krisda Monthienci chienchai | ថៃ | ឧត្តរមានជ័យ | សំរោង | កូនក្រាល | កសក | |
| 90 | កាត់បន្ថយទំហំផ្ទៃដី | 50 | ក្រុមហ៊ុន Tomring Rubber Co. Ltd. [យោងតាមអនុក្រឹត្យ]; Tomring Rubber (Cambodia) Co. Ltd. [យោងតាមទីស្តីការគណៈរដ្ឋមន្ត្រី] | 7750 | | | Esther Deong Chew Ming | | ឧត្តរមានជ័យ | ត្រពាំងប្រាសាទ អន្លង់វែង | | ក្រសួងបរិស្ថាន | ដែនជម្រកសត្វព្រៃគូលេនព្រហ្មទេព |
| 91 | កាត់បន្ថយទំហំផ្ទៃដី | 50 | ក្រុមហ៊ុន Samrong Rubber Industries Pte. Ltd. | 9658 | | 4/12/2006 | ប៉ាង ណាម | ខ្មែរ | ឧត្តរមានជ័យ | អន្លង់វែង រាំរិន | | កសក | |
| 92 | *និរាសករណ៍* | 70 | ក្រុមហ៊ុន Khun Sea | 8200 | | | | | ឧត្តរមានជ័យ | | | ក្រសួង | ដែនជម្រកសត្វ |

| ល.រ | ស្ថានភាពបច្ចុប្បន្ន | រយៈពេលថ្មី(ឆ្នាំ) | ឈ្មោះក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច | ទំហំផ្ទៃដីសរុប (ហត) | ទំហំផ្ទៃដីថ្មី(ហត) | កាលបរិច្ឆេទចុះកិច្ចសន្យា | នាយកក្រុមហ៊ុន | សញ្ជាតិ | ខេត្ត | ស្រុក | ឃុំ | ដែនសមត្ថកិច្ច (មុនពេលផ្ទេរ) | អនុបយោគដី |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | Import Export Co. Ltd. | | | | | | | | | បរិស្ថាន | ព្រៃគូលេន ព្រហ្មទេព |
| 93 | កាត់បន្ថយទំហំផ្ទៃដី | 50 | ក្រុមហ៊ុន Tay Ninh Siem Reap Aphivath Caoutchouch Co. Ltd. | 7600 | | | Le Van Chanh | | ឧត្តរមានជ័យ | | | ក្រសួងបរិស្ថាន | ដែនជម្រកសត្វព្រៃគូលេន ព្រហ្មទេព |
| 94 | កាត់បន្ថយទំហំផ្ទៃដី | 50 | ក្រុមហ៊ុន Sok Samnang Development | 1865 | 1800 | | កែវ សារ៉ាន់ | | ឧត្តរមានជ័យ | | | ក្រសួងបរិស្ថាន | ដែនជម្រកសត្វព្រៃគូលេន ព្រហ្មទេព |
| 95 | កាត់បន្ថយទំហំផ្ទៃដី | 50 | ក្រុមហ៊ុន Hout Meng Rita Co. Ltd. | 1195 | | | អាន សុខនីន | | ឧត្តរមានជ័យ | អន្លង់វែង | | ក្រសួងបរិស្ថាន | ដែនជម្រកសត្វព្រៃគូលេន ព្រហ្មទេព |
| 96 | *កែសម្រួល* | 50 | ក្រុមហ៊ុន National Development Co., Ltd | 6000 | | | | | ឧត្តរមានជ័យ | បន្ទាយអំពិល | | ក្រសួងបរិស្ថាន | |
| 97 | *កែសម្រួល* | 50 | ក្រុមហ៊ុន Meng Ly Heng Investment | 1000 | | | | | ឧត្តរមានជ័យ | សំរោង | | កសក | |
| 98 | កាត់បន្ថយទំហំផ្ទៃដី | 50 | ក្រុមហ៊ុន Se Hong Plantation Company Ltd. | 9700 | | | Lee Jong Ho | កូរ៉េ | ឧត្តរមានជ័យ | | | ក្រសួងបរិស្ថាន | ដែនជម្រកសត្វព្រៃគូលេន ព្រហ្មទេព |
| 99 | កាត់បន្ថយទំហំផ្ទៃដី | 50 | ក្រុមហ៊ុន GG World Group (Cambodia) Development Co. Ltd. | 5000 | 2000 | 5/18/2005 | An Yang Yin Chang | ចិន | ស្ទឹងត្រែង | ស្ទឹងត្រែង | | កសក | |
| 100 | កាត់បន្ថយទំហំផ្ទៃដី | 50 | ក្រុមហ៊ុន Grand Land Agricultural Development (Cambodia) Co. Ltd. | 9854 | | 1/23/2006 | An Yang Yin Chang | ចិន | ស្ទឹងត្រែង | សេសាន | | កសក | |
| 101 | និរាសករណ៍ | 70 | ក្រុមហ៊ុន Un-Inter Trading and Development Group (Cambodia) | 7000 | | 10/12/2009 | Zhang Yi | ចិន | ស្ទឹងត្រែង | សេសាន | | កសក | |

| ល.រ | ស្ថានភាពបច្ចុប្បន្ន | រយៈពេលថ្មី(ឆ្នាំ) | ឈ្មោះក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច | ទំហំផ្ទៃដីសរុប (ហត) | ទំហំផ្ទៃដីថ្មី(ហត) | កាលបរិច្ឆេទចុះកិច្ចសន្យា | នាយកក្រុមហ៊ុន | សញ្ជាតិ | ខេត្ត | ស្រុក | ឃុំ | ដែនសមត្ថកិច្ច (មុនពេលផ្ទេរ) | អនុបយោគដី |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| 102 | កាត់បន្ថយទំហំផ្ទៃដី | 50 | ក្រុមហ៊ុន Sopheak Nika Investment Agro-industry Plants Co., Ltd | 10000 | | 8/8/2005 | ម៉ែន សុភក្រ្ត | ខ្មែរ | ស្ទឹងត្រែង | សេសាន | | កសក | |
| 103 | កាត់បន្ថយទំហំផ្ទៃដី | 50 | ក្រុមហ៊ុន Green Sea Agriculture Co. Ltd. ( previously Green Sea Industry Co. Ltd. ) | 100852 | 9800 | 11/23/2001 | ម៉ុង ឫទ្ធី | ខ្មែរ | ស្ទឹងត្រែង | សៀមប៉ាង ស្ទឹងត្រែង | | កសក | |
| 104 | កាត់បន្ថយទំហំផ្ទៃដី | 50 | ក្រុមហ៊ុន Cassava Starch Production Co. Ltd. | 7400 | | 9/13/1999 | កែវ វុទ្ធី | ខ្មែរ | ស្ទឹងត្រែង | ស្ទឹងត្រែង | | កសក | |
| 105 | និរាសករណ៍ | 50 | ក្រុមហ៊ុន ( Cambodia ) Research Mining and Development | 7200 | | 10/12/2009 | ឡាយ សុខលាង | ខ្មែរ | ស្ទឹងត្រែង | សេសាន | ក្បាលរមាស | កសក | |
| 106 | កាត់បន្ថយទំហំផ្ទៃដី | 50 | ក្រុមហ៊ុន Huayue Group Co. Ltd. ( previously Siv Guek Investment Co. Ltd. ) | 10000 | | 1/25/2006 | Caiping Zhang | ចិន | ស្ទឹងត្រែង | សេសាន | ក្បាលរមាស | កសក | |
| 107 | កាត់បន្ថយទំហំផ្ទៃដី បន្ទាប់ពីនិរាសករណ៍ | 50 | ក្រុមហ៊ុន សុខ ហេង វិនិយោគ | 7172 | | 1/27/2006 | ឡាយ សុខហេង | ខ្មែរ | ស្ទឹងត្រែង | សេសាន | | កសក | |
| 108 | កាត់បន្ថយទំហំផ្ទៃដី | 50 | ក្រុមហ៊ុន Phou Mady Investment Group | 10000 | | 1/24/2006 | អាន ស្រីបួយ | ខ្មែរ | ស្ទឹងត្រែង | សេសាន | ស្រែគរ | កសក | |
| 109 | កាត់បន្ថយទំហំផ្ទៃដី | 50 | ក្រុមហ៊ុន Sal Sophea Peanich Co. Ltd. | 9917 | | 8/8/2005 | ឈុន កុសល | ខ្មែរ | ស្ទឹងត្រែង | សេសាន | ស្ទឹងត្រែង | កសក | |
| 110 | កាត់បន្ថយទំហំផ្ទៃដី | 50 | ក្រុមហ៊ុន Flour Manufacturing Co. Ltd. | 7400 | 2965 | 9/13/1999 | កែវ វុទ្ធី | ខ្មែរ | ស្ទឹងត្រែង | ស្ទឹងត្រែង | | កសក | |

ប្រភព៖ ផ្ទៀងផ្ទាត់ និងត្រួតពិនិត្យដោយក្រុមអ្នកស្រាវជ្រាវផ្អែកលើប្រភពព័ត៌មានមកពី ក្រសួងកសិកម្ម ក្រសួងបរិស្ថាន រដ្ឋបាលសាលាខេត្ត អង្គការ NGO Forum គណៈកម្មាធិការវិនិយោគនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងគេហទំព័រអង្គការទិន្នន័យអភិវឌ្ឍន៍

**វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា**

អាសយដ្ឋានៈ ផ្ទះលេខ ៩-១១ ផ្លូវលេខ ៤៧៦ សង្កាត់ទួលទំពូង ១ ភ្នំពេញ កម្ពុជា
ប្រអប់សំបុត្រ ២២៩៥ ភ្នំពេញ-៣
ទូរស័ព្ទលេខៈ (៨៥៥-២៣) ២១៤ ៤២៩
ទូរសារលេខៈ (៨៥៥-២៣) ៩៩៤ ០៦៣
អ៊ីម៉ែលៈ ngoforum@ngoforum.org.kh
គេហទំព័រៈ www.ngoforum.org.kh